# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# របបគតិយុត្តនៃមតកសាសន៍នៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ: កញ្ញា **គេង គីមលី**

កញ្ញា **គុប ណាវ័ន្ត**

ណែនាំដោយ

លោក **ខិន ឧណ្ណារ៉ា**



ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **គេង គីមលី** និង **គុប ណារ័ត្ន** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្រ្ត ឆ្នាំ ទី៤ ជំនាន់ទី២៣ ឆ្នាំសិក្សា២០២២-២០២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច។

**សូមលំឱនកាយគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ៖**

**លោកឪពុកអ្នកម្តាយ** ជាទីស្រឡាញ់របស់កូនដែលបានផ្តល់កំណើត ព្រមទាំងបានលះបង់ទាំងកម្លាំង កាយ ចិត្ត និង ការជំនះរាល់ភាពលំបាកទាំងឡាយ ដើម្បីឲ្យកូនបានសិក្សារៀនសូត្រ ចាប់តាំងពីថ្នាក់បឋមសិក្សា រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រ។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង គណៈគ្រប់គ្រង លោក លោកស្រី សាស្រ្តចារ្យ និងបុគ្គលិកការិយាល័យស្រាវជ្រាវ ការិយាល័យសិក្សា** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់អស់ពីកម្លាំងកាយចិត្តក្នុងកិច្ចការ ដឹកនាំ គ្រប់គ្រង ជាពិសេសបង្ហាត់បង្រៀន ផ្តល់ដំបូន្មាន ក៏ដូចជាបទពិសោធន៍ល្អៗជាច្រើនដែល ជាទ្រព្យដ៏គាប់ប្រសើរ និងមានតម្លៃឥតគណនាសម្រាប់និស្សិតគ្រប់រូប ដើម្បីជាស្ពានចម្លងទៅថ្ងៃអនាគតដ៏ភ្លឺស្វាង។

**លោក ខិន វណ្ណារ៉ា** ដែលបានចំណាយពេលវេលាដ៏មានតម្លៃរបស់លោកក្នុង ការបង្ហាត់បង្ហាញ ណែនាំ ផ្តល់ដំបូន្មានល្អៗ ផ្តល់នូវប្រភពឯកសារ ជួយជ្រោមជ្រែង កែសម្រួលកំហុសឆ្គងទាំងឡាយ និងលើកទឹកចិត្តយើងខ្ញុំ ក្នុងការស្រាវជ្រាវ និងចងក្រងសារណាបញ្ចប់ការសិក្សារហូតបានជោគជ័យ។

ជាចុងក្រោយ យើងខ្ញុំសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធក្នុងលោក សូមតាមជួយថែរក្សាដល់លោកអ្នកមានគុណទាំងពីរ លោក លោកស្រី សាស្រ្តាចារ្យ និងអ្នកដែលបានជួយជ្រោមជ្រែងក្នុងកិច្ចការសារណានេះ ឱ្យជួបតែសេចក្តីសុខ និងសុភមង្គលជានិច្ចនិរន្តរ៍។

# អារម្ភកថា

សូមគោរពស្វាគមន៍ចំពោះលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ បងប្អូន មិត្តនិស្សិតទាំងអស់ ដែលមានបំណងពិនិត្យ សិក្សាស្រាវជ្រាវចំពោះសៀវភៅស្រាវជ្រាវមួយក្បាលនេះរបស់ពួកយើង។ ពួកយើងជានិស្សិត ជំនាញនីតិសាស្ត្រ ជំនាន់ទី២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ពិតជាមានកិត្តិយសណាស់ដែលបានទទួលការណែនាំ បង្ហាត់បង្ហាញចំពោះប្រធានបទនេះ យ៉ាងយកចិត្តទុកដាក់ពីសំណាក់លោកគ្រូ ជិន វណ្ណារ៉ា រហូតសម្រេចបាននូវសៀវភៅសារណាមួយក្បាលនេះឡើង សម្រាប់ឱ្យពួកយើងផ្ទាល់មានឱកាសប្រមូលចងក្រងនូវឯកសារច្បាប់ពាក់ព័ន្ធ ឱ្យកាន់តែជាក់ច្បាស់ទៅលើប្រធានបទ និងសម្រាប់ចែករំលែកចំណេះដឹងឱ្យអ្នកសិក្សាទាំងឡាយបានសិក្សាស្វែងយល់ទីលើប្រធានបទ។

គោលបំណងនៃការជ្រើសរើសយកប្រធានបទខាងលើមកស្រាវជ្រាវ និងចងក្រងគឺ ផ្អែកលើមូលដ្ឋាននៃចំណេះដឹង ដែលពាក់ព័ន្ធនឹងនីតិរដ្ឋប្បវេណី ហើយពួកយើងក៏មាននូវឆន្ទៈ និងបំណងចង់ជ្រាបច្បាស់អំពីប្រធានបទសម្រាប់ជាគ្រឹះក្នុងការដោះស្រាយបញ្ហាមួយចំនួន ដែលពួកយើងបានជួបប្រទះផ្ទាល់ ព្រមទាំងសង្កេតឃើញពីស្ថានភាពផ្ទាល់ក្នុងសង្គមដែលហាក់ ពុំសូវបានចាប់អារម្មណ៍ប្រើប្រាស់មូលដ្ឋានច្បាប់ដែលពាក់ព័ន្ធទៅនឹងប្រធានបទ រួមទាំងបំផុសស្មារតីដល់មនុស្សគ្រប់រូបឱ្យងាកមកប្រើប្រាស់ការផ្ទេរទ្រព្យសម្បត្តិតាមតាមឆន្ទៈចុងក្រោយទៅតាមសមត្ថភាពនៃការចាត់ចែងសិទ្ធិរបស់គេ និងប្រើប្រាស់ឱ្យត្រឹមត្រូវហើយមានប្រសិទ្ធភាពស្របទៅតាមច្បាប់។

យើងខ្ញុំក៏ទទួលស្គាល់ថាការខិតខំប្រឹងប្រែងរបស់យើង ពិតជាពុំអាចមានភាពល្អឥតខ្ចោះឡើយ និងដែលអាចបង្កជាកំហុសអចេតនាទាំងឡាយក្នុងសៀវភៅមួយក្បាលនេះ។ ដូច្នេះជាចុងក្រោយនេះពួកយើងខ្ញុំរង់ចាំទទួលការរិះគន់ពី លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ សំណាក់មិត្តអ្នកអាន អ្នកស្រាវជ្រាវ មិត្តរួមជំនាន់ និងប្អូនៗជំនាន់ក្រោយ រាល់កំហុសឆ្គងដែលកើតឡើងដោយអចេតនា នូវពាក្យពេចន៍ វគ្គ ឃ្លា វេយ្យាករណ៍ អក្ខរក្រម ដើម្បីជួយកែលំអរអោយសៀវភៅនេះកាន់តែល្អប្រសើឡើង។

ជាទីបញ្ចប់ យើងខ្ញុំសូមជូនពរដល់ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ មិត្តអ្នកអាន អ្នកស្រាវជ្រាវ និងមិត្តនិស្សិតទាំងអស់ ទទួលបាននូវពរទាំងឡាយបួន សម្បត្តិបី អរិយទ្រព្យប្រាំពីរ និងមានសេក្តីសុខ សំណាងល្អគ្រប់ពេលវេលា ជោគជ័យលើការសិក្សា និងជោគជ័យនូវគោលបំណងដែលប៉ងគ្រប់ៗគ្នាកុំបីខានឡើយ។

# មាតិកា

**សេចក្ដីផ្ដើម** ........ ១

## ជំពូកទី១

## សញ្ញាណទូទៅនៃមតកសាសន៍

**ផ្នែកទី១៖ សញ្ញាណទូទៅ និងលក្ខណៈសម្បត្តិរបស់ភាគី ក្នុងមតកសាសន៍** ........ ៣

១.១ និយមន័យនៃមតកសាសន៍ ........ ៤

១.១.១ និយមន័យកំណត់ក្នុងន័យទូទៅ ........ ៤

១.១.២ និយមន័យយោងតាមសន្ធានុក្រមរដ្ឋប្បវេណី ........ ៥

១.២ ចំណុចដែលអាចមានក្នុងមតកសាសន៍ ........ ៦

១.២.១ ការកំណត់ចំណែកមត៌ក ........ ៦

១.២.២ ការកំណត់នូវវិធីបែងចែកដោយមតកសាសន៍ ជាអាទិ៍ ........ ៦

១.២.៣ ការធ្វើអនុប្បទានទ្រព្យសម្បត្តិ ........ ៧

១.២.៤ ការធ្វើអនុប្បទានទ្រព្យសម្បត្តិចំពោះសន្តតិជន ........ ៨

១.២.៥ ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍ ........ ៩

១.២.៦ ចំណុចផ្សេងៗ ........ ៩

១.៣ លក្ខណៈសម្បត្តិ នៃភាគីក្នុងមតកសាសន៍ ........ ៩

១.៣.១ បុគ្គលដែលមានលក្ខណៈជាមតកជន ........ ១០

១.៣.១.១ សមត្ថភាពបុគ្គលដែលអាចធ្វើមតកសាសន៍ ........ ១០

១.៣.១.២ សមត្ថភាពបុគ្គលនាពេលធ្វើមតកសាសន៍ ........ ១១

១.៣.២ លក្ខណៈសម្បត្តិ នៃសន្តតិជន ........ ១១

១.៣.២.១ សមត្ថជនដែលមានលក្ខណៈជាសន្តតិជន ........ ១១

១.៣.២.៣ សមត្ថជនដែលត្រូវបានហាមឃាត់ក្នុងការក្លាយជាសន្តតិជន ........ ១២

**ផ្នែកទី២៖ ប្រភេទនៃមតកសាសន៍** ........ ១៥

២.១ ប្រភេទមតកសាសន៍ ទម្រង់ធម្មតា ........ ១៥

២.១.១ ទម្រង់មតកសាសន៍ដោយលិខិតយថាភូត ........ ១៥

២.១.២ ទម្រង់មតកសាសន៍ដោយលិខិតឯកជន ........ ១៦

២.១.៣ ទម្រង់មតកសាសន៍ដោយលិខិតសម្ងាត់ ........ ១៦

២.២ ប្រភេទមតកសាសន៍ ទម្រង់ពិសេស ........ ១៧
២.២.១ មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ ........ ១៧
២.២.២ មតកសាសន៍នៃជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ........ ១៨
២.២.៣ មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង ជាអាទិ៍ ........ ១៨
២.២.៤ មតកសាសន៍នៃជនដែលមិនអាចនិយាយបាន ........ ១៩
២.២.៥ មតកសាសន៍នៃជនជាតិខ្មែរដែលរស់នៅបរទេស ........ ២០

## ជំពូកទី២

## អានុភាព និងការលុបចោលមតកសាសន៍

**ផ្នែកទី១៖ អានុភាពនៃមតកសាសន៍** ........ ២២
១.១ រយៈពេលនៃការបង្កើតអានុភាព ........ ២២
១.២ អានុភាពនៃការកំណត់ចំណែកមត៌ក ជាអាទិ៍ ........ ២៣
១.៣ អានុភាពនៃមរណភាពនៃជនដែលត្រូវបានសន្មតថាជាសន្តតិជន ........ ២៣
១.៤ អានុភាពនៃការកម្រិតមតកសាសន៍ ចំពោះអ្នកអាណាព្យាបាលទូទៅ ........ ២៤
១.៥ អានុភាពនៃសិទ្ធិទទួលទ្រព្យសម្បត្តិ ក្នុងករណីដែលអច្ច័យទានមោឃៈ ជាអាទិ៍ ........ ២៤
**ផ្នែកទី២៖ ការលុបចោលមតកសាសន៍** ........ ២៥
២.១ ការលុបចោលដោយទម្រង់នៃមតកសាសន៍ ........ ២៥
២.២ ការលុបចោលមតកសាសន៍ដោយការចាត់ចែងនាពេលនៅរស់ ........ ២៦
២.៣ ការលុបចោលដោយការបដិសេធលិខិតមតកសាសន៍ ជាអាទិ៍ ........ ២៧

## ជំពូកទី៣

## អច្ច័យទាន និងការអនុវត្តមតកសាសន៍

**ផ្នែកទី១៖ អច្ច័យទាន** ........ ២៩
១.១ លក្ខណៈនៃអច្ច័យទាន ........ ២៩
១.១.១ និយមន័យ ........ ២៩
១.១.២ ប្រភេទអច្ច័យទាន ........ ៣០
១.១.៣ រយៈពេលអច្ច័យទានបង្កើតអានុភាព ........ ៣១
១.២ ការយល់ព្រម និងការបោះបង់អច្ច័យទាន ........ ៣១
១.២.១ ការបោះបង់អច្ច័យទាន និង សិទ្ធិលុបចោលសច្ចានុម័តទទួលស្គាល់ ឬ បោះបង់ ........ ៣១

១.២.២ ការទទួលស្គាល់ ឬ បោះបង់ករណីអច្ច័យលាភីជាសន្តតិជន ........ ៣២
១.២.៣ មរណភាពនៃអច្ច័យលាភី........ ៣២
១.២.៤ ការទទួលស្គាល់ ឬ បោះបង់ដោយសន្តតិជនអច្ច័យលាភី........ ៣៣
១.៣ អច្ច័យទានភ្ជាប់បន្ទុក........ ៣៣
១.៣.១ ការលុបចោលអច្ច័យទានភ្ជាប់បន្ទុក ........ ៣៣
១.៣.២ សិទ្ធិ និង ករណីយកិច្ចអច្ច័យលាភីភ្ជាប់បន្ទុក........ ៣៤

**ផ្នែកទី២៖ ការអនុវត្តមតកសាសន៍** ........ ៣៤

២.១ អ្នកប្រតិបត្តិមតកសាសន៍ ........ ៣៤
២.១.១ ការជ្រើសតាំង និងជនមានសមត្ថភាពជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍........ ៣៤
២.១.២ តួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍........ ៣៥
២.១.៣ កម្រៃ និង សាហ៊ុយនៃអ្នកប្រតិបត្តិមតកសាសន៍........ ៣៦
២.១.៤ ការលាឈប់ និងបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍ ........ ៣៨
២.២ នីតិវិធីក្នុងបើកមតកសាសន៍ ........ ៣៨
២.២.១ អត្ថន័យនៃការបើកមតកសាសន៍ ........ ៣៩
២.២.២ ការពិនិត្យ និងការបើកលិខិតមតកសាសន៍........ ៣៩
២.២.៣ គោលបំណងនៃការបញ្ជាក់មតកសាសន៍........ ៣៩
២.២.៤ នីតិវិធីសំខាន់ដែលត្រូវគោរពតាមមុនឡើងតុលាការ ........ ៤០
២.២.៥ នីតិវិធីពិនិត្យបញ្ជាក់នៅតុលាការ ........ ៤០
២.២.៥.១ សមត្ថកិច្ច........ ៤០
២.២.៥.២ ការកោះហៅសន្តតិជន ជាអាទិ៍........ ៤១
២.២.៥.៣ កាលបរិច្ឆេទនៃការពិនិត្យបញ្ជាក់........ ៤១

**សេចក្តីសន្និដ្ឋាន** ........ ៤៣

**អនុសាសន៍** ........ ៤៤

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្ដីផ្ដើម

នៅរាល់សកម្មភាពរស់នៅរបស់មនុស្សក្នុងសង្គម គឺជាមូលដ្ឋានដល់ការចងឡើងនូវបញ្ញត្តិគតិយុត្ត នានាសម្រាប់បង្កើតទម្លាប់ ជម្រុញ កែប្រែ និងណែនាំ សង្គមមនុស្សក៏ដូចជាអ្នកអនុវត្ត ឲ្យមាននូវគ្រឹះក្នុងការដោះស្រាយបញ្ហានានាដែលកើតឡើងទៅតាម របៀប បែបបទនីតិវិធីដែលត្រឹមត្រូវ។ ជាក់ស្ដែងក្រមរដ្ឋប្បវេណី ២០០៧ ត្រូវបានអ្នកសិក្សាទទួលស្គាល់ថាជាច្បាប់ដែលកំណត់គោលការណ៍ទូទៅក្នុងទំនាក់ទំនងនៃនីតិឯកជន។ ដោយសារការបញ្ញត្តិក្នុងច្បាប់ និង ការអនុវត្តជាក់ស្ដែងមានលក្ខណៈទាមទារឱ្យមានភាពស៊ីជម្រៅដល់ការបកស្រាយច្រើន ទើបធ្វើឱ្យក្រមរដ្ឋប្បវេណី ត្រូវផ្សារភ្ជាប់ទៅនឹងច្បាប់ និងឯកសារពាក់ព័ន្ធជាច្រើនរួមមាន សន្ទានុក្រមរដ្ឋប្បវេណី សេចក្ដីពន្យល់អំពីមាត្រានីមួយៗក្រមរដ្ឋប្បវេណី សេចក្ដីពន្យល់អំពីក្រមរដ្ឋប្បវេណី ជាដើម ដើម្បីសម្រួលដល់អ្នកសិក្សា និងអ្នកអនុវត្ត លើការបកស្រាយ និងអនុវត្តន៍ស្របទៅតាមឆន្ទៈនៃក្រមរដ្ឋប្បវេណី។

ដោយសារវិសាលភាពនៃក្រមរដ្ឋប្បវេណីមានលក្ខណៈធំទូលាយគ្របដណ្ដប់លើវិស័យឯកជន នូវគ្រប់រូបភាព ប៉ុន្តែប្រធានបទយើងនឹងបកស្រាយចំពោះទ្រឹស្ដី និងបទបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណីគន្ថីទី៨ស្ដីពីសន្តតិកម្ម ក្នុងនោះដែរច្បាប់ក៏បានបែងចែងពីការធ្វើសន្តតិកម្មតាមពីររបៀប ទីមួយគឺការបែងចែកសន្តតិកម្មតាមច្បាប់កំណត់ និងបែងចែកទៅតាមឆន្ទៈរបស់មតកជន[1] គឺតាមរយៈមតកសាសន៍។ យោងតាមបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីការបែងចែកសន្តតិកម្មអាចធ្វើឡើងតាមពីររបៀប អាស្រ័យទៅតាមស្ថានភាពនាពេលបើកសន្តតិកម្មនោះថា មតកជនបានបន្សល់ទុកនូវបណ្ដាំដើម្បីកំណត់បែងចែកទ្រព្យរបស់ខ្លួន ឬគ្មានបណ្ដាំ។ ក្នុងករណីដែលពុំមានបណ្ដាំនោះទេ សន្តតិកម្មនឹងត្រូវបានបែងចែកតាមការកំណត់នៃច្បាប់ ប៉ុន្តែបើសន្តតិកម្មនោះប្រព្រឹត្តិទៅតាមមតកសាសន៍នោះគេត្រូវអនុវត្តន៍សន្តតិកម្មទៅតាមឆន្ទៈនៃម្ចាស់បណ្ដាំ។ យ៉ាងណាមិញទោះជាវាជាប្រភេទសន្តតិកម្មតាមច្បាប់ ឬសន្តតិកម្មតាមមតកសាសន៍ក៏សុទ្ធតែត្រូវបង្កើតអានុភាពតាមរយៈមរណភាពរបស់មតកជន ប៉ុន្តែក្នុងសញ្ញាណគតិយុត្តនៃរបបសន្តតិកម្មតាមមតកសាសន៍ក៏បានបង្ហាញខ្លះៗពីការបែងចែកនូវប្រទានកម្មដោយមូលហេតុមរណភាព ឬអច្ច័យទានដែរ ដូច្នេះហើយទើបយើងក៏មានលើកឡើងនូវចំណុចដែលពាក់ព័ន្ធនឹងអច្ច័យទានមកបកស្រាយដោយពុំមានភាពលម្អិតដូចមតកសាសន៍នោះទេ។

នៅក្នុងសង្គមជាក់ស្ដែង ប្រជាជនខ្មែរ ការប្រើប្រាស់បញ្ញត្តិនានាដែលពាក់ព័ន្ធនឹងសន្តតិកម្មតាមមតកសាសន៍ ពុំមានលក្ខណៈញឹកញាប់នោះទេ បញ្ហាដែលត្រូវបានដោះស្រាយដោយបញ្ញត្តិទាំងនោះក៏អ្នកអនុវត្តពុំសូវបានជួបប្រទះដូចគ្នា ដោយបញ្ហានេះអាចឈរលើមូលហេតុផ្សេងៗដូចជា ទំនៀមទម្លាប់ប្រជាពលរដ្ឋ ប្រព័ន្ធ

[1] មាត្រា១១៤៥ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

គ្រប់គ្រងទ្រព្យសម្បត្តិ ការស្វែងយល់អំពីលក្ខខណ្ឌដែលច្បាប់តម្រូវជាដើម។ ប្រសិនបើការបែងចែកទ្រព្យសម្បត្តិនេះធ្វើឡើងដោយសន្តិវិធីតាមការពិភាក្សាបែងចែក នោះការអនុវត្តរបបសន្តតិកម្មពុំបង្កជាបញ្ហាចោទនោះទេ ប៉ុន្តែផ្ទុយទៅវិញបើវាបង្កជាទំនាស់នោះនឹងនាំឲ្យលំបាកដល់ការដោះស្រាយ។ ទៀតសោតសូម្បីតែនៅពេលមតកជននៅរស់រានមានជីវិតក៏អាចប្រឈមនឹងបញ្ហាពាក់ព័ន្ធនឹងការបែងចែកទ្រព្យ ដូចជាទំនាស់ ជម្លោះ ការដណ្តើម ផលប្រយោជន៍គ្នាពុំដាច់ស្រេច ទម្រាំពេលដែលមតកជនទទួលមរណភាពវា គឺកាន់តែជាបញ្ហាស្មុគស្មាញក្នុងការដោះស្រាយថែមទៀត ខណៈដែលបុគ្គលជាម្ចាស់កម្មសិទ្ធិបានរលត់នូវភាពជារូបវន្តបុគ្គល ពុំអាចមកបង្ហាញឆន្ទៈនានា ទៅអ្នកអនុវត្តក៏ដូចជាអ្នកទទួលផលប្រយោជន៍ ដែលនាំឱ្យខូចខាតផលប្រយោជន៍ ទ្រព្យសម្បត្តិ ពេលវេលា និងបង្កឱ្យមានផលប៉ះពាល់ដល់ចំណងទំនាក់ទំនងល្អក្នុងគ្រួសារទៀតផង។ បន្ថែមពីនេះបើទោះជាប្រជាជនមួយចំនួនបានបង្ហាញឆន្ទៈតាមរយៈមតកសាសន៍ ប៉ុន្តែទីបំផុតពួកគេនៅតែជួបប្រទះនឹងបញ្ហាដោយសារការយល់ដឹង និង ចំណាត់ចែងតាមតែការយល់ឃើញរបស់ពួកគេដោយមិនបានគោរពលក្ខខណ្ឌនៃច្បាប់ទាមទារ ដែលពួកគេឈរលើមូលហេតុថាខ្លួនជាម្ចាស់នៃកម្មសិទ្ធិ មានសិទ្ធិ ប៉ុន្តែសិទ្ធិទាំងនោះត្រូវបានប្រើប្រាស់ផ្ទុយពីមូលដ្ឋាននៃច្បាប់ ក្រោមរូបភាពជាឧទាហរណ៍ មតកសាសន៍ដែលខុសលក្ខខណ្ឌទម្រង់ មតកសាសន៍ដែលពុំអាចកើតមានដោយផ្ទុយនឹងទំនៀមទម្លាប់ និងសណ្តាប់ធ្នាប់ល្អក្នុងសង្គមជាដើម។

ដូច្នេះដើម្បីជាប្រយោជន៍នៃការសិក្សា ឆ្លើយតបនឹងបញ្ហាក្នុងសង្គម រួមទាំងជាប្រយោជន៍ការសិក្សាស្រាវជ្រាវបានលម្អិត និង ស៊ីជម្រៅរបស់ពួកយើងផ្ទាល់ និងជាប្រយោជន៍ក្នុងការចែករំលែកដល់អ្នកច្បាប់គ្រប់ជំនាន់ក៏ដូចជាប្រជាពលរដ្ឋទូទៅដែលមានបំណងចង់ជ្រាបច្បាស់អំពីមតកសាសន៍ ថានឹងត្រូវគោរពតាមលក្ខខណ្ឌច្បាប់ដូចម្តេចខ្លះទើបត្រូវបានទទួលស្គាល់ និងទទួលការការពារដោយច្បាប់យ៉ាងត្រឹមត្រូវ មិនបង្កការលំបាកនាពេលខាងមុខ។ ចំពោះការសិក្សាលើប្រធានបទ **“របបគតិយុត្តនៃមតកសាសន៍នៅកម្ពុជា”** មានបែងចែកជាបីជំពូកដែល ជំពូកទី១ បង្ហាញអំពី **សញ្ញាណទូទៅនៃមតកសាសន៍**។ ចំណែក **អានុភាព និងការលុបចោលមតកសាសន៍** នឹងលើកមកពន្យល់នៅ ជំពូកទី២ ជាចុងក្រោយ ជំពូកទី៣ យើងបកស្រាយអំពី **អច្ច័យទាន និងការអនុវត្តមតកសាសន៍**។

# ជំពូកទី១
# សញ្ញាណទូទៅនៃមតកសាសន៍

# ជំពូកទី១

# សញ្ញាណទូទៅនៃមតកសាសន៍

ក្នុងស្ថានភាពនៃការយល់ឃើញជាទូទៅរបស់ប្រជាជនខ្មែរគេនិយមហៅថា "បណ្តាំមត៌ក" ក្នុងអត្ថន័យជាការផ្តាំផ្ញើដល់អ្នកនៅរស់រានមានជីវិតពីសំណាក់អ្នកស្លាប់ ក្នុងការចាត់ចែងនូវទ្រព្យរបស់ខ្លួន។ ជាវប្បធម៌នៃការយល់ដឹងទូទៅ គេសន្និដ្ឋានថាអ្នកស្លាប់ដែលជាម្ចាស់នៃទ្រព្យអាចធ្វើអ្វី ឬ មានឆន្ទៈផ្តល់ឲ្យនរណាក៏បាន ទៅតាមការយល់ឃើញរបស់ពួកគេ។ ប៉ុន្តែដើម្បីទទួលបាននូវអានុភាពគតិយុត្តទាមទារឲ្យម្ចាស់បណ្តាំត្រូវស្វែងយល់អំពី ចំណងគតិយុត្តមួយចំនួនដែលពាក់ព័ន្ធ ហើយលិខិតបណ្តាំមត៌កនោះ ដូចដែលយើងនឹងលើកមកពន្យល់នៅចំណុចបន្ទាប់។ ផ្នែកទី១៖ សញ្ញាណទូទៅ និងលក្ខណៈសម្បត្តិរបស់ភាគី ក្នុងមតកសាសន៍, ផ្នែកទី២ ៖ ប្រភេទនៃមតកសាសន៍។

## ផ្នែកទី១៖ សញ្ញាណទូទៅ និងលក្ខណៈសម្បត្តិរបស់ភាគី ក្នុងមតកសាសន៍

បទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីក្នុងគន្ថីទី៨ អំពីសន្តតិកម្ម ចាប់ពីជំពូកទី១ មកបានបង្ហាញពីសញ្ញាណនៃរបបសន្តតិកម្មដែលត្រូវបានចាប់ផ្តើមឡើងដោយមរណភាពរបស់មតកជន ហើយការបែងចែកសន្តតិកម្មត្រូវផ្អែកលើបញ្ញត្តិនៃច្បាប់ ឬដោយឆន្ទៈរបស់មតកជន។ ដោយឡែកចំណុចដែលប្រធានបទយើងផ្តោតសំខាន់គឺសន្តតិកម្មតាមមតកសាសន៍។ សន្តតិកម្មតាមមតកសាសន៍គឺការបែងចែកសន្តតិកម្មគោរពនូវឆន្ទៈរបស់មតកជន មតកជននាពេលនៅរស់អាចសម្តែងនូវឆន្ទៈសេរីក្នុងការបែងចែកទ្រព្យរបស់ខ្លួន ប៉ុន្តែមិនមែនគ្រប់ឆន្ទៈដែលមតកជនធ្វើសុទ្ធតែមានអានុភាពអនុវត្តន៍តាមទាំងស្រុងនោះទេ មិនតែប៉ុណ្ណោះទោះជាក្រោយមរណភាពរបស់មតកជនមតកសាសន៍ត្រូវបានបើកក៏ដោយក្តី ប៉ុន្តែប្រសិនបើមតកសាសន៍នោះពុំមានសុពលភាពត្រឹមត្រូវតាមច្បាប់នោះទេ មតកសាសន៍នោះក៏អាចចាត់ទុកជាមោឃៈផងដែរ ដូច្នេះហើយទើបទាមទារឲ្យការធ្វើមតកសាសន៍ត្រូវគោរពតាមលក្ខខណ្ឌនានាដែលកំណត់តាមច្បាប់ចៀសវាងបញ្ហានាពេលក្រោយ។

ទោះជាមតកសាសន៍ជាសកម្មភាពឯកតោភាគីដែលមតកជនសម្តែងឆន្ទៈតែម្ខាងក៏ពិតមែន តែនៅពេលមតកសាសន៍បង្កើតអានុភាព សន្តតិជននឹងក្លាយជាភាគីនៃសន្តតិកម្មដែលត្រូវសម្តែងឆន្ទៈយល់ព្រម ឬបោះបង់សន្តតិកម្មនោះ ហេតុនេះហើយទើបយើងប្រើពាក្យថា ភាគីក្នុងមតកសាសន៍ បន្ថែមពីនេះមិនមែនបុគ្គលគ្រប់រូបសុទ្ធតែត្រូវបានកំណត់ថាជាមតកជន ឬសន្តតិជនទាំងស្រុងនោះទេ ជាពិសេសនៅពេលដែលពួកគេពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដូច្នេះក្នុងចំណុចបន្តបន្ទាប់យើងនឹងលើកឡើងអំពីលក្ខណៈសម្បត្តិនៃបុគ្គលទាំងនោះយកមកបកស្រាយពន្យល់។

## ១.១ និយមន័យនៃមតកសាសន៍

ក្នុងរបបសន្តតិកម្មការសម្តែងឆន្ទៈក្នុងមតកសាសន៍ គឺកិច្ច ឬ សកម្មភាពឯកតោភាគី ដែលឆន្ទៈត្រូវធ្វើឡើងដោយមតកជនក្នុងការបង្ហាញឆន្ទៈបែងចែកទ្រព្យរបស់ខ្លួនទៅឲ្យសន្តតិជន បន្ទាប់ពីខ្លួនបានទទួលមរណភាព។ លើសពីនេះអានុភាពនៃមតកសាសន៍ មតកជនក៏អាចសម្តែងឆន្ទៈក្នុងការធ្វើអច្ច័យទាន ទៅឲ្យសន្តតិជន ឬតតិយជន ហើយអានុភាពនៃឆន្ទៈនោះត្រូវកើតមានដោយមរណភាពនៃមតកជន ពោលគឺនៅពេលម្ចាស់សិទ្ធិត្រូវបានរលត់សិទ្ធិរបស់ខ្លួន ហើយសិទ្ធិទាំងនោះត្រូវបានផ្ទេរដោយស្វ័យប្រវត្តិដោយគោរពតាមឆន្ទៈចុងក្រោយនោះ ប៉ុន្តែសន្តតិជនក៏ត្រូវបង្ហាញឆន្ទៈក្នុងការព្រមព្រៀងទទួលផងដែរ។ សន្តតិកម្មតាមមតកសាសន៍ និងអច្ច័-យទាន ពុំដូចគ្នានោះទេ ហើយចំណុចនេះយើងនឹងលើកមកបកស្រាយនៅជំពូកទី៣។ ក្នុងចំណុចបន្ទាប់យើងនឹងលើកយកនិយមន័យមតកសាសន៍ កំណត់ក្នុងន័យទូទៅ និងយោងតាមសន្ធានក្រមរដ្ឋប្បវេណី ដើម្បីមកបង្ហាញ។

### ១.១.១ និយមន័យកំណត់ក្នុងន័យទូទៅ

យោងតាមវចនានុក្រមសម្តេចសង្ឃរាជ **ជួន ណាត** ពុំបានកំណត់ជារួមអំពីនិយមន័យជារួមរបស់ពាក្យថា "មតកសាសន៍" នោះទេ។ ដូច្នេះដើម្បីឲ្យយើងអាចកំណត់និយមន័យនៃពាក្យនេះបានយើងត្រូវផ្អែកលើការទាញនិយមន័យដោយបន្សំពាក្យ ដើម្បីអាចកំណត់ន័យពាក្យ "មតកសាសន៍" ឲ្យន័យរួមមួយអាចប្រើប្រាស់បានដើម្បីលើកយកមកធ្វើការបកស្រាយ។ វចនានុក្រម សម្តេចសង្ឃរាជ **ជួន ណាត** បានកំណត់ន័យនៃពាក្យ "មតក" និង ពាក្យ "សាសន" ដូចខាងក្រោម៖

- "មតក" (ម:ត:ក:) : (បា. មតក; សំ. ម្ឫតក) បុគ្គលដែលស្លាប់ហើយ ។

- "សាសន" (-ស:ន៉ៈ) : (បា.សំ. (គាសន) ពាក្យបណ្តាំ, ពាក្យផ្តាំផ្ញើ, ពាក្យប្រៀនប្រដៅ, ការប្រៀនប្រដៅ,សាសនា, លទ្ធិ, ពាក្យបង្គាប់, ការបង្គាប់បញ្ជា, ដំណឹង, សំបុត្រ, ពាក្យប្រកាស, ការប្រកាសប្រាប់, ការជឿស្តាប់,ការដាក់ទណ្ឌកម្ម, ការផ្ចាលទោស, ការកែសម្រួល, ការគ្រប់គ្រង ការត្រួតត្រា ។

ដូច្នេះ ពាក្យ "មតកសាសន៍" មានន័យថា បុគ្គលដែលស្លាប់ទៅហើយមានពាក្យបណ្តាំ ពាក្យផ្តាំផ្ញើ ជាសំបុត្រ ការប្រកាសជាដើម។

ទន្ទឹមនឹងនេះយើងបានពិនិត្យឃើញថា ក្នុងនិយមន័យពាក្យ "មតក" បានរំលេចអត្ថន័យនៃពាក្យ "មតកសាសន៍" (ម:ត:ក:សាស) ថាជាបណ្តាំបុគ្គលស្លាប់ (បណ្តាំខ្មោច)។[2]

[2] វចនានុក្រមខ្មែរ ទម្រង់អេឡិចត្រូនិច របស់សម្តេចព្រះសង្ឃរាជ ជួន ណាត Version១.២.២

ដោយឡែក ក្នុងបរិបទនៃការរស់នៅរបស់មនុស្សក្នុងសង្គមឆ្លងកាត់ពីមួយសម័យកាល ទៅមួយសម័យកាល ប្រជាជនទូទៅយល់ដឹងអំពីមតកសាសន៍ ក្រោមពាក្យថា បណ្ដាំមត៌ក ដែលគេយល់ថាវា ជាការផ្ដាំ គ្រប់រូបភាព អំពីការចែកទ្រព្យរបស់បុគ្គលម្នាក់មុនពេលដែលគាត់បានទទួលមរណភាព បណ្ដាំមត៌កនោះអាចជា ការទុកនូវសំបុត្របណ្ដាំដោយសរសេរ ការផ្ដាំដោយផ្ទាល់ទៅសមាជិកគ្រួសារ និងខ្លះទៀតបានផ្ដែផ្ដាំទៅតតិយជនដទៃ ហើយក៏អាចជា មេភូមិ មេឃុំ អាជ្ញាធរមូលដ្ឋានទៀតផង។ ការយល់ឃើញ និងការអនុវត្តរបៀបនេះពុំត្រូវលើកឡើង និងបានបដិសេធទាំងស្រុងថាខុស ឬត្រូវនោះទេ ហើយក៏បានបន្តពីមួយជំនាន់ទៅមួយជំនាន់ រហូតមកដល់បច្ចុប្បន្ន ដោយកង្វះនូវចំណេះដឹងច្បាប់ដែលពាក់ព័ន្ធហើយបញ្ហាចោទក៏គេពុំសូវបានលើកឡើងមកបង្ហាញឲ្យទូលំទូលាយ ដែលធ្វើឲ្យការអនុវត្តហាក់នៅខ្វះចន្លោះច្រើន។

### ១.១.២ និយមន័យយោងតាមសន្ធានុក្រមផ្នែករដ្ឋប្បវេណី

យោងតាមសន្ធានុក្រមផ្នែករដ្ឋប្បវេណីដែលភ្ជាប់ជាឧបសម្ព័ន្ធក្នុងក្រមរដ្ឋប្បវេណី ពាក្យ "មតកសាសន៍" ត្រូវបានកំណត់ ជាលិខិតបណ្ដាំដែលបុគ្គលម្នាក់ បានធ្វើឡើងតាមទម្រង់ដែលកំណត់ដោយច្បាប់ ដើម្បីសម្ដែងឆន្ទៈចុងក្រោយ អំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនជាអាទិ៍ បន្ទាប់ពីទទួលមរណភាព។[3] បើនិយាយឱ្យងាយយល់ មតកសាសន៍ ជាបណ្ដាំចុងក្រោយរបស់មតកជន ដែលគាត់ចង់ធ្វើការចាត់ចែងទ្រព្យរបស់គាត់ទុកជាមុនទៅឱ្យសន្តតិជនរបស់គាត់ ឬជនដែលគាត់ចង់ឱ្យ មុនពេលគាត់ស្លាប់ទៅ ព្រោះថាបើសិនជាគាត់ស្លាប់ទៅដោយមិនបានធ្វើមតកសាសន៍នាពេលនៅរស់នោះទេ នោះទ្រព្យរបស់គាត់នឹងត្រូវធ្វើការបែងចែកទៅតាមច្បាប់ ដែលវាអាចខុសពីបំណងរបស់គាត់។ ការសម្ដែងឆន្ទៈក្នុងមតកសាសន៍ គឺជាសញ្ញាណនៃគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន គឺគោរពនូវឆន្ទៈសេរីរបស់មតកជន ប៉ុន្តែទាមទារឲ្យមានភាពស្របគ្នាទៅនឹងបញ្ញត្តិច្បាប់ដែលពាក់ព័ន្ធដើម្បីឲ្យបុគ្គលគ្រប់រូបទទួលបាននូវសុវត្ថិភាពគតិយុត្ត។

ផ្ទុយទៅវិញ ទោះជារបបសន្តតិកម្មតាមមតកសាសន៍ មានឆន្ទៈផ្ដល់នូវសេរីភាពបុគ្គលឯកជនច្រើនក្នុងការបង្ហាញឆន្ទៈសេរី ចំពោះការបែងចែកទ្រព្យរបស់គេយ៉ាងណាក្ដីក៏មតកសាសន៍មិនអាចធ្វើឡើងបំពាននូវភាគបម្រុងបាននោះទេ។ ដើម្បីធានាថាបុគ្គលដែលមានសិទ្ធិលើភាគបម្រុង មិនត្រូវបានបំពានសិទ្ធិក្នុងការទទួលបានផលនៃភាគបម្រុងនោះ ឬការបែងចែកសន្តតិកម្មបានធ្វើឡើងដោយបំពាននូវភាគបម្រុងនោះ ទើបក្រមរដ្ឋប្បវេណីបានបញ្ញត្តអំពីភាគបម្រុងចំពោះបុគ្គលដែលមានសិទ្ធិលើភាគបម្រុង វិធីកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង និងការរលត់សិទ្ធិទាមទារឲ្យកាត់បន្ថយភាគបម្រុង ប៉ុន្តែចំណុចដែលពាក់ព័ន្ធនឹងភាគបម្រុងនេះពុំមែនជាអ្វីដែលយើងនឹងលើកយកមកពន្យល់បកស្រាយលម្អិតនោះទេ។

[3] សន្ធានុក្រមផ្នែករដ្ឋប្បវេណី ដកស្រង់ពីសន្ធានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី, ល.រ១១៨

## ១.២ ចំណុចដែលអាចមានក្នុងមតកសាសន៍

ក្នុងគន្ថីទី៨ ជំពូកទី៣ ផ្នែកទី៣ បានបញ្ញត្តអំពីចំណុចនៃមតកសាសន៍។ បញ្ញត្តិទាំងនោះចែងពីគោលគំនិតជាមូលដ្ឋានដល់ការកំណត់អំពីចំណុចដែលអាចមាននៅក្នុងការធ្វើមតកសាសន៍។ ដោយសារមតកជនមានសេរីភាពក្នុងការបង្ហាញឆន្ទៈរបស់ខ្លួនក្នុងមតកសាសន៍ ច្បាប់ពុំបានបញ្ញត្តជាក់លាក់ថាក្នុងមតកសាសន៍មួយ គេត្រូវតែសរសេរ ឬកំណត់អំពីអ្វីមួយនោះទេ ផ្ទុយទៅវិញបទប្បញ្ញត្តិទាំងនោះបានផ្តល់គោលគំនិតដល់អ្នកដែលមានបំណងធ្វើមតកសាសន៍នូវចំណុចមួយចំនួនដែលអាចមានក្នុងនោះ ដើម្បីជាមូលដ្ឋានដល់ការកំណត់អំពីទម្រង់ ការបែងចែក លទ្ធភាពរបស់មតកជន នៅក្នុងមតកសាសន៍។ នៅក្នុងមតកសាសន៍មួយ គេអាចកំណត់នូវចំណុចមួយចំនួនដូចខាងក្រោម៖

### ១.២.១ ការកំណត់ចំណែកមត៌ក

ជាគោលការណ៍នៅក្នុងលិខិតមតកសាសន៍មួយ មតកជនអាចកំណត់ចំណែកមត៌ក របស់សហសន្តតិជន ឬអាចបង្ហាញឆន្ទៈផ្ទុយពីមាត្រា ១១៦៣ បាន។[4] ប៉ុន្តែយ៉ាងណាត្រូវរក្សានូវគោលការណ៍ មិនបំពានលើភាគបម្រុង។ មានន័យថាផ្អែកតាមឆន្ទៈសេរីនៃការធ្វើមតកសាសន៍ មតកជនអាចកំណត់ដោយខ្លួនឯងក្នុងការបែងចែកនូវទ្រព្យសម្បត្តិរបស់ខ្លួនទៅឱ្យសន្តតិជនរបស់ខ្លួន ត្រង់ចំណុចនេះច្បាប់ពុំហាមឃាត់ក្នុងការកំណត់ចំណែកដោយចែកជាប្រភាគ ឬបែងចែកនូវវត្ថុជាក់លាក់ណាមួយឡើយ បន្ថែមពីនោះទៅទៀតទាក់ទងនឹងការកំណត់ចំណែកមត៌កក៏មិនរារាំងចំពោះអ្នកទទួលផលប្រយោជន៍ពិសេសផងដែរ។ ក្នុងករណីដែលឆន្ទៈរបស់មតកជននៅតែមានបំណងកំណត់នូវចំណែកបន្ថែមឱ្យសន្តតិជននោះ គាត់នៅតែទទួលបានចំណែកមត៌កបន្ថែមនោះ ប៉ុន្តែចំណែកមត៌កបន្ថែមនោះក៏អាចប្រឈមនឹងត្រូវបានកាត់បន្ថយមកវិញផងដែរ ក្នុងករណីដែលចំណែកមត៌កដែលកំណត់ជាហេតុដែលនាំឱ្យបំពាននូវភាគបម្រុងរបស់សន្តតិជនដទៃទៀត។ ម្យ៉ាងក្នុងករណីដែលក្នុងមតកសាសន៍ មតកជនបានកំណត់ចំណែកមត៌កសម្រាប់សន្តតិជនម្នាក់ ឬច្រើននាក់ ក្នុងចំណោមសហសន្តតិជនទាំងអស់នោះ មត៌កនោះត្រូវបានបែងចែកទៅតាមការកំណត់របស់មតកជន ឲ្យទៅសន្តតិជនដែលបានកំណត់នូវចំណែកមត៌កជាមុន មុននឹងឈានដល់ការបែងចែកចំណែកឱ្យទៅសន្តតិជដទៃដែលពុំបានកំណត់ចំណែកមត៌កក្នុងមតកសាសន៍នោះ ទៅតាមភាគចំណែកមត៌កដែលនៅសល់ បន្ទាប់ពីបានបែងចែកតាមការកំណត់ចំណែកនោះរួចរាល់។

### ១.២.២ ការកំណត់នូវវិធីបែងចែកដោយមតកសាសន៍ ជាអាទិ៍

ក្រៅពីការការកំណត់ចំណែកមត៌ក មតកជនក៏អាចកំណត់នូវវិធីក្នុងការបែងចែកមត៌កដោយខ្លួនឯងតាមរយៈមតកសាសន៍ ឬ អាចប្រគល់អណ្ណត្តិឱ្យតតិយជនណាម្នាក់ក្នុងការកំណត់នូវវិធីបែងចែកមត៌ក និងក៏

[4] មាត្រា ១១៨២ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

អាចហាមឃាត់ក្នុងការបែងចែកមត៌ករបស់ខ្លួនតាមរយៈមតកសាសន៍ផងដែរ ដែលជាគោលការណ៍ក្នុងក្រមរដ្ឋប្បវេណីការហាមឃាត់បែងចែកមត៌កនេះកំណត់មិនឱ្យលើសពី ៥ឆ្នាំ បន្ទាប់ពីសន្តតិកម្មបានចាប់ផ្តើម។[5] មាត្រានេះគ្រាន់តែបង្ហាញក្នុងករណីដែលមតតជនបានកំណត់នូវវិធីបែងចែកមត៌ក ក្នុងមតកសាសន៍ ឬមតកជនក៏អាចកំណត់ក្នុងមតកសាសន៍ឲ្យតតិយជនណាម្នាក់កំណត់នូវវិធីបែងចែក និងរយៈពេលមួយដែលហាមឃាត់ចំពោះការបែងចែកមត៌ក។

ក្នុងអត្ថន័យនៃ ការកំណត់ចំណែកមត៌ក និងការកំណត់នូវវិធីបែងចែកមត៌ក សុទ្ធតែមានសញ្ញាណដែលអាចកំណត់បានថា ការកំណត់ទាំងពីរជាវិធីសាស្ត្រសម្រាប់ការបែងចែកនូវទ្រព្យរបស់មតកជន ព្រោះអានុភាពនៃការកំណត់ចំណែកមត៌ក និងការកំណត់នូវវិធីបែងចែកមត៌ក ជាមូលហេតុដែលនាំឲ្យសន្តតិជនទទួលនូវសន្តតិកម្មដោយអនុវត្តន៍តាមការកំណត់ទាំងពីរនោះ។ ឧទាហរណ៍ មតកជន “ក” បន្ទាប់ពីទទួលមរណភាពបានបន្សល់នូវទ្រព្យសម្បត្តិ ជាប្រាក់បញ្ញើនៅធនាគា ១០០០០$ ផ្ទះមួយកន្លែង និងរថយន្តមួយគ្រឿង។ បន្ទាប់ពីអានុភាពនៃមរណភាពរបស់ “ក” ទ្រព្យសម្បត្តិទាំងនោះនឹងស្ថិតនៅភាពជាអវិភាគនៅឡើយបើពុំទាន់មានការបែងចែក ប៉ុន្តែ “ក” បានបន្សល់នូវលិខិតមតកសាសន៍ក្នុងគោលបំណងបែងចែកនូវទ្រព្យរបស់ខ្លួនផ្អែកលើមតកសាសន៍នោះ បើ “ក” បានកំណត់ចំណែក ឬកំណត់វិធីបែងចែក នោះអ្នកប្រតិបត្តិមតកសាសន៍និងប្រើវាជាវិធីសាស្ត្រសម្រាប់បែងចែកទៅតាមការកំណត់របស់ “ក”។

### ១.២.៣ ការធ្វើអនុប្បទានទ្រព្យសម្បត្តិ

ម្ចាស់បណ្តាំអាចធ្វើប្រទានកម្មនូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែក ឬ អាចធ្វើប្រទានកម្មដោយមតកសាសន៍[6](អច្ច័យទាន)បាន។ ដោយសារអានុភាពនៃមតកសាសន៍មតកជនអាចសម្តែងឆន្ទៈជាការធ្វើអនុប្បទាននូវទ្រព្យសម្បត្តិរបស់ខ្លួនឲ្យទៅសន្តតិជន ឬតតិយជនដែលមិនមែនជាសន្តតិជនបាន ក្នុងនោះ ការធ្វើអនុប្បទានទ្រព្យសម្បត្តិ ចំពោះជនដែលត្រូវបានសន្មតថា ជាសន្តតិជន ត្រូវបានសន្មតថាជាការកំណត់នូវវិធីបែងចែកមត៌ក ឬ កំណត់នូវចំណែកមត៌ក។ ការធ្វើអនុប្បទានទ្រព្យសម្បត្តិ ចំពោះតតិយជន ហៅថាអច្ច័យទាន។ ប្រទានកម្មដោយមូលហេតុមរណភាព ក៏ប្រហាក់ប្រហែលនឹងអច្ច័យទានដែរ ក៏ប៉ុន្តែ អច្ច័យទាន គឺជាអនុប្បទាននៃទ្រព្យសម្បត្តិដោយការបង្ហាញឆន្ទៈរបស់មតកជនតែម្ខាង រីឯប្រទានកម្មដោយមូលហេតុមរណភាព គឺជាអនុប្បទានទ្រព្យសម្បត្តិតាមកិច្ចសន្យារវាងទាយក និង បដិគ្គាហក ។ សកម្មភាពពីរនេះមានចំណុចរួម មួយ គឺការកើតមាន

[5] មាត្រា១១៨៣ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[6] មាត្រា ១១៨៤ ក្រមរដ្ឋប្បវេណីដដែល

ឡើងនូវអានុភាពនៃការផ្ទេរទ្រព្យសម្បត្តិដោយមរណភាពរបស់ទាយ ហេតុនេះហើយចំពោះ អានុភាពនៃប្រទានកម្មដោយមូលហេតុមរណភាពត្រូវអនុវត្តតាមបញ្ញត្តិស្តីពីអច្ច័យទាន។[7]

មតកសាសន៍ អច្ច័យទាន និងប្រទានកម្មដោយមូលហេតុមរណភាព ត្រូវបង្កើតអានុភាពដោយមរណភាពរបស់មតកជនដូចគ្នា តែចំណុចដែលខុសគ្នានោះគឺ មតកសាសន៍ជាសកម្មភាពឯកតោភាគីដែលអ្នកទទួលទ្រព្យជាសន្តតិជនដែលសន្តតិជននោះសម្តែងឆន្ទៈទទួល ឬបោះបង់នៅពេលក្រោយ ដោយឡែក អច្ច័យទានក៏ជាសកម្មភាពឯកតោភាគីដែរ ប៉ុន្តែអ្នកទទួលផលប្រយោជន៍អាចជាសន្តតិជន ឬតតិយជនមិនមែនជាសន្តតិជនក៏បាន ប៉ុន្តែការធ្វើអច្ច័យទានចំពោះសន្តតិជនត្រូវបានសន្មតថាជា ការកំណត់ចំណែកមត៌ក ឬ កំណត់នូវវិធីបែងចែកមត៌កដល់សន្តតិជននោះ[8] ហើយអាចសម្តែងឆន្ទៈយល់ព្រម ឬបោះបង់នៅពេលក្រោយ រីឯ ប្រទានកម្មមូលហេតុមរណភាពវិញ ជាកិច្ចសន្យា ដែលអ្នកទទួលអាចជាសន្តតិជន ឬពុំមែនជាសន្តតិជនក៏បាន ដែលបានព្រមព្រៀងក្នុងការទទួលទ្រព្យសម្បត្តិតែលក្ខខ័ណ្ឌគឺកិច្ចសន្យានោះមានអានុភាពក្រោយមរណភាពរបស់ទាយក។

### ១.២.៤ ការធ្វើអនុប្បទានទ្រព្យសម្បត្តិចំពោះសន្តតិជន

បើមតកជន បានធ្វើមតកសាសន៍ដែលមានអត្ថន័យជាការធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬ ច្រើន ឱ្យទៅសហសន្តតិជនតែម្នាក់ ឬច្រើននាក់ មតកសាសន៍នោះត្រូវបានសន្មតថាបានកំណត់នូវវិធីបែងចែកមត៌ក លើកលែងតែនៅក្នុងករណី ដែលមតកសាសន៍នោះមានអត្ថន័យជាអច្ច័យទានយ៉ាងច្បាស់លាស់ ដូចជាអច្ច័យទានដែល ភ្ជាប់ជាមួយនឹងបន្ទុក ជាអាទិ៍ ហើយបើតម្លៃនៃទ្រព្យសម្បត្តិដែលបានកំណត់នោះ មានចំនួនលើសពីចំណែកមត៌ករបស់សន្តតិជន នោះត្រូវសន្មតថាបានកំណត់ចំណែកមត៌កផងដែរ ។ ក្នុងករណីដែលមតកជនបានធ្វើមតកសាសន៍ ចំពោះទ្រព្យសម្បត្តិតែមួយភាគ នៅក្នុងចំណោមមត៌ក បើតម្លៃនៃទ្រព្យសម្បត្តិនោះ មានចំនួនតិចជាងចំណែកមត៌ក ដែលសន្តតិជននោះត្រូវទទួល លុះត្រាតែពុំមានការបង្ហាញឆន្ទៈផ្សេងទៀតនៅក្នុងមតកសាសន៍នោះ ត្រូវសន្មតថាបានកំណត់ត្រឹមតែវិធីបែងចែកមត៌កដែលត្រូវធ្លាក់ទៅលើសន្តតិជននោះតែប៉ុណ្ណោះ។[9] មាត្រានេះកំណត់អំពីស្ថានភាពដែលមតកជនធ្វើអនុប្បទានទ្រព្យសម្បត្តិចំពោះសន្តតិជន ខុសពីមាត្រា១១៨៤ ដែលអនុប្បទានក្នុងមាត្រានោះអាចធ្វើបានទាំងចំពោះសន្តតិជនផង និងតតិយជនដែលមិនមែនជាសន្តតិជនផង។ ប៉ុន្តែការធ្វើអនុប្បទាននោះ គឺជាសញ្ញាណដែលគេអាចកំណត់ថា តើក្នុងមតកសាសន៍នោះបានកំណត់ពីវិធីបែងចែក ឬការកំណត់ចំណែកមត៌ក។

---

[7] សៀវភៅស្តីពី សេចក្តីកំណត់មាត្រានីមួយៗ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៩ របស់ក្រសួងយុត្តិធម៌ (គន្លឺ៨-គន្លឺ៩) ពន្យល់ មាត្រា១១៨៤

[8] សៀវភៅស្តីពី សេចក្តីកំណត់មាត្រានីមួយៗ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៩ របស់ក្រសួងយុត្តិធម៌ (គន្លឺ៨-គន្លឺ៩) ពន្យល់ មាត្រា១១៨៤

[9] មាត្រា១១៨៥ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

### ១.២.៥ ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍

មតកជនអាចធ្វើការកំណត់អ្នកប្រតិបត្តិមតកសាសន៍ តាមមតកសាសន៍បាន។ មតកជនអាចចាត់តាំងសហសន្តតិជនណាម្នាក់ ឬច្រើននាក់ ធ្វើជាអ្នកប្រតិបត្តិមតកសាសន៍បាន ឬអាចប្រគល់អាណត្តិឱ្យទៅតតិយជនកំណត់អ្នកប្រតិបត្តិនោះ។[10] មាត្រានេះចែងថា មតកជនអាចធ្វើការចាត់តាំងអ្នកប្រតិបត្តិមតកសាសន៍ ជាអាទិ៍បាន ហើយមតកជនក៏អាចចាត់តាំងសហសន្តតិជនណាម្នាក់ធ្វើជាអ្នកប្រតិបត្តិមតកសាសន៍បានដែរ។ ជាពិសេស ក្នុងករណីដែលបាន ធ្វើមតកសាសន៍ដោយកំណត់ឱ្យសហសន្តតិជនណាម្នាក់ទទួលសន្តតិកម្មនូវមត៌កទាំងអស់ ហើយព្រមជាមួយគ្នានេះក៏ចាត់តាំងអ្នកនោះឱ្យធ្វើជាអ្នកប្រតិបត្តិមតកសាសន៍ផង ជាមួយដែលការងាយស្រួល។

### ១.២.៦ ចំណុចផ្សេងៗ

ក្រៅពីធ្វើមតកសាសន៍តាមចំណុចដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ម្ចាស់បណ្តាំក៏អាចធ្វើមតកសាសន៍ដោយផ្តល់ជាយោបល់ ដើម្បីឱ្យមានភាពសុខដុមរមនាដល់ក្រុម គ្រួសារ និង ចំណុចផ្សេងៗទៀត ជាអាទិ៍ បាន ។ ក្រៅពីការផ្ទេរទ្រព្យសម្បត្តិ ឬ ការទទួលស្គាល់កូន មកតជនអាចធ្វើមតកសាសន៍ដែលមានន័យពាក់ព័ន្ធនឹងទំនៀមទម្លាប់ក្នុងសង្គមបាន ហើយចែងអំពី ករណីយកិច្ចគោរពតាមមតកសាសន៍ បែបនេះផងដែរ។ មាត្រា ៥២៦នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា បានចែងថា បណ្តាំប្រភេទនេះត្រូវទុកជាច្បាប់សម្រាប់គ្រួសារ ក៏ប៉ុន្តែ ក្នុងក្រមថ្មីនេះ បានចែងត្រឹមតែឱ្យមានករណីយកិច្ចគោរព ប៉ុណ្ណោះ។[11] បន្ថែមពីនេះមតកជនអាចកំណត់ក្នុងមតកសាសន៍នូវការកាត់ផ្តាច់សន្តតិជនណាមួយពីការទទួលសន្តតិកម្ម ការណែនាំក្នុងការធ្វើពិធីបុណ្យសព ឬកំណត់ជនណាម្នាក់ត្រូវដឹកនាំពិធីបុណ្យនៃបុព្វជន ការលើកលែងការទទួលផលប្រយោជន៍ពិសេសត្រឡប់មកវិញ កំណត់អច្ច័យទាន វិធីកាត់បន្ថយអច្ច័យទាន ជាអាទិ៍ ក្នុងមតកសាសន៍។[12] ចំណុចផ្សេងៗក្នុងមតកសាសន៍នីមួយៗ អាចខុសៗគ្នាអាស្រ័យទៅតាមការបង្ហាញឆន្ទៈរបស់អ្នកធ្វើបណ្តាំនោះ។

## ១.៣ លក្ខណៈសម្បត្តិ នៃភាគីក្នុងមតកសាសន៍

ក្នុងរបបមតកសាសន៍ទោះបីវាជាសកម្មភាពឯកតោភាគី ក្នុងការបង្ហាញឆន្ទៈបែងចែកទ្រព្យរបស់មតកជនក្តី ប៉ុន្តែដើម្បីឲ្យច្បាប់ទទួលស្គាល់ភាពជាមតកជនយ៉ាងត្រឹមត្រូវគេត្រូវពិចារណាលើស្ថានភាពបុគ្គល និងលក្ខខណ្ឌមួយចំនួន លើសពីនេះទៅទៀត បុគ្គលដែលនឹងក្លាយជាម្ចាស់ទ្រព្យបន្ទាប់ពីមតកសាសន៍បង្កើតអានុភាពក៏ត្រូវតែមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមការកំណត់នៃច្បាប់ផងដែរ។

---

[10] មាត្រា១១៨៦ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[11] សៀវភៅស្តីពី សេចក្តីកំណត់មាត្រានីមួយៗ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៩ របស់ក្រសួងយុត្តិធម៌ (គន្លឹ៨-គន្លឹ៩) ពន្យល់ មាត្រា១១៨៧

[12] ឯកសារបទបង្ហាញស្តីពីសន្តតិកម្មII ដោយសាលាដំបូងរាជធានីភ្នំពេញ SHINODA Yoichiro Attorney at Law (Japan)

### ១.៣.១ បុគ្គលដែលមានលក្ខណៈជាមតកជន

ក្រមរដ្ឋប្បវេណី បានកំណត់អំពីសមត្ថភាពរបស់ម្ចាស់បណ្តាំ ក្នុងការធ្វើមតកសាសន៍ ដោយពិចារណាលើសមត្ថភាពអាចធ្វើមតកសាសន៍ និងសមត្ថភាពនាពេលធ្វើមតកសាសន៍។

#### ១.៣.១.១ សមត្ថភាពបុគ្គលដែលអាចធ្វើមតកសាសន៍

នីតិជន និងអនីតិជនដែលបានទទួលអត្តាធីនភាពរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬ អំណាចមេបា ត្រូវបានកំណត់ថាជាបុគ្គលដែលអាចធ្វើមតកសាសន៍បាន។[13] នីតិជនត្រង់ចំណុចនេះ សំដៅដល់ជនដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ រាប់បញ្ចូលទាំងជននៅក្រោមរបបអាណាព្យាបាលទូទៅ ឬ ជននៅក្រោមហិតូបត្ថម្ភ ដែលបានទទួលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ឬ ហិតូបត្ថម្ភ។ ដោយហេតុថាការធ្វើមតកសាសន៍ គឺជាសកម្មភាពឯកតោភាគី ហើយជននៅក្រោមអាណាព្យាបាលទូទៅឬ ជននៅក្រោមហិតូបត្ថម្ភ ជាជនត្រូវបានកម្រិតសមត្ថភាពដែលមិនទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ មានន័យថាគ្រប់សកម្មភាពដែលបានធ្វើឡើងដោយជននៅក្រោមអាណាព្យាបាលទូទៅ និងសកម្មភាពដែលបានធ្វើឡើងដោយជននៅក្រោមហិ-តូបត្ថម្ភដូចជា៖[14] ការទទួល ឬការប្រើប្រាស់ទុន ការខ្ចីទ្រព្យ ឬការធានា ការធ្វើសកម្មភាពដែលមានគោលបំណងទទួលបាន ឬធ្វើឱ្យបាត់បង់សិទ្ធិដែលទាក់ទងនឹងអចលនវត្ថុ ឬទ្រព្យសម្បត្តិដែលមានសារៈសំខាន់ផ្សេងទៀតការធ្វើសកម្មភាពបណ្តឹង ការធ្វើប្រទានកម្ម ឬធ្វើកិច្ចសន្យាស្រុះស្រួល ឬកិច្ចសន្យាមជ្ឈត្តកម្មការទទួលស្គាល់នូវសន្តតិកម្ម ឬការបោះបង់ចោលនូវសិទ្ធិសន្តតិកម្ម ឬការបែងចែកនូវមត៌ក ការប្រកែកមិនទទួលប្រទានកម្មឬអច្ច័យទាន ឬការយល់ព្រមទទួលនូវប្រទានកម្មឬអច្ច័យទានដែលភ្ជាប់នឹងបន្ទុក ការសាងសង់សំណង់ថ្មី ការសង់ឡើងវិញ ការសង់បន្ថែម ឬការជួសជុលធំ ការធ្វើភតិសន្យាដែលមានអំឡុងពេលលើសពី ៣ (បី)ឆ្នាំ ចំពោះដីធ្លី លើសពី២(ពីរ)ឆ្នាំ ចំពោះអាគារលើសពី៦(ប្រាំមួយ)ខែ ចំពោះចលនវត្ថុ សកម្មភាពដែលតុលាការបានប្រកាសជាពិសេសថាចាំបាច់ត្រូវមានការយល់ព្រមពីហិតូបត្ថម្ភកៈតាមពាក្យសុំរបស់ជនដែលបានរៀបរាប់នៅក្នុងមាត្រា ២៨ (ការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ) នៃក្រមរដ្ឋប្បវេណី ឬហិតូបត្ថម្ភកៈ ឬអ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ។សកម្មភាពទាំងនេះមានមូលហេតុត្រូវលុបចោលអាចត្រូវបានលុបចោលដោយហិតូបត្ថម្ភកៈ។ សកម្មភាពដែលអាចលុបចោលដោយហិតូបត្ថម្ភកៈ ឬអ្នកអាណាព្យាបាលទូទៅ ដូចដែលរៀបរាប់នេះមិនត្រូវបានអនុវត្តន៍ចំពោះមតកសាសន៍ទេ[15] ដោយផ្អែកលើទម្រង់នៃការបង្កើតមតកសាសន៍នៃជនក្រោមអាណាព្យាបាលទូទៅមតកសាសន៍នោះត្រូវបានទទួលស្គាល់អំពីសុពលភាព និងអាចរារាំងពីការលុបចោលពីអ្នកអាណា

[13] មាត្រា១១៦៨ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[14] មាត្រា៣០ ក្រមរដ្ឋប្បវេណីដដែល

[15] មាត្រា១១៦៨,ក២ ក្រមរដ្ឋប្បវេណីដដែល

ព្យាបាលទូទៅ។ សរុបមក អ្នកនៅក្រោមរបបអាណាព្យាបាលទូទៅ ឬ អ្នកនៅក្រោមហិតូបត្ថម្ភ ជាបុគ្គលដែលអាចធ្វើមតកសាសន៍បាន។

ចំណែកអនីតិជន ជាគោលការណ៍មិនអាចធ្វើមតកសាសន៍បានទេ លុះត្រាតែជននោះទទួលបានអត្តាធីនភាព។ ដូច្នេះ បើអនីតិជនធ្វើមតកសាសន៍ មតកសាសន៍នោះ ត្រូវទុកជាមោឃៈ។

#### ១.៣.១.២ សមត្ថភាពបុគ្គលនាពេលធ្វើមតកសាសន៍

ម្ចាស់បណ្តាំត្រូវមានសមត្ថភាពធ្វើមតកសាសន៍ នៅពេលធ្វើមតកសាសន៍នោះ ។[16] សមត្ថភាពត្រង់ចំណុចនេះសំដៅលើសមត្ថភាពខាងឆន្ទៈ ជាការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន។ ដូច្នេះ នៅពេលធ្វើមតកសាសន៍ ប្រសិនបើម្ចាស់ បណ្តាំខ្វះសមត្ថភាព មតកសាសន៍នោះត្រូវចាត់ទុកជាមោឃៈ។ ឧទាហរណ៍៖ ម្ចាស់បណ្តាំ បានធ្វើមតកសាសន៍ក្នុងស្ថានភាពដែលខ្លួនស្រវឹងស្រាជោគជាំ ឬ ញៀនថ្នាំ ឬស្ថិតក្នុងស្ថានភាពដែលមានវិបត្តិផ្នែកបញ្ញាស្មារតី ជាអាទិ៍។ ម៉្យាងទៀត បុគ្គលដែលអះអាងអំពីការខ្វះសមត្ថភាពរបស់ម្ចាស់បណ្តាំ ត្រូវបញ្ជាក់ភស្តុតាងអំពីហេតុនេះ។[17]

ក្នុងករណី មតកជន ជាជននៅក្រោមអាណាព្យាបាលទូទៅដែលត្រូវបានចាត់ទុកថាជាបុគ្គលអាចធ្វើមតកសាសន៍បាន។ ប៉ុន្តែ ដោយសារជននៅក្រោមអាណាព្យាបាលទូទៅ ត្រូវបានសន្មតថា ជាបុគ្គលពុំមានសមត្ថភាពខាងឆន្ទៈ ដូច្នេះ ទោះបីជាជននៅក្រោមអាណាព្យាបាលទូទៅមានស្មារតី ឬបានជាស្បះស្បើយពីជំងឺនាពេលធ្វើមតកសាសន៍ក៏ដោយ ក៏មិនអាចទទួលស្គាល់មតកសាសន៍នេះដែរ។ ហេតុនេះដើម្បីអាចបញ្ជាក់ពីសមត្ថភាពនាពេលធ្វើមតកសាសន៍របស់ជននៅក្រោមអាណាព្យាបាលទូទៅ ចាំបាច់ត្រូវអនុវត្តតាមទម្រង់នៃមតកសាសន៍ជននៅក្រោមអាណាព្យាបាលទូទៅ។[18]

### ១.៣.២ លក្ខណៈសម្បត្តិ នៃសន្តតិជន

បន្ថែមលើលក្ខណៈសម្បត្តិរបស់មតកជន សន្តតិជនដែលជាអ្នកទទួលស្នងមត៌កក៏ទាមទារឲ្យមាននូវលក្ខណៈសម្បត្តិមួយចំនួនដូចខាងក្រោម៖

#### ១.៣.២.១ សមត្ថជនដែលមានលក្ខណៈជាសន្តតិជន

បុគ្គលដែលមានតែជនដែលមានជីវិតរស់នៅ នាពេលចាប់ផ្តើមសន្តតិកម្ម ក្រៅពីបុគ្គលដែលច្បាប់បញ្ញត្តថាជា អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍ ការផ្តាច់មត៌កពីសន្តតិជន ដោយមតកសាសន៍ ទើបអាចទទួលសន្តតិកម្មបាន។[19] ក្នុងករណីមតកជន និងជនដែលត្រូវសន្មតថាជាសន្តតិជន បានទទួលមរណៈភាពព្រមគ្នា ឬ

[16] មាត្រា១១៦៩, ក១ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[17] មាត្រា១១៦៩, ក២ ក្រមរដ្ឋប្បវេណី

[18] មាត្រា១១៧៦ ក្រមរដ្ឋប្បវេណីដដែល

[19] មាត្រា១១៤៩ ក្រមរដ្ឋប្បវេណីដដែល

សន្មតថា បានទទួលមរណៈភាពជាមួយគ្នា នាំឱ្យជនដែលសន្មតថាជាសន្តតិជននោះ មិនបានបំពេញល័ក្ខខ័ណ្ឌមានជីវិតរស់នៅ នៅពេលចាប់ផ្តើមសន្តតិកម្មទេ ដូច្នេះ អានុភាពនឹងបង្កើតឲ្យមានសន្តតិកម្មជំនួស។[20] ទារកនៅក្នុងគភ៌ក៏រាប់ថាជាសន្តតិជនផងដែរ[21] នឹងអាចទទួលសន្តតិកម្មបន្ទាប់ពីការចាប់កំណើតហើយនៅរស់រានមានជីវិត មានសមត្ថភាពទទួលសិទ្ធិតាមបញ្ញត្តិរបស់ក្រមរដ្ឋប្បវេណី។

បន្ថែមលើភាពជាសមត្ថជនដែលមានលក្ខណៈសម្បត្តិជាសន្តតិជន ក្រមរដ្ឋប្បវេណីក៏ពុំបានហាមឃាត់ការឡើងស្នងមត៌ករបស់សន្តតិជនដែលជាជនប្រទេសនោះទេ។ ដូច្នេះលក្ខណៈសម្បត្តិរបស់សន្តតិជនក្នុងចំណុចនេះយើងនឹងធ្វើការលើកឡើងចំពោះជនដែលជាជនបរទេសដែរ។ ករណីដែលមតកសាសន៍បានកំណត់នូវចំណែកមត៌កសម្រាប់សន្តតិជនជាជនបរទេស ពួកគេនៅតែមានលទ្ធភាពទទួលបាននូវចំណែកមត៌កនោះចំពោះមត៌កដែលជាចលនវត្ថុ ប៉ុន្តែករណីដែលមត៌កជាចលនវត្ថុត្រូវបានហាមឃាត់ការផ្ទេរសិទ្ធិ និងធ្វើលទ្ធកម្មចំពោះអចលនវត្ថុនោះ។[22] ប្រសិនបើសន្តតិជនដែលជាជនបរទេសនោះទទួលបាននូវសញ្ជាតិខ្មែរ នោះពួកគេមានសមត្ថភាពទទួលសិទ្ធិដូចគ្នាទៅនឹងប្រជាពលរដ្ឋខ្មែរដែរ។

### ១.៣.២.៣ សមត្ថជនដែលត្រូវបានហាមឃាត់ក្នុងការក្លាយជាសន្តតិជន

ផ្អែកតាមក្រមរដ្ឋប្បវេណីនៅក្នុងរបបសន្តតិកម្ម សន្តតិជនត្រូវបានច្បាប់បញ្ញត្តថាជាជនដែលអ្នកដែលមានសិទ្ធិឡើងស្នងមត៌ក ប៉ុន្តែភាពជាសន្តតិជនក៏អាចត្រូវបានហាមឃាត់ដោយច្បាប់ និងការកាត់ផ្តាច់តាមឆន្ទៈរបស់មតកសាសន៍ដោយមូលហេតុដូចខាងក្រោម៖

#### ក. អភ័ព្វបុគ្គលនៃសន្តតិកម្ម

បុគ្គលមួយចំនួនដែលច្បាប់បានកំណត់ថាជាអភ័ព្វបុគ្គលពុំអាចក្លាយជាសន្តតិជនមានដូចជា៖ បុគ្គលដែលបានទទួលទោស ដោយមានចេតនាធ្វើឃាត ឬ ប៉ុនប៉ងធ្វើឃាត លើមតកជន ឬ លើជនដែលមានលំដាប់សន្តតិកម្មមុន ឬ លំដាប់ស្មើគ្នា ទោះដោយ ផ្ទាល់ក្តី ឬ ដោយប្រយោលក្តី។ បុគ្គលដែលដឹងអំពីការសម្លាប់មតកជន តែមិនបានរាយការណ៍ ឬ មិនបានប្តឹង។ ប៉ុន្តែចំណុចនេះ មិនត្រូវយកមកអនុវត្តទេ ចំពោះករណីដែលបុគ្គលនោះ មិន អាចវិនិច្ឆ័យអំពើល្អ ឬ អាក្រក់ បាន ឬ ករណីដែលអ្នកសម្លាប់ជាសហព័ទ្ធ ឬ ញាតិលោហិត ខ្សែផ្ទាល់របស់បុគ្គលនោះ។ បុគ្គលដែលបានរារាំងមតកជនក្នុងការធ្វើ លុបចោល ឬ កែប្រែមតកសាសន៍ស្តីពីសន្តតិកម្មដោយការឆបោក ឬ គម្រាមកំហែង។ បុគ្គលដែលបានឱ្យ មតកជនធ្វើ លុបចោល ឬ កែប្រែមតកសាសន៍ស្តីពីសន្តតិកម្ម ដោយការឆបោក ឬ គម្រាមកំហែង។ បុគ្គលដែលបានក្លែង កែបន្លំ បំផ្លាញចោល ឬ លាក់ទុកនូវលិខិត

---

[20] មាត្រា១១៥៨, ច១ ក្រមរដ្ឋប្បវេណីដែល

[21] មាត្រា១១៤៩, ច២ ក្រមរដ្ឋប្បវេណីដដែល

[22] មាត្រា៦, ក១ ច្បាប់ស្តីពី ការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអាគារសហកម្មសិទ្ធិរបស់ជនបរទេស ឆ្នាំ២០១០

មតកសាសន៍ស្តីពីសន្តតិកម្ម របស់មតកជន ។[23] ក្រោមមូលហេតុខាងលើនេះហើយទើបច្បាប់បញ្ញត្តឲ្យជនទាំងនោះជាអភ័ព្វបុគ្គល សញ្ញាណនៃច្បាប់ក្នុងមាត្រានេះបង្ហាញពីស្ថានភាពមួយដែលសន្តតិជនជាជនទុច្ចរិត ជាមូលហេតុដែលគេមិនអាចទទួលបាននូវចំណែកទ្រព្យសម្បត្តិបាន បើទោះជាមាន ឬគ្មានការលើកឡើងដោយមតកជនផ្ទាល់អំពីការកាត់ផ្តាច់ពីភាពជាសន្តតិជនក្តី ក៏ស្មារតីច្បាប់បានដើរតួជាអ្នកអនុវត្តសកម្មភាពនោះក្នុងគោលបំណងការការពារផលប្រយោជន៍យ៉ាងសមស្របឲ្យមតកជន។

**ខ. ការផ្តាច់មត៌កពីសន្តតិជន**

មតកជន កាលនៅរស់អាចដាក់ពាក្យសុំទៅតុលាការ ឱ្យផ្តាច់មត៌កពីជនដែលត្រូវ បានសន្មតថាជាសន្តតិជននោះ មិនឱ្យទទួលសន្តតិកម្មបាន បើជនដែលត្រូវបានសន្មតថាជា សន្តតិជនដែលមានភាគបម្រុងបានប្រព្រឹត្តនូវសកម្មភាពមួយចំនួនដូចជា៖ បើបានធ្វើបាបចំពោះមតកជន បើបានប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ បើអាចមកមើលថែទាំមតកជននៅពេលដែលមានជម្ងឺ ប៉ុន្តែមិនមកថែទាំ បើត្រូវបានទទួលសាលក្រម ឬ សាលដីកាផ្តន្ទាទោសឱ្យជាប់ពន្ធនាគារមួយជីវិត បើបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរគួរឱ្យកត់សំគាល់ ជាអាទិ៍ ។ មតកជនក៏អាចបង្ហាញឆន្ទៈអំពីការផ្តាច់មត៌កនេះ តាមមតកសាសន៍បានដែរ។ ជនដែលត្រូវបានសន្មតថាជាសន្តតិជនដែលបានទទួលការទាមទារផ្តាច់មត៌កនេះ អាចធ្វើវិវាទអំពីអត្ថិភាព ឬ នត្ថិភាព នៃមូលហេតុនៃការផ្តាច់មត៌កនេះនៅក្នុងការសម្រេចសេចក្តីក្នុងការទាមទារផ្តាច់មត៌កនោះបាន។[24] មាត្រាបញ្ញត្តអំពីស្ថានភាពមួយបែបទៀតដែលជាមូលហេតុដែលនាំឲ្យសន្តតិជនគ្មានសិទ្ធិជាសន្តតិជន ក្នុងមាត្រានេះផ្តល់សិទ្ធិឲ្យមតកជនដែលមានបំណងកាត់ផ្តាច់សន្តតិជនពីសន្តតិកម្ម ដោយយោងតាមមូលហេតុដែលបានលើកឡើងខាងលើ ហើយមានការត្រួតពិនិត្យនិងសម្រេចបញ្ជាក់ពីតុលាការជាលក្ខខ័ណ្ឌ។ ដោយឡែកក្នុងនោះក៏មានបញ្ញត្តពីលក្ខខណ្ឌវិវាទអត្ថិភាព ឬ នត្ថិភាព ចំពោះការបង្ហាញឆន្ទៈក្នុងការផ្តាច់មត៌ករបស់មតកជនផងដែរ មានន័យថា ទោះជាមានការបង្ហាញឆន្ទៈស្នើសុំទៅតុលាការអំពីការផ្តាច់មត៌កភ្ជាប់ជាមួយនឹងមូលហេតុរបស់មតកជនក្តី ក៏ពុំមានភាពដាច់ខាត ឬហាមឃាត់ជនដែលត្រូវបានស្នើសុំផ្តាច់ចេញមត៌កក្នុងការសម្តែងឆន្ទៈតវ៉ាក្នុងការទាមទារនោះដែរ ដូច្នេះតុលាការត្រូវពិចារណាបន្ថែមក្នុងសេចក្តីសម្រេចក្នុងការទាមទារប្រសិនជាមានការលើកឡើងពីវិវាទអត្ថិភាព ឬ នត្ថិភាពនៃការទាមទារនោះ។

**គ.ការផ្តាច់មត៌កពីសន្តតិជន ដោយមតកសាសន៍**

បើមតកជនបានធ្វើមតកសាសន៍ដូចបានកំណត់នៅក្នុងមាត្រា ១១៥១ (ការផ្តាច់ មត៌កពីសន្តតិជន) ខាងលើនេះ អ្នកប្រតិបត្តិមតកសាសន៍ ត្រូវដាក់ពាក្យសុំទៅតុលាការ ឱ្យផ្តាច់មត៌កពីសន្តតិជន ដោយគ្មានការ

[23] មាត្រា១១៥០ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[24] មាត្រា១១៥១ ក្រមរដ្ឋប្បវេណីដដែល

យឺតយ៉ាវ នៅក្រោយពេលដែលមតកសាសន៍នោះ បានបង្កើតអានុភាព។ ក្នុងករណីនេះ ការផ្តាច់មត៌កពីសន្តតិជននោះ មានអានុភាព ប្រតិសកម្ម ចាប់ពីពេលដែលមតកជនបានទទួលមរណភាព។[25]ការបង្ហាញឆន្ទៈនៃការផ្តាច់មតកសាសន៍ តាមមតកសាសន៍ មតកជនអាចសរសេរអំពីការផ្តាច់មត៌កពីសន្តតិជននោះ ក្នុងលិខិតមតកសាសន៍ភ្ជាប់ទៅនឹងមូលហេតុតែម្តងដើម្បីបង្កើតអានុភាព តាមរយៈការបើកមតកសាសន៍ទន្ទឹមនឹងមតកសាសន៍នោះបង្កើតអានុភាព។ មាត្រានេះបង្ហាញពីវិធីនៃការផ្តាច់មត៌កដោយមតកជនតាមរយៈមតកសាសន៍ ប្រសិនបើគេពិនិត្យឃើញថា នៅក្នុងមតកសាសន៍មានអត្ថន័យដែលបង្ហាញឆន្ទៈផ្តាច់មត៌កពីសន្តតិជន អ្នកប្រតិបត្តិមតកសាសន៍ត្រូវដាក់ពាក្យសុំទៅតុលាការ ក្នុងការផ្តាច់មត៌កពីសន្តតិជននៅក្រោយពេលដែលមតកសាសន៍បង្កើតអានុភាព ហើយទោះជាការសម្រេចសេចក្តីរបស់តុលាការប្រកាសនៅពេលក្រោយណាមួយក៏ដោយ ក៏អានុភាពនៃការផ្តាច់មត៌កនោះត្រូវរាប់ថាទន្ទឹមនឹងពេលដែលមតកសាសន៍បង្កើតអានុភាពដែរ។

[25] មាត្រា១១៥២ ក្រមរដ្ឋប្បវេណីដដែល

## ផ្នែកទី២៖ ប្រភេទនៃមតកសាសន៍

មតកជនមានសេរីភាពក្នុងការបង្កើតមតកសាសន៍តាមអ្វីដែលខ្លួនចង់ធ្វើ ប៉ុន្តែដើម្បីមានភាពងាយស្រួលក្នុងការបញ្ជាក់អំពីភាពត្រឹមត្រូវនៃមតកសាសន៍នោះក្រោយពេលមតកជនបានទទួលមរណភាព ថាតើជាឆន្ទៈពិតប្រាកដរបស់មតកជនឬយ៉ាងណា? ច្បាប់បានតម្រូវឱ្យការបង្កើតនោះ ចាំបាច់ត្រូវធ្វើតាមទម្រង់ដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី។

មតកសាសន៍ពុំអាចធ្វើបានឡើង បើពុំផ្អែកតាមទម្រង់ដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ហើយមតកសាសន៍ណាមួយដែលបានធ្វើឡើងមិនស្របនឹងទម្រង់ណាមួយត្រូវចាត់ទុកជាមោឃៈ។ ប៉ុន្តែមតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំត្រូវចាត់ទុកថាមានសុពលភាព លុះត្រាតែមតកសាសន៍នោះ មិនផ្ទុយនឹងមតកសាសន៍ផ្សេងទៀតដែលបានធ្វើដោយម្ចាស់បណ្តាំដូចគ្នានេះ ហើយប្រសិនបើមានករណី មតកសាសន៍គ្មានការចុះថ្ងៃខែឆ្នាំមានចំនួនច្រើន មានខ្លឹមសារផ្ទុយគ្នា អានុភាពនៃមតកសាសន៍នោះ ត្រូវកាត់បន្ថយគ្នាទៅវិញទៅមក។[26] ត្រង់ចំណុច ខ្លឹមសារដែលផ្ទុយគ្នានេះ មិនអាចយកមកអនុវត្តបានទេ គឺអនុវត្តសម្រាប់តែខ្លឹមសារដូចគ្នាប៉ុណ្ណោះ។ ចំណែកមត៌កដែលនៅសល់ត្រូវចែកតាមច្បាប់។ ប្រសិនបើមានមតកសាសន៍ដែលមានការចុះថ្ងៃខែឆ្នាំ និងមតកសាសន៍ដែលគ្មានចុះថ្ងៃខែឆ្នាំ មានខ្លឹមសារផ្ទុយគ្នា មតកសាសន៍ដែលមានការចុះថ្ងៃខែឆ្នាំមានអានុភាពជាង។ មួយទៀត បើករណីមានមតកសាសន៍មួយមានចុះថ្ងៃខែឆ្នាំ ហើយមួយទៀតមិនបានចុះថ្ងៃខែឆ្នាំធ្វើឡើងដោយម្ចាស់បណ្តាំដូចគ្នា មានខ្លឹមសារដូចគ្នា នោះមតកសាសន៍នោះមានអានុភាពដូចគ្នា។ ចំណែកមតកសាសន៍ដែលមានតែស្នាមម្រាមដៃរបស់មតកជន ដោយជំនួសដោយការចុះហត្ថលេខា មិនមានអានុភាពនោះទេ ព្រោះការសរសេរនាមត្រកូល និងនាមខ្លួន និងការផ្តិតម្រាមដៃ ជំនួសឱ្យការចុះហត្ថលេខា អាចអនុវត្តបានចំពោះតែសារការី និងសាក្សីប៉ុណ្ណោះ។[27]

### ២.១ ប្រភេទមតកសាសន៍ ទម្រង់ធម្មតា

ផ្អែកតាមក្រមរដ្ឋប្បវេណី មតកសាសន៍ អាចធ្វើឡើងដោយលិខិតឯកជន លិខិតយថាភូត និងលិខិតសម្ងាត់ ជាករណីទូទៅ។

#### ២.១.១ ទម្រង់មតកសាសន៍ដោយលិខិតយថាភូត

មតកសាសន៍ដោយលិខិតយថាភូត គឺជាមតកសាសន៍ដែលម្ចាស់បណ្តាំត្រូវធ្វើឡើងនៅចំពោះមុខសារការី តាមទម្រង់ដូចខាងក្រោម៖

- ត្រូវមានវត្តមានរបស់សាក្សីយ៉ាងតិច២ នាក់។

---

[26] មាត្រា ១១៧០ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[27] មាត្រា ១១៨០ ក្រមរដ្ឋប្បវេណីដដែល

- ម្ចាស់បណ្ដាំត្រូវប្រាប់ផ្ទាល់មាត់ នូវខ្លឹមសារនៃមតកសាសន៍ ចំពោះសារការី។
- សារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្ដាំនោះ ជាលាយល័ក្ខណ៍ អក្សរ ហើយត្រូវសូត្រឲ្យម្ចាស់បណ្ដាំ និងសាក្សីស្ដាប់។
- បន្ទាប់ពីម្ចាស់បណ្ដាំស្ដាប់ និងសាក្សីបានទទួលស្គាល់ថា ការកំណត់ជាលាយល័ក្ខណ៍អក្សរ នោះត្រឹមត្រូវហើយ ជននីមួយៗត្រូវធ្វើឲ្យមានភាពច្បាស់លាស់នៅលើឯកសារអំពីឈ្មោះ អាយុ និងលំនៅឋាន ហើយត្រូវចុះហត្ថលេខារៀងៗខ្លួន។ ប៉ុន្តែបើម្ចាស់បណ្ដាំ មិនអាចសរ សេរអក្សរ ឬមិនអាចចុះហត្ថលេខាបានទេ សារការីអាចជំនួសការសរសេរ និងហត្ថលេខា ដូចកំណត់ខាងលើនេះ ដោយសរសេរឈ្មោះ អាយុ និងលំនៅឋានរបស់ជននោះ ហើយត្រូវ សរសេរបន្ថែមនូវហេតុនោះផង។
- សារការីត្រូវសរសេរថ្ងៃខែឆ្នាំ ហើយត្រូវចុះហត្ថលេខា។[28]

### ២.១.២ ទម្រង់មតកសាសន៍ដោយលិខិតឯកជន

មតកសាសន៍ដោយលិខិតឯកជន តម្រូវឱ្យម្ចាស់បណ្ដាំត្រូវសរសេរអំពីខ្លឹមសារទាំងមូលនៃមតកសាសន៍ ហើយ ចុះថ្ងៃខែឆ្នាំ ព្រមទាំងចុះហត្ថលេខាដោយខ្លួនឯងដោយផ្ទាល់ដៃរបស់ម្ចាស់បណ្ដាំ ហេតុនេះ ក្នុងករណី មតកសាសន៍ត្រូវបានសរសេរដោយអ្នកដទៃ ឬដែលត្រូវបានសរសេរប្រើម៉ាស៊ីនដូចជា អង្គុលីលេខជាអាទិ៍ នឹងត្រូវទុកជាមោឃៈ។[29] មតកសាសន៍ ករណីមានការបន្ថែម ឬការលុប ឬការកែប្រែផ្សេងទៀត ម្ចាស់បណ្ដាំត្រូវសរសេរបន្ថែមនូវហេតុនេះ ព្រមទាំងចុះហត្ថលេខាផង។[30] ក្នុងករណីនេះ មតកសាសន៍ ពុំមានហត្ថលេខារបស់មតកជន ហើយមានតែស្នាមម្រាមដៃមិនអាចជំនួសហត្ថលេខាបានទេ ព្រោះថាករណីលើកលែងក្នុងមាត្រា ១១៨០នៃក្រមរដ្ឋប្បវេណី អាចអនុវត្តបានសម្រាប់តែ សារការី និងសាក្សីតែប៉ុណ្ណោះ។ មួយវិញទៀត ប្រសិនបើករណីមានសាក្សី ឬប្រថាប់ត្រាមេធាវី ដែលជាចំណុចមិនតម្រូវក្នុងមតកសាសន៍ទម្រង់នេះ មតកសាសន៍នោះនៅតែមានសុពលភាព ព្រោះថាចំណុចបន្ថែមខាងលើនេះមិនបានប៉ះពាល់ទៅដល់លក្ខខណ្ឌទម្រង់នោះទេ។

### ២.១.៣ ទម្រង់មតកសាសន៍ដោយលិខិតសម្ងាត់

មតកសាសន៍ដោយលិខិតសម្ងាត់ ជាមតកសាសន៍មួយប្រភេទ ដែលមានគោលបំណងរក្សានូវខ្លឹមសារសម្ងាត់ទាំងស្រុង ការពារការលុបចោល ឬការបន្លំដោយតតិយជន។ មតកសាសន៍ទម្រង់នេះអនុញ្ញាតឱ្យម្ចាស់បណ្ដាំអាច សរសេរដោយផ្ទាល់ដៃ ឬប្រើម៉ាស៊ីនដូចជា កុំព្យូទ័រ ឬអង្គុលីលេខ ជាដើម ឬអាចឱ្យគេសរសេរជំនួស។ មតកសាសន៍ដោយលិខិតសម្ងាត់ ត្រូវធ្វើឡើង ដោយយោងតាមទម្រង់ដូចខាងក្រោមនេះ៖

[28] មាត្រា១១៧៣ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[29] មាត្រា ១១៧៤, ក១ ក្រមរដ្ឋប្បវេណីដដែល

[30] មាត្រា ១១៧៤, ក២ ក្រមរដ្ឋប្បវេណីដដែល

- ម្ចាស់បណ្ដាំត្រូវចុះហត្ថលេខាលើលិខិតនោះ។
- ម្ចាស់បណ្ដាំត្រូវដាក់លិខិតនោះក្នុងស្រោមបិទជិត ហើយត្រូវចុះហត្ថលេខា ឬ សរសេរសញ្ញាសំគាល់ ឬ មធ្យោបាយផ្សេងទៀតដែលអាចវិនិច្ឆ័យបានអំពីការ បានបើក ឬ មិន បានបើកស្រោមលិខិតនោះ នៅមាត់ស្រោមលិខិតនោះ។
- ម្ចាស់បណ្ដាំត្រូវដាក់លិខិតដែលបានបិទជិតនោះ នៅចំពោះមុខសារការីម្នាក់ និង សាក្សី ២ នាក់ និង ធ្វើសេចក្ដីថ្លែងការណ៍ថា លិខិតនេះជាលិខិតមតកសាសន៍របស់ខ្លួន ហើយបើមានជនក្រៅពីសាមីខ្លួនបានសរសេរ ត្រូវធ្វើសេចក្ដីថ្លែងការណ៍អំពីឈ្មោះ និង លំនៅឋានរបស់ជនដែលបានសរសេរនោះ ។
- សារការី ត្រូវចុះថ្ងៃខែឆ្នាំដែលសាមីខ្លួន បានដាក់លិខិតនោះ និង សរសេរសេចក្ដីថ្លែងការណ៍របស់ម្ចាស់បណ្ដាំ នៅលើលិខិតដែលបិទជិតនោះ ហើយត្រូវចុះហត្ថលេខាលើលិខិតនោះ ជាមួយគ្នានឹងសាក្សី និង ម្ចាស់បណ្ដាំ ។[31]

### ២.២ ប្រភេទមតកសាសន៍ ទម្រង់ពិសេស

ក្រៅពីទម្រង់ទាំងបីនេះ ក្នុងករណីពិសេសក្រមរដ្ឋប្បវេណី ក៏ទទួលស្គាល់មតកសាសន៍ដែលធ្វើដោយជនជួបគ្រោះថ្នាក់ជាបន្ទាន់ដល់អាយុជីវិត និងជនដែលជាប់ឃុំឃាំងជាអាទិ៍ ហើយមានបំណងធ្វើមតកសាសន៍ និងមិនអាចអាចធ្វើមតកសាសន៍តាមទម្រង់ទូទៅបាន។ ក្រៅពីនេះ ក៏ឃើញមាន បញ្ញត្តិមាត្រា១១៧៦ ១១៧៩ និង១១៨១ នៃក្រមរដ្ឋប្បវេណីជាទម្រង់បំពេញបន្ថែម។

#### ២.២.១ មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ

ប្រសិនបើម្ចាស់បណ្ដាំដែលជននៅក្រោមអាណាព្យាបាលទូទៅ ដែលបានជាសះស្បើយមួយរយៈឡើងវិញ នូវសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យនូវលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ហើយមានបំណងចង់ធ្វើមតកសាសន៍ដោយលិខិតយថាភូត លិខិតឯកជន ឬលិខិតសម្ងាត់ ច្បាប់បានទទួលស្គាល់នូវការធ្វើមតកសាសន៍នៅពេលនោះ។ ប៉ុន្តែច្បាប់ក៏បានតម្រូវឱ្យមានវត្តមានគ្រូពេទ្យ យ៉ាងតិច ២ នាក់ នៅពេលធ្វើមតកសាសន៍ ដើម្បីធ្វើការបញ្ជាក់មើលថា ម្ចាស់បណ្ដាំពិតជាបានសះស្បើយមួយរយៈ ឡើងវិញនូវសមត្ថភាពធ្វើមតកសាសន៍។[32] កាតព្វកិច្ចរបស់គ្រូពេទ្យ ដែលមានវត្តមាននៅពេលធ្វើមតកសាសន៍ នេះគឺដើម្បីបញ្ជាក់ ឱ្យបានច្បាស់លាស់អំពីការអនុវត្តតាមនីតិវិធី នៅក្នុងមតកសាសន៍នោះ។ ម្យ៉ាងទៀត ចំពោះករណីដែលចាំបាច់មាន វត្តមានរបស់សាក្សី ដូចជាការធ្វើមតកសាសន៍ដោយលិខិតយថាភូត ជាអាទិ៍ ត្រូវមានវត្តមានសាក្សីផ្សេងក្រៅពីគ្រូពេទ្យ ផងដែរ ប្រសិនបើជនដែលនៅក្រោមអាណាព្យាបាលទូទៅ ធ្វើមតកសាសន៍ដោយលិខិតឯកជន

[31] មាត្រា១១៧៥ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[32] មាត្រា១១៧៦ ក្រមរដ្ឋប្បវេណីដដែល

ឬ ធ្វើមតកសាសន៍ ដោយលិខិតសម្ងាត់ នៅក្នុងករណីនីមួយៗនេះ ចាំបាច់ត្រូវមានវត្តមានរបស់គ្រូពេទ្យនៅពេលជននោះសរសេរមតកសាសន៍ដោយផ្ទាល់ ឬ នៅពេលជននោះបង្ហាញខ្លឹមសារនៃមតកសាសន៍ទៅឱ្យសារការី។ ម្យ៉ាងទៀត ក្នុងករណីដែលជននៅក្រោមអាណាព្យាបាលទូទៅ ធ្វើមតកសាសន៍អ្នកអាណាព្យាបាល ជាអាទិ៍ គឺត្រូវមានកម្រិត ។

### ២.២.២ មតកសាសន៍នៃជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត

មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិតអាចធ្វើបានតាមទម្រង់ដូចតទៅ៖ [33]

- ត្រូវមានសាក្សីយ៉ាងតិច ៣ នាក់
- ម្ចាស់បណ្តាំធ្វើ ការប្រកាសដោយផ្ទាល់មាត់អំពីខ្លឹមសារនៃមតកសាសន៍ ចំពោះជនម្នាក់ក្នុងចំណោមសាក្សីនោះ
- ជនដែលទទួលការប្រកាសដោយផ្ទាល់មាត់នោះ ត្រូវសរសេរជាលាយល័ក្ខណ៍អក្សរ ហើយអានឱ្យសាក្សីស្តាប់ ឬឱ្យមើល
- ហើយនៅក្រោយពេលដែលសាក្សីនីមួយៗ ទទួលស្គាល់ការសរសេរនោះ ត្រឹមត្រូវ សាក្សីនីមួយៗនោះត្រូវចុះហត្ថលេខាលើលិខិតនោះ
- មតកសាសន៍នេះ ត្រូវដាក់ពាក្យសុំបញ្ជាក់នៅតុលាការក្នុងអំឡុងពេល ១ ខែ គិតចាប់ពីថ្ងៃធ្វើមតកសាសន៍នោះ។

ប្រសិនបើពុំមានជំនឿទុកចិត្តថាមតកសាសន៍នោះ ចេញពីឆន្ទៈរបស់ម្ចាស់បណ្តាំ តុលាការមិនអាចធ្វើការបញ្ជាក់មតកសសាន៍នោះបានឡើយ។

### ២.២.៣ មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង ជាអាទិ៍

មតកសាសន៍របស់ជនដែលត្រូវជាប់ឃុំឃាំង ជាអាទិ៍ ជាស្ថានភាពមួយដែលជននោះមិនអាចធ្វើមតកសាសន៍ដោយលិខិតយថាភូត លិខិតឯកជន ឬលិខិតសម្ងាត់បានដោយសារស្ថានភាពពិសេស។ ឧទាហរណ៍៖ បុគ្គលដែលត្រូវជាប់ឃុំឃាំងនៅទីកន្លែងណាមួយដាច់ដោយឡែក ដោយសាលក្រម ឬសាលដីកា ឬដោយសារការចាត់ចែងផ្នែករដ្ឋបាល បុគ្គលដែលជាប់លើយន្តហោះ ឬនាវា។ មតកសាសន៍របស់ជនដែលត្រូវជាប់ឃុំឃាំង ជាអាទិ៍ ត្រូវធ្វើតាមទម្រង់ដូចខាងក្រោម៖ [34]

---

[33] មាត្រា១១៧៧ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[34] មាត្រា១១៧៨ ក្រមរដ្ឋប្បវេណីដដែល

- ត្រូវឱ្យមានវត្តមានរបស់នគរ បាល ឬ មន្ត្រីនៃមន្ទីរឃុំឃាំងម្នាក់ និង សាក្សីយ៉ាងតិច ២ នាក់ ហើយចំពោះបុគ្គលដែលនៅក្នុងនាវា ឬ យន្តហោះ ត្រូវមានវត្តមានមេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះ ម្នាក់ និង សាក្សីយ៉ាងតិច ២ នាក់ ។
- ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍ ដោយផ្ទាល់មាត់ ចំពោះនគរបាល មន្ត្រីមន្ទីរឃុំឃាំង មេបញ្ជាការ បរិ-បាលនាវា ឬយន្តហោះ ឬបុគ្គលិកនាវា ឬយន្តហោះបាន
- អនុវត្តដូចមាត្រា ១១៧៣ ចំណុច ខ ដល់ ង នៃក្រមរដ្ឋប្បវេណីដែលពាក្យសាការីនៅក្នុងមាត្រា១១៧៣ សម្រាប់ករណីនេះ គឺ នគរបាល មន្ត្រីមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា ឬយន្តហោះ ឬបុគ្គលិកនាវា ឬយន្តហោះ។

ត្រង់ចំណុចត្រូវអនុវត្តដូចគ្នានឹង មាត្រា ១១៧៣នៃក្រមរដ្ឋប្បវេណីនេះ នគរបាល ជាអាទិ៍ មិនមែនជាសារការីទេ គឺគ្រាន់តែអនុវត្តតាមវិធីធ្វើមតកសាសន៍ ដែលចែងក្នុងមាត្រា ១១៧៣នៃក្រមរដ្ឋប្បវេណីប៉ុណ្ណោះ ដូច្នេះ មតកសាសន៍ដែលធ្វើឡើងនេះ មិនមែនជាមតកសាសន៍ដោយលិខិតយថាភូតទេ។

មតកសាសន៍តាមទម្រង់នេះ នឹងពុំមានអានុភាពឡើយ ប្រសិនបើ ម្ចាស់បណ្តាំ នៅមានជីវិតរស់នៅ ក្នុងអំឡុងពេល ៦ ខែ គិតចាប់ពីពេលដែល ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍ តាមទម្រង់នៃលិខិតឯកជន ឬលិខិតសម្ងាត់ ឬលិខិតយថាភូត ក្រោយពេលដែលត្រូវបានដោះលែងពីមន្ទីរឃុំឃាំង ឬចុះពី នាវា ឬយន្តហោះ។

### ២.២.៤ មតកសាសន៍នៃជនដែលមិនអាចនិយាយបាន

ក្នុងករណីបុគ្គលដែលមិនអាចនិយាយបាន មានបំណងធ្វើមតកសាសន៍ដោយលិខិតយថាភូត ឬ មតកសាសន៍ដោយលិខិតសម្ងាត់ ឬជាជនដែលកំពុងជួបប្រទះគ្រោះថ្នាក់ជាបន្ទាន់ដល់អាយុជីវិត ត្រូវអនុលោមតាមមតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន បន្ថែមពីលើទម្រង់ដែលមានកំណត់នៅក្នុងទម្រង់មតកសាសន៍ដោយលិខិតយថាភូត មតកសាសន៍ដោយលិខិតសម្ងាត់ មតកសាសន៍ជនជួបគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត នៃក្រមរដ្ឋប្បវេណី។

ចំពោះករណីម្ចាស់បណ្តាំ ជាជនដែលមិនអាចនិយាយបាន មានបំណងធ្វើមតកសាសន៍ដោយលិខិតយថាភូត និងមតកសាសន៍នៃជនមិនអាចនិយាយបាន នៃក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តដូចទម្រង់ខាងក្រោម៖

- ត្រូវមានសាក្សី យ៉ាងតិច ២ នាក់
- សេចក្តីថ្លែងការណ៍អំពីខ្លឹមសារនៃមតកសាសន៍ធ្វើឡើង ដោយការបកប្រែ ឬ ការសរសេរដោយផ្ទាល់ដៃរបស់ម្ចាស់បណ្តាំ (ជំនួសឱ្យ ការប្រាប់អំពីខ្លឹមសារនៃមតកសាសន៍ ទៅសារការី) នៅចំពោះមុខសាក្សី និង សារការី

- សារការី ត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្ដាំ ជាលាយលក្ខណ៍អក្សរ ហើយត្រូវសូត្រឱ្យម្ចាស់បណ្ដាំ និងសាក្សីស្ដាប់ ដើម្បីធ្វើការទទួលស្គាល់នូវកំណត់ជាលាយលក្ខណ៍អក្សរនោះ
- ម្ចាស់បណ្ដាំ និង សាក្សី ត្រូវធ្វើឱ្យមានភាពច្បាស់លាស់នៅលើឯកសារអំពីឈ្មោះ អាយុ លំនៅឋាន និងហត្ថលេខារបស់ម្ចាស់បណ្ដាំ និងសាក្សី
- សារការី ត្រូវសរសេរ ថ្ងៃខែឆ្នាំ និងហត្ថលេខា។

### ២.២.៥ មតកសាសន៍នៃជនជាតិខ្មែរដែលរស់នៅបរទេស

បើជនជាតិខ្មែររស់នៅបរទេស មានបំណងធ្វើមតកសាសន៍តាមលិខិតយថាភូត ឬលិខិតសម្ងាត់ នៅកន្លែងដែលមានចំពោះមុខកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅ ហើយកុងស៊ុលត្រូវអនុវត្តតួនាទីជាសារការី។[35] បទប្បញ្ញត្តិស្ដីពីមតកសាសន៍ ក៏ពុំបានហាមឃាត់ឆន្ទៈនៃការបែងចែក ទ្រព្យសម្បត្តិសម្រាប់ប្រជាជនខ្មែរដែលរស់នៅបរទេសនោះទេ ប៉ុន្តែដើម្បីឲ្យលិខិតមតកសាសន៍ត្រូវទទួលបានសុពលភាពនៃទម្រង់នោះទាមទារឲ្យមតកជនធ្វើឡើងតាមលក្ខខណ្ឌដែលច្បាប់តម្រូវ។ ម៉្យាងទោះជាបញ្ញត្តិនេះពុំបានលើកឡើងយ៉ាងណាក៏ដោយ ក៏ប្រជាជនខ្មែររស់នៅបរទេសអាចធ្វើមតកសាសន៍ជាលិខិតឯកជនតាមមាត្រា១១៧៤ បានដែរ។ បន្ថែមពីនេះ គេក៏អាចធ្វើមតកសាសន៍តាមវិធីដែលប្រទេសនោះមាន នៅចំពោះមុខសារការីនៃប្រទេសនោះបានដែរ ហើយតាមផ្លូវច្បាប់ឯកជនអន្តរជាតិ វិធីមួយណាក៏នឹងត្រូវមានសុពលភាពដូចគ្នា។ ក៏ប៉ុន្តែ ដើម្បីធ្វើមតកសាសន៍ នៅចំពោះមុខសារការីបរទេសនោះ ជាទូទៅច្រើនតែត្រូវធ្វើដោយប្រើភាសាប្រទេសនោះ ហេតុនេះហើយ ដើម្បីអនុញ្ញាតឱ្យ ជនដែលមិនចេះភាសាបរទេស អាចមានលទ្ធភាពធ្វើមតកសាសន៍ដោយលិខិតយថាភូត ឬដោយលិខិតសម្ងាត់ជាភាសា ខ្មែរបាន កុងស៊ុលកម្ពុជាត្រូវបានប្រគល់សិទ្ធិឱ្យអនុវត្តមុខនាទីរបស់សារការី។[36]

បញ្ញត្តិដែលចែងអំពីមតកសាសន៍នៃជនជាតិខ្មែរនៅក្រៅប្រទេសនៅក្នុងក្រមរដ្ឋប្បវេណីចែងអំពី វិធីក្នុងការក្នុងការធ្វើមតកសាសន៍ដោយផ្អែកលើទម្រង់នៃមតកសាសន៍ដែលមានស្រាប់ប៉ុណ្ណោះ ដោយពុំបញ្ជាក់ពីលក្ខខណ្ឌពិសេសៗ ដែលសន្តតិកម្មនោះអាចជាទ្រព្យ ចលនទ្រព្យ ឬអចលទ្រព្យ ហើយស្ថិតនៅក្នុងប្រទេសកម្ពុ-ជា ឬនៅក្រៅប្រទេសនោះទេ។ សញ្ញាណនេះបានបង្ហាញឲ្យឃើញថាក្រមរដ្ឋប្បវេណីមានមូលដ្ឋានកំណត់ពីទ្រឹស្ដីដល់ការអនុវត្តមតកសាសន៍ប្រភេទនេះ និងពីរបៀបនៃការធ្វើមតកសាសន៍នោះដែលអាចទទួលស្គាល់និងអនុវត្តន៍ក្នុងដែនដីនៃព្រះរាជណាចក្រកម្ពុជាបាន ម៉្យាងវិញទៀតចំពោះលក្ខខណ្ឌពិសេសៗដែលអាចមានដូចដែលយើងបានលើកឡើងខាងលើ ក៏អាចអនុវត្តន៍បានដោយយោងតាមការកំណត់ផ្សេងៗក្នុងច្បាប់ដោយឡែក។

[35] មាត្រា១១៨១ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[36] សៀវភៅស្ដីពី សេចក្ដីកំណត់មាត្រានីមួយៗ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៩ របស់ក្រសួងយុត្តិធម៌ (គន្លឹ៨-គន្លឹ៩) ពន្យល់ មាត្រា១១៨១

# ជំពូកទី២

# អានុភាព និងការលុបចោលមតកសាសន៍

# ជំពូកទី២
# អានុភាព និងការលុបចោលមតកសាសន៍

ក្រោយពីបានលើកឡើងអំពីសញ្ញាណទូទៅនៃមតកសាសន៍រួចមក យើងនឹងធ្វើការបកស្រាយបន្ទាប់អំពីលក្ខខណ្ឌដែលបង្កើតអានុភាព និងប្រភេទនៃការលុបចោលនៃមតកសាសន៍នៅចំណុចខាងក្រោមបន្តបន្ទាប់។

## ផ្នែកទី១៖ អានុភាពនៃមតកសាសន៍

ក្នុងផ្នែកនេះយើងមិនត្រឹមតែបង្ហាញអំពីរយៈពេលដែលបង្កើតអានុភាព កម្រិតនៃអានុភាពប៉ុណ្ណោះទេ ផ្ទុយទៅវិញ យើងនឹងបង្ហាញអំពីអានុភាពផ្សេងៗដែលកើតមានឡើងតាមរយៈការកំណត់ក្នុងមតកសាសន៍ ហើយលក្ខខណ្ឌទាំងនោះ ជាមូលហេតុនាំការអនុវត្តរបស់មតកសាសន៍មានភាពខុសប្លែកពីគ្នាពីមួយទីមួយ។

### ១.១ រយៈពេលនៃការបង្កើតអានុភាព

មតកសាសន៍ ត្រូវបង្កើតអានុភាព ចាប់ពីពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព។[37] លើកលែងតែចំពោះ មតកសាសន៍ ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ បើល័ក្ខខ័ណ្ឌនោះត្រូវ បានបំពេញនៅក្រោយពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព មតកសាសន៍នោះ ត្រូវមានអានុភាព ចាប់ពីពេលដែលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ។[38] មានន័យថា អានុភាពនៃមតកសាសន៍ត្រូវបានបង្កើតឡើងក្រោយមរណភាពរបស់មតកជន ព្រោះមតកសាសន៍គឺជាឆន្ទៈរបស់ម្ចាស់បណ្តាំ ក្នុងការសម្រេចនូវកម្មសិទ្ធិទ្រព្យសម្បត្តិ ជាអាទិ៍ ក្រោយពេលដែលសាមីខ្លួនទទួលមរណភាព។ សិទ្ធិនៃការទទួលគ្រប់គ្រងទ្រព្យសម្បត្តិនោះត្រូវមានអានុភាពទៅតាមប្រព័ន្ធស្វ័យប្រវត្តិតាមរយៈមតកសាសន៍ ការទទួលដោយស្វ័យប្រវត្តិនៃទ្រព្យសម្បត្តិតាមរយៈមតកសាសន៍នេះពុំមានន័យថារាប់បញ្ចូលនឹងនីតិវិធីនៃការបើកមតកសាសន៍ រួមទាំងការធ្វើលទ្ធកម្មផ្សេងៗចំពោះទ្រព្យដែលជាចលនវត្ថុនោះទេ។ ដូច្នេះបន្ទាប់ពីការបង្កើតអានុភាពសន្តតិជនត្រូវចាត់ចែងការកាន់កាប់ ឬលទ្ធកម្មដោយឡែកតាមការកំណត់នៃច្បាប់ដោយឡែក។ មានន័យថា បើមតកជនមានបំណងចែកទ្រព្យសម្បត្តិឱ្យទៅសន្តតិជន បន្ទាប់ពីបង្កើតអានុភាពសន្តតិជននោះនឹងក្លាយជាម្ចាស់កម្មសិទ្ធិដោយស្វ័យប្រវត្តិ ប៉ុន្តែមិនរាប់បញ្ចូលការចាត់ចែងផ្ទេរសិទ្ធិដទៃនោះទេ។ ហើយក្នុងករណីដែលមតកសាសន៍បានភ្ជាប់ជាមួយល័ក្ខខ័ណ្ឌបង្អង់នោះអានុភាពនៃមតកសាសន៍ត្រូវចាត់ទុកថាកើតមានពេលដែលល័ក្ខខ័ណ្ឌបង្អង់នោះត្រូវបានបំពេញ។ ឧទាហរណ៍ បើមតកជនមានបំណងកំណត់ការហាមឃាត់បែងចែកមតកក្នុងរយៈពេលកំណត់ណាមួយ (ពុំអាចលើសពីរយៈពេល ៥ឆ្នាំ)[39]

---

[37] មាត្រា១១៩៤, ច១ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[38] មាត្រា១១៩៤, ច២ ក្រមរដ្ឋប្បវេណីដដែល

[39] មាត្រា១១៨៣ ក្រមរដ្ឋប្បវេណីដដែល

ល័ក្ខខ័ណ្ឌបង្អង់ដែលបានបញ្ញត្តនោះជាការកំណត់ពេល បើមតកជនកំណត់នូវល័ក្ខខ័ណ្ឌដោយឡែកដូចជា លុះត្រាសន្តតិជនបានរៀបអាពាហ៍ពិពាហ៍ និងបង្កើតបានបុត្រាមួយ ក្នុងចំណងអាពាហ៍ពិពាហ៍នោះ នេះជាសញ្ញាណនៃការដាក់ល័ក្ខខណ្ឌ។ យោងតាមឧទាហរណ៍ខាងលើ ល័ក្ខខ័ណ្ឌបង្អង់ក្នុងបណ្តាមតកសាសន៍ពុំដូចគ្នានោះទេ អាស្រ័យទៅលើស្ថានភាពនៃល័ក្ខខ័ណ្ឌទាំងនោះ។

### ១.២ អានុភាពនៃការកំណត់ចំណែកមត៌ក ជាអាទិ៍

បើមតកជនបានកំណត់ចំណែកមត៌ក ឬ វិធីបែងចែកមត៌ក ដោយធ្វើអនុប្បទាន ទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬ ច្រើន ឱ្យចំពោះសន្តតិជនតែម្នាក់ ឬ ច្រើននាក់ ឬ ដោយមតកសាសន៍ ទ្រព្យសម្បត្តិជាក់លាក់នោះ ត្រូវធ្លាក់ទៅសន្តតិជនដែលនឹងត្រូវទទួល ទ្រព្យសម្បត្តិនោះ ដោយស្វ័យប្រវត្តិ ព្រមគ្នានឹងពេលមតកសាសន៍នោះបង្កើតអានុភាព។ នៅក្នុងករណីដែលមតកសាសន៍ ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ បើល័ក្ខខ័ណ្ឌ នោះត្រូវបានបំពេញនៅក្រោយពេលដែលម្ចាស់បណ្តាំ បានទទួលមរណភាព ទ្រព្យសម្បត្តិដែលសន្តតិជននោះនឹងត្រូវទទួលបានត្រូវធ្លាក់លើសន្តតិជននោះដោយប្រតិសកម្ម គិតចាប់ពីពេលដែលមតកជន ទទួលមរណភាព។[40] នៅក្នុងអានុភាពនៃការកំណត់ចំណែកពុំបានចែងអ្វីដែលស្មុគស្មាញនោះទេ ជាអត្ថន័យគឺ ទ្រព្យសម្បត្តិដែលមតកជនមានបំណងកំណត់ថាឲ្យទៅសន្តតិជនណា ឬកំណត់វិធីបែងចែករបៀបណាត្រូវគោរពទៅតាមឆន្ទៈនៃការកំណត់ដែលមានក្នុងបណ្តាំនោះ។ មួយវិញទៀត ករណីដែលមតកកសាសន៍ដែលភ្ជាប់ជាមួយល័ក្ខខ័ណ្ឌបង្អង់បានបង្កើតអានុភាពពេលដែលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ អានុភាពនៃការទទួលដោយស្វ័យប្រវត្តិនៃទ្រព្យសម្បត្តិរបស់សន្តតិជនដែលភ្ជាប់ល័ក្ខខ័ណ្ឌនោះ ត្រូវបានសន្មតថាបានទទួលចាប់តាំងពីពេលដែលមតកជននោះទទួលមរណភាពមកម្ល៉េះ នេះជាគោលការណ៍ប្រតិសកម្មនៃការទទួលទ្រព្យសម្បត្តិ។

### ១.៣ អានុភាពនៃមរណភាពនៃជនដែលត្រូវបានសន្មតថាជាសន្តតិជន

នៅក្នុងករណីដែលមតកជនបានកំណត់ចំណែកមត៌ករបស់សន្តតិជន ឬវិធីនៃការបែងចែកមត៌ក ដោយមតកសាសន៍ បើជនដែលត្រូវបានសន្មតថាជាសន្តតិជន បានទទួលមរណភាព នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬ បានបាត់បង់សិទ្ធិសន្តតិកម្ម[41] ដោយសន្តតិជនជាអភ័ពបុគ្គល ឬ ដោយ ការកាត់កាល់សន្តតិជន ការកំណត់នោះត្រូវបានចាត់ទុកថា បានធ្វើចំពោះអ្នកទទួលសន្តតិកម្មជំនួសរបស់ជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ។ ក្នុងករណីដែលគ្មានអ្នកទទួលសន្តតិកម្មជំនួស ឬ សន្តតិជនបានបោះបង់សន្តតិកម្ម ចំណែកមត៌កដែលបានកំណត់ចំពោះ ជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ ពុំត្រូវបង្កើតអានុភាពឡើយ។ ប៉ុន្តែប្រសិនបើនៅក្នុងមតកសាសន៍មានការបង្ហាញឆន្ទៈពិសេសដោយមតកជន ត្រូវអនុលោមតាមឆន្ទៈពិសេស

[40] មាត្រា១១៩៥ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[41] មាត្រា១១៩៦ ក្រមរដ្ឋប្បវេណីដដែល

នោះ។ មាត្រានេះចែងពីស្ថានភាពមួយដែលសន្តតិជនដែលនឹងទទួលនូវមត៌កត្រូវទទួលមរណភាព ឬបាត់បង់សិទ្ធិទទួលសន្តតិកម្ម មុនពេលសន្តតិកម្មមានអានុភាព អានុភាពនោះឲ្យកើតមាននូវសន្តតិកម្មជំនួស។ អានុភាពនៃសន្តតិកម្មជំនួសកើតមានចំពោះជនដែលជាបច្ឆាញាតិរបស់មតកជនប៉ុណ្ណោះ។[42] ប៉ុន្តែការកើតមាននូវសន្តតិកម្មជំនួសនេះអាចនឹងត្រូវបានកែប្រែ ប្រសិនបើមតកជនមានឆន្ទៈផ្សេងកំណត់ក្នុងមតកសាសន៍។ ឧទាហរណ៍ មតកជន "ក" បានធ្វើមតកសាសន៍ ដោយមាន "ច" សន្តតិជនដែលត្រូវបានកាត់ផ្តាច់ពីមត៌ក ហើយក្នុងចំណងអាពាហ៍ពិពាហ៍ "ច" មានកូនប្រុសម្នាក់ ប៉ុន្តែនៅក្នុងមតកសាសន៍មតកជន "ក" បានធ្វើអច្ច័យទានឲ្យទៅនាង "ស" នូវចំណែកមត៌ករបស់ "ច" នោះនៅពេលមតកសាសន៍បង្កើតអានុភាពគេនឹងគោរពទៅតាមឆន្ទៈរបស់ "ក"។[43]

## ១.៤ អានុភាពនៃការកម្រិតមតកសាសន៍ ចំពោះអ្នកអាណាព្យាបាលទូទៅ

ក្រមរដ្ឋប្បវេណីបានបញ្ញត្តិឱ្យជននៅក្រោមអាណាព្យាបាលទូទៅ អាចធ្វើមតកសាសន៍បានដោយគោរពតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា១១៧៦ នៃក្រមនេះ។ ក៏ប៉ុន្តែ ដោយយល់ឃើញថាសមត្ថភាពរបស់ជនទាំងនេះមានកម្រិតតិចតួច ហើយមានការបារម្ភថា អ្នកអាណាព្យាបាលរបស់គាត់អាចបោកប្រាស់គាត់ឱ្យធ្វើមតកសាសន៍សម្រាប់ជាផលប្រយោជន៍ដល់អ្នកអាណាព្យាបាលនោះ ឬ អ្នកនៅជុំវិញរបស់ខ្លួននោះ ទើបច្បាប់បានចែងបន្ថែមអំពីការកម្រិតនូវមតកសាសន៍ ចំពោះអ្នកអាណាព្យាបាល។ ត្រូវចាត់ទុកជាមោឃៈចំពោះមតកសាសន៍ទាំងឡាយណាដែលធ្វើឡើងដោយជនដែលនៅក្រោមអាណាព្យាបាលទូទៅ ហើយមានអត្ថន័យជាការផ្តល់ប្រយោជន៍ដល់អ្នកអាណាព្យាបាល ឬអ្នកដែលនៅជុំវិញខ្លួនរបស់អ្នកអាណាព្យាបាលនោះ នៅមុនពេលបញ្ចប់ការគណនានូវចំណូលចំណាយក្នុងកិច្ចការអាណាព្យាបាល។[44] ប៉ុន្តែមតកសាសន៍នោះនឹងមានសុពលភាព ផ្ទុយការចែងខាងលើប្រសិនបើ ករណីអ្នកអាណាព្យាបាលនោះជាញាតិលោហិតផ្ទាល់ សហព័ទ្ធ ឬ បងប្អូនបង្កើត របស់អ្នកនៅក្រោមអាណាព្យាបាលនោះ ដែលជាទូទៅយើងអាចដឹងថាមតកជនតែងមានបំណងឱ្យមត៌កខ្លួនទៅជនទាំងនោះ។[45]

## ១.៥ អានុភាពនៃសិទ្ធិទទួលទ្រព្យសម្បត្តិ ក្នុងករណីដែលអច្ច័យទានមោឃៈ ជាអាទិ៍

ជាគោលការណ៍ ប្រសិនបើអច្ច័យទានត្រូវមោឃៈ ជាអាទិ៍ នាំឱ្យអច្ច័យលាភីមិនអាចទទួលបានទ្រព្យដែលអច្ច័យលាភីត្រូវទទួលនោះទេ ហើយទ្រព្យនោះនឹងធ្លាក់ទៅសន្តតិជនរបស់មតកជនវិញ បើមតកជនមិន

---

[42] មាត្រា១១៥៧ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[43] មាត្រា១១៩៦, ច៣ ក្រមរដ្ឋប្បវេណីដដែល

[44] មាត្រា១១៩៧, ច១ ក្រមរដ្ឋប្បវេណីដដែល

[45] មាត្រា១១៩៧, ច២ ក្រមរដ្ឋប្បវេណីដដែល

បានបង្ហាញឆន្ទៈផ្សេង។ អច្ច័យទានអាចមោឃៈ ក្នុងករណីដូចជា អច្ច័យលាភីជាអភ័ព្វបុគ្គល ឬអច្ច័យលាភីបានទទួលមរណភាព ឬការបោះបង់អច្ច័យទានដោយអច្ច័យលាភី។[46] មាត្រានេះចែងអំពីសិទ្ធិក្នុងការទទួលទ្រព្យសម្បត្តិករណីដែលអច្ច័យទានមោឃភាព ផ្អែកតាមក្រមរដ្ឋប្បវេណីអច្ច័យទានពុំមានអានុភាពចំពោះសន្តតិកម្មជំនួសទេ ប្រសិនបើអច្ច័យលាភីជាតតិយជនពុំមែនជាសន្តតិជន[47] ដូច្នេះករណីដែលអច្ច័យទានចំពោះតតិយជនប្រភេទនេះត្រូវមោឃភាព ទ្រព្យដែលកំណត់ថាជាអច្ច័យទាននោះនឹងត្រូវធ្លាក់លើសន្តតិជនរបស់មតកជនវិញ។ លើកលែងតែ ក្នុងមតកសាសន៍ មតកជនមានបំណងចាត់ចែងភាគនៃអច្ច័យទាននោះដោយវិធីផ្សេង នោះគេត្រូវអនុវត្តន៍ទៅតាមឆន្ទៈនោះ។ ឧទាហរណ៍ ក្នុងមតកសាសន៍មួយ "ខ" បានធ្វើអច្ច័យទានឲ្យ "គ" ប្រពន្ធដើមរបស់ខ្លួនដែលគ្មានចុះសំបុត្រអាពាហ៍ពិពាហ៍ នូវទឹកប្រាក់ ៥០០០ដុល្លា។ ក្នុងមតកសាសន៍បានបន្ថែមទៀតថា ប្រសិនបើ "គ" ពុំមានជីវិតដល់ពេលមតកសាសន៍បង្កើតអានុភាពទេ ទ្រព្យដែលជាភាគនៃអច្ច័យទានរបស់ "គ" លោក "ខ" សូមធ្វើការបរិច្ចាគទៅមន្ទីរពេទ្យកុមារ។ ក្រោមឧទាហរណ៍នេះ ទោះជាបញ្ញត្តិនៃមាត្រា១១៩៨ ចែងថា អច្ច័យទានមោឃភាពនឹងធ្លាក់ទៅលើសន្តតិជនក៏ដោយ ក៏មាត្រាដដែលនេះផ្តល់សេរីភាពដល់ឆន្ទៈរបស់មតកជនដែលមានបំណងផ្សេងផងដែរ។

## ផ្នែកទី២៖ ការលុបចោលមតកសាសន៍

ការលុបចោលមតកសាសន៍ គឺជាផ្នែកមួយនៃសិទ្ធិរបស់មតកជនដែលពុំអាចបោះបង់ចោលបានទេក្នុងការសម្តែងឆន្ទៈនៃការលុបចោលនោះ ក៏ព្រោះតែឆន្ទៈនៃការបង្កើតមតកសាសន៍គឺជាឆន្ទៈសេរីដែលបង្ហាញដោយមតកជនផ្ទាល់។ ការលុបចោលមតកសាសន៍ក្នុងបញ្ញត្តិនៃក្រមរដ្ឋប្បវេណីសំដៅលើការលុបចោលចំពោះផ្នែកនៃមតកសាសន៍ តាមរយៈរូបភាពផ្សេងៗដែលយើងនឹងលើកយកមកបកស្រាយក្នុងចំណុចបន្តបន្ទាប់។

### ២.១ ការលុបចោលដោយទម្រង់នៃមតកសាសន៍

ការលុបចោលដោយទម្រង់នៃមតកសាសន៍ ផ្តល់ឲ្យមតកជនអាចធ្វើការលុបចោលមតកសាសន៍មួយភាគ ឬ ទាំងមូលបាន តាមទម្រង់នៃមតកសាសន៍នោះ។ បើមតកសាសន៍ដែលបានធ្វើក្រោយនេះ មានភាពផ្ទុយនឹងមតកសាសន៍ដែល បានធ្វើមុន ត្រូវចាត់ទុកថា មតកសាសន៍ដែលបានធ្វើក្រោយនោះ បានលុបចោលមតកសាសន៍ដែលបានធ្វើមុន ចំពោះផ្នែកដែលផ្ទុយគ្នានោះ។[48] ការលុបចោលទម្រង់នៃមតកសាសន៍ពុំបានកំណត់អំពីប្រភេទនៃមតកសាសន៍នោះទេ ដូច្នេះ ទោះបីជាមតកសាសន៍នោះ ជាមតកសាសន៍ ដោយលិខិតយថាភូតក៏ដោយ ក៏គេអាចលុបចោលនូវមតកសាសន៍នោះមួយភាគ ឬ ទាំងមូល តាមទម្រង់មតកសាសន៍ ដោយលិខិត

---

[46] មាត្រា១១៩៨ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[47] មាត្រា១២០០, ច។ ក្រមរដ្ឋប្បវេណីដដែល

[48] មាត្រា១១៨៩ ក្រមរដ្ឋប្បវេណីដដែល

ឯកជនក៏បាន ឬ តាមមតកសាសន៍របស់ជនដែលកំពុងតែជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ក៏បានដែរ ដើម្បីលុបចោលនូវមតកសាសន៍មុនដោយទម្រង់នៃមតកសាសន៍ គឺត្រូវធ្វើមតកសាសន៍ថ្មីមួយទៀតតាមវិធីធ្វើមតកសាសន៍ ដោយប្រើវិធីពីរ ទី១ ការលុបចោលដោយបានបញ្ជាក់អំពីការលុបចោលនៃលិខិតចាស់ក្នុងបណ្តាំមត៌កថ្មី (ឧទាហរណ៍ៈ បណ្តាំមត៌កនេះមានអនុភាពធ្វើឲ្យលុបចោលនូវបណ្តាំមត៌កដែលបានចុះថ្ងៃ កខ ចំណុច គក ឬទាំងស្រុងនូវមត៌កនោះ)។ និងទី២ ការលុបចោលដោយមត៌កថ្មីមានខ្លឹមសារផ្ទុយពីបណ្តាំមត៌កចាស់ (ឧទាហរណ៍ៈ បណ្តាំមត៌កចុះថ្ងៃ ខក របស់ "ង" បានប្រគល់ ដី១៥ម៉ែត្រ ឲ្យទៅកូនទី១ "ង១" និង ផ្ទះតម្លៃ ២០០០០ដុល្លា ឲ្យទៅ "ង២" បន្ទាប់មកលោក "ង" បានធ្វើនូវលិខិតបណ្តាំថ្មី ដោយប្រគល់នូវ ដី១៥ម៉ែត្រ ឲ្យទៅ "ង២" និងផ្ទះតម្ល ២០០០០ដុល្លា ឲ្យទៅ "ង១"វិញ ទម្រង់នៃលិខិតទាំងពីរមានលក្ខណៈផ្ទុយពីគ្នា ដោយក្នុងករណីនេះ ត្រូវចាត់ទុកថា មតកជនបាន លុបចោលនូវមតកសាសន៍មុន ដោយមតកសាសន៍ក្រោយ ហើយមានតែមតកសាសន៍ក្រោយទេ ដែលមានអានុភាព។

## ២.២ ការលុបចោលមតកសាសន៍ដោយការចាត់ចែងនាពេលនៅរស់

ការលុបចោលមតកសាសន៍ ដោយការចាត់ចែងនាពេលនៅរស់ បើម្ចាស់បណ្តាំបានធ្វើអនុប្បទាន ឬ បានធ្វើសកម្មភាពផ្សេងទៀត ចំពោះវត្ថុដែល ជាកម្មវត្ថុនៃមតកសាសន៍ នាពេលនៅរស់ ត្រូវចាត់ទុកថា ម្ចាស់បណ្តាំបានលុបចោល មតកសាសន៍ ចំពោះផ្នែកដែលផ្ទុយនឹងអនុប្បទាន ឬ សកម្មភាពផ្សេងនោះ។[49] សកម្មភាពនៃការចាត់ចែងនាពេលនៅរស់ អាចសន្និដ្ឋានថាជាការអវត្តមានវត្ថុដែលជាកម្មវត្ថុនៃសន្តតិកម្មដែលត្រូវបានចាត់ចែងដោយសន្តតិជនក្រោមរូបភាពនានា ដូចជា ការធ្វើអនុប្បទាន ការលក់ ការខូចខាតគុណតម្លៃនៃសន្តតិកម្ម ជាអាទិ៍។

មាត្រានេះបញ្ញត្ត ក្នុងករណីដែលម្ចាស់បណ្តាំខ្លួនឯងបានធ្វើអនុប្បទាន ជាអាទិ៍ នូវវត្ថុដែលជាកម្មវត្ថុនៃមតកសាសន៍ ត្រូវចាត់ទុកថា មតកជនបានលុបចោលមតកសាសន៍ ចំពោះផ្នែកដែលមានភាពផ្ទុយគ្នានោះ។ ឧទាហរណ៍ តាមមតកសាសន៍ ចលនវត្ថុជាក់លាក់មួយត្រូវឱ្យជាអច្ច័យទានដល់ A ក៏ប៉ុន្តែ ប្រសិនបើម្ចាស់បណ្តាំ បានធ្វើប្រទានកម្មនូវចលនវត្ថុនោះឱ្យ B នៅពេលដែលខ្លួននៅរស់ ត្រូវចាត់ទុកថា សាមីខ្លួនបានលុបចោលនូវផ្នែកនេះ នៃមតកសាសន៍ ។ ផ្ទុយទៅវិញ ប្រសិនបើវត្ថុដែលជាកម្មវត្ថុនោះ ត្រូវបានតតិយជនធ្វើឱ្យបែកបាក់ នោះមិនអាចចាត់ទុក ថា បានលុបចោលនូវផ្នែកនេះ នៃមតកសាសន៍បានទេ ។ ដូច្នេះ ទោះបីជា មិនបានធ្វើលទ្ធកម្មវត្ថុដែលជាកម្មវត្ថុនោះ ក៏ដោយ ក៏អាចទទួលនូវសិទ្ធិទាមទារនូវសំណងនៃការខូចខាត ចំពោះតតិយជននោះ ជំនួសវត្ថុដែលជាកម្មវត្ថុនោះដែរ (មាត្រា ១២០៩) ក្នុងមាត្រានេះ បានចែងថា "ចំពោះផ្នែកដែលផ្ទុយ"

[49] មាត្រា១១៩០ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

បានសេចក្តីថា ចំពោះករណីដែលក្នុងចំណោម សន្តតិជនបីនាក់ គឺ A, B និង C មតកជនបានធ្វើមតកសាសន៍ឱ្យ ទទួលសន្តតិកម្មដីធ្លីជាក់លាក់មួយ ឱ្យ B ទទួល សន្តតិកម្មសិទ្ធិលើបំណុលដែលជាប្រាក់បញ្ញើនៅធនាគារ ហើយឱ្យ C ទទួលសន្តតិកម្មចលនវត្ថុជាក់លាក់មួយ ប្រសិនបើ ដីនោះ ត្រូវបានធ្វើអនុប្បទានដល់តតិយជននោះមានតែផ្នែកដែលពាក់ព័ន្ធនឹងដីនោះប៉ុណ្ណោះដែលត្រូវចាត់ទុកថា មតកជន បានលុបចោល ហើយខ្លឹមសារនៃមតកសាសន៍ចំពោះ B ឬ C នឹងមិនមានការប៉ះពាល់ឡើយ ។ ម៉្យាងទៀត មាត្រានេះ ជាបញ្ញត្តិចែងឡើងក្នុងន័យគោរពនូវឆន្ទៈរបស់ម្ចាស់បណ្តាំ ដូច្នេះ៖ ប្រសិនបើម្ចាស់បណ្តាំនោះបានលក់ដីធ្លីនោះ ដើម្បីឱ្យ A ធ្វើលទ្ធកម្មប្រាក់ជំនួសដីធ្លី ពេលនោះមិនត្រូវចាត់ទុកថា បានលុបចោលនូវមតកសាសន៍នោះទេ គឺគួរតែឱ្យ ធ្វើលទ្ធកម្មប្រាក់ដែលបានមកពីការលក់នោះ តាមអានុភាពនៃមតកសាសន៍។[50]

## ២.៣ ការលុបចោលដោយការបដិសេធលិខិតមតកសាសន៍ ជាអាទិ៍

ការលុបចោលដោយការបដិសេធលិខិតមតកសាសន៍ ជាអាទិ៍ បើម្ចាស់បណ្តាំបានបំផ្លាញច្បាប់ដើមនៃមតកសាសន៍ ដោយចេតនា ត្រូវចាត់ទុកថា បានលុបចោលមតកសាសន៍ ចំពោះផ្នែកដែលត្រូវបានបំផ្លាញនោះ។[51] បញ្ញត្តិនោះត្រូវយក មកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់បណ្តាំបានបំផ្លាញវត្ថុ ដែលជាកម្មវត្ថុនៃមតកសាសន៍ ដោយចេតនា ។

មាត្រានេះបញ្ញត្តអំពីការចាត់ទុកថា ជាការលុបចោលនូវមតកសាសន៍ ប្រសិនបើមានការបំផ្លាញមតតសាសន៍ ឬ ការបំផ្លាញវត្ថុដែលជាកម្មវត្ថុនៃមតកសាសន៍ ដោយម្ចាស់បណ្តាំ។ លិខិតមតកសាសន៍គឺជាភស្តុតាងតែមួយគត់ដែលអាចបញ្ជាក់ថា មានមតកសាសន៍នោះ។ ដូច្នេះប្រសិនបើម្ចាស់បណ្តាំបានបំផ្លាញលិខិតនោះដោយចេតនា ត្រូវចាត់ទុកថា សាមីខ្លួនបានលុបចោលមតកសាសន៍ត្រង់ផ្នែកដែលខ្លួនបាន បំផ្លាញនោះ ។ ម៉្យាងទៀត ក្នុងករណីដែលម្ចាស់បណ្តាំបានបំផ្លាញកម្មវត្ថុ នៃសន្តតិកម្មដោយចេតនា គឺត្រូវចាត់ទុកថាសាមីខ្លួនបានលុបចោលនូវមតកសាសន៍របស់ខ្លួន ដូចការចាត់ចែងវត្ថុនោះពេលនៅរស់ដែរ។ ក្នុងករណីដែលលិខិត មតកសាសន៍ត្រូវបានបំផ្លាញដោយទង្វើរបស់តតិយជន ឬ ដោយប្រធានសក្តិ អានុភាពនៃការលុបចោលមិនកើតឡើងទ ក៏ប៉ុន្តែ ប្រសិនបើលិខិតមតកសាសន៍នោះមើលលែងដាច់ គ្មានវិធីអ្វីផ្សេងក្រៅពីចាត់ទុកថា ផ្នែកនៃមតកសាសន៍នោះគ្មានអានុភាព។[52]

សរុបជារួមការលុបចោលមតកសាសន៍ក្នុងទម្រង់ដូចដែលបានលើកឡើងខាងលើនេះ ជាមូលហេតុដែលនាំឲ្យការអនុវត្តចំពោះមតកសាសន៍នោះមានការប្រែប្រួល ទៅតាមផ្នែកដែលមានការកែប្រែនោះដែលនាំឲ្យ

[50] សៀវភៅស្តីពី សេចក្តីកំណត់មាត្រានីមួយៗ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៩ របស់ក្រសួងយុត្តិធម៌ (គន្លឹ៨-គន្លឹ៩) ពន្យល់ មាត្រា១១៩០

[51] មាត្រា១១៩១ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[52] សៀវភៅស្តីពី សេចក្តីកំណត់មាត្រានីមួយៗ ក្រមរដ្ឋប្បវេណីដដែល ពន្យល់ មាត្រា១១៩១

អានុភាពនៃមតកសាសន៍នោះត្រង់ចំណុចខ្លះមិនអាចអនុវត្តន៍បាន។ ជាក់ស្តែងដូចជាការលុបចោលដោយការចាត់ចែងនាពេលនៅរស់ជាដើម ជាមូលហេតុដែលនាំឲ្យទ្រព្យដែលជាសន្តតិកម្មក្នុងមតកសាសន៍នោះត្រូវប្រែប្រួលចំពោះការចាត់ចែង។ ការលុបចោលមតកសាសន៍ដូចរៀបរាប់ខាងលើ ពុំមានអានុភាពធ្វើឲ្យមតកសាសន៍ដែលមានភាពត្រឹមត្រូវក្នុងទម្រង់អស់អានុភាព ឬត្រូវមោឃភាពនោះទេ។

# ជំពូកទី៣

# អច្ច័យទាន និងការអនុវត្តមតកសាសន៍

# ជំពូកទី៣

# អច្ច័យទាន និងការអនុវត្តមតកសាសន៍

អានុភាពនៃមតកសាន៍ដែលត្រឹមត្រូវតាមទម្រង់ ពុំបានកំណត់ថាត្រូវតែជាសន្តតិជន ឬ ញាតិរបស់មតកជនក្នុងថ្នាក់ណាមួយ ទើបបុគ្គលនោះទទួលបាននូវសិទ្ធិទទួលមត៌កនោះទេ ផ្ទុយទៅវិញមតកសាសន៍គឺគោរពទៅតាមឆន្ទៈដែលបន្សល់ទុកនៃម្ចាស់បណ្តាំ ដូច្នេះបុគ្គលដែលទទួលមត៌កអាចជាសន្តតិជន ញាតិ និងក៏អាចជាតតិយជនដែលមាននិស្ស័យពិសេសរបស់មតកជនផ្សេងទៀតផងដែរ។ ហេតុនេះហើយទើបមានបញ្ញត្តិស្តីពីអច្ច័យទានដែលផ្តល់សិទ្ធិឲ្យមតកជនដែលមានបំណងផ្ទេរនូវទ្រព្យសម្បត្តិរបស់ខ្លួន នៅពេលមរណភាពឲ្យទៅតតិយជនអាចធ្វើទៅបាន ហើយបញ្ញត្តិអំពីអច្ច័យទានក៏បានលើកឡើងក្នុងបទប្បញ្ញត្តិស្តីពីសន្តតិកម្មតាមមតកសាសន៍នៅក្នុងក្រមរដ្ឋប្បវេណី ផងដែរ។

## ផ្នែកទី១៖ អច្ច័យទាន

យោងតាមអានុភាពនៃមតកសាសន៍ មតកជនក៏អាចកំណត់ពីការធ្វើប្រទានកម្មនូវទ្រព្យរបស់ខ្លួនឲ្យទៅសន្តតិជន ឬតតិយជនបាន ហើយការកំណត់អំពីការបែងចែកទ្រព្យឲ្យទៅតតិយជនបែបនេះច្បាប់បានកំណត់ថាមតកជនបានធ្វើអច្ច័យទាន ដូច្នេះចំណុចបន្ទាប់យើងនឹងបកស្រាយអំពីអ្វីទៅជាអច្ច័យទាន។

### ១.១ លក្ខណៈនៃអច្ច័យទាន

អច្ច័យទាន គឺជាសកម្មភាពឯកតោភាគីមួយប្រភេទដែលមតកជនមានបំណងធ្វើប្រទានកម្មទ្រព្យរបស់ខ្លួនឲ្យតតិយជន ដែលមិនមែនជាសន្តតិជន។ អ្នកទទួលផលអច្ច័យទាន ហៅថា **អច្ច័យលាភី**។ អច្ច័យលាភីអាចទទួលផល ចាប់តាំងពីខ្លួនបានទាមទារឲ្យអនុវត្តន៍អច្ច័យទានបាន លើកលែងតែមតកជនបង្ហាញឆន្ទៈផ្សេង។[53] អច្ច័យទានក៏ពុំមាននូវលក្ខណៈខុសគ្នាពីរសន្តតិកម្មតាមមតកសាសន៍ប៉ុន្មានដែរ ព្រោះវាស្ថិតក្នុងបញ្ញត្តិដែលគ្រប់គ្រងរបបគតិយុត្តនៃមតកសាសន៍ដូចគ្នា ប្លែកតែបុគ្គលដែលស្នងមត៌កប៉ុណ្ណោះ។ ដូច្នេះលក្ខខណ្ឌ និងទម្រង់ក្នុងការបង្កើតអច្ច័យទានគេអាចអនុវត្តន៍ដូចគ្នានឹងបញ្ញត្តិស្តីពីមតកសាសន៍បាន។

#### ១.១.១ និយមន័យ

អច្ច័យទាន ជាប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅឲ្យមនុស្សម្នាក់ ឬ ច្រើននាក់នូវទ្រព្យសម្បត្តិរបស់ខ្លួនតាមរយៈមតកសាសន៍។[54] ក្នុងបណ្តាំមត៌កប្រសិន បើមតកជនបានធ្វើមតកសាសន៍ដែលមានអត្ថន័យជាការធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬ ច្រើន ឲ្យទៅសហសន្តតិជនតែម្នាក់ ឬ ច្រើននាក់ មតកសាសន៍នោះ

[53] មាត្រា១២០៦ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[54] សន្ទានុក្រមផ្នែករដ្ឋប្បវេណី ដកស្រង់ពីសន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី, ល.រ១៧៧

ត្រូវបានសន្មតថាបានកំណត់វិធីបែងចែកមត៌ក[55] ប៉ុន្តែការធ្វើអនុប្បទានសម្រាប់តតិយជន គឺជាអច្ច័យទាន ព្រោះ អនុប្បទានិក អាចមិនមែនជាសន្តតិជនរបស់មតកជននោះទេ។

### ១.១.២ ប្រភេទអច្ច័យទាន

យោងតាមបញ្ញត្តិចែងពីអច្ច័យទាន និងឆន្ទៈក្នុងការធ្វើប្រទានកម្ម របស់មតកជនចំពោះអច្ច័យលាភី សញ្ញាណរបស់អច្ច័យទាន បានបែងចែកអច្ច័យទានជា៣ គឺៈ

**អច្ច័យទានសកល** គឺជាប្រភេទប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅឲ្យមនុស្សម្នាក់ ឬ ច្រើននាក់ នូវទ្រព្យសម្បត្តិទាំងអស់ ឬមួយផ្នែកដែលកំណត់តាមភាគ។[56] អច្ច័យទានសកល មានសិទ្ធិ និង ករណីយកិច្ច ដូចគ្នានឹងសន្តតិជន។[57] ឧទាហរណ៍: មតកសាសន៍មួយរបស់លោក A មានខ្លឹមសារបែងចែកនូវទ្រព្យសម្បត្តិជា ដីមានតម្លៃ ៦០០០០ដុល្លា, ផ្ទះមានតម្លៃ ៤៥០០០ដុល្លា និងរថយន្ត ២០០០០ដុល្លា ឲ្យទៅ សន្តតិជនរបស់ ២នាក់ និង ធ្វើប្រទានកម្មនូវទឹកប្រាក់១/៥ នៃទ្រព្យសម្បត្តិសរុបឲ្យក្មួយស្រីរបស់ខ្លួន។

**អច្ច័យទានមានកំណត់** គឺជាប្រទានកម្មដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ ទៅឲ្យមនុស្សម្នាក់ ឬច្រើននាក់ដោយមតកសាសន៍។[58] ឧទាហរណ៍: មតកសាសន៍មួយមានខ្លឹមសារបែងចែកនូវទ្រព្យសម្បត្តិជា ផ្ទះមានតម្លៃ ៥០០០០ដុល្លា សន្តតិជនរបស់ម្នាក់ និងរថយន្តតម្លៃ ១០០០០ដុល្លា ជាប្រទានកម្មឲ្យទៅប្អូនប្រុសតែម្នាក់របស់មតកជន។

**អច្ច័យទានភ្ជាប់បន្ទុក** គឺជាអច្ច័យទានដែលអច្ច័យលាភីត្រូវទទួលបន្ទុកនូវករណីយកិច្ចមួយចំនួនតាមផ្លូវច្បាប់។ ឧទាហរណ៍: មតកសាសន៍មួយ មានខ្លឹមសារជាប្រទានកម្មនូវដីមួយកន្លែងមានតម្លៃ ២០០០០ដុល្លា ឲ្យទៅអច្ច័យលាភី B នៅពេលដែល B បានរៀនចប់បរិញ្ញាបត្រ ដោយជោគជ័យ។

ម្យ៉ាងវិញទៀតចំណុចដែលបានលើកឡើងអំពី “ករណីយកិច្ចមួយចំនួនតាមផ្លូវច្បាប់” នោះ ជាក់ស្តែងគឺពុំមែនជាករណីយកិច្ចដែលច្បាប់បានកំណត់ជាក់លាក់ដើម្បីឲ្យអច្ច័យលាភីបំពេញនោះទេ ប៉ុន្តែវាជាលក្ខខណ្ឌដែលអច្ច័យលាភីត្រូវបំពេញស្របតាមឆន្ទៈរបស់មតកជន។ ដោយសារអានុភាពនៃមតកសាសន៍ត្រូវបង្កើតតាមរយៈមរណភាពរបស់ មតកជន ហើយមតកជនផ្ទាល់ពុំមានវត្តមាននៅត្រួតពិនិត្យថាអច្ច័យលាភីបានបំពេញករណីយកិច្ច ឬអត់នោះទេ នេះជាមូលហេតុដែល គេត្រូវទាមទារឲ្យច្បាប់ដើរតួនាទីជាអ្នកត្រួតពិនិត្យការអនុវត្តករណីយកិច្ចរបស់អច្ច័យលាភីដើម្បីបំពេញឆន្ទៈចុងក្រោយរបស់មតកជន។

---

[55] មាត្រា១១៨៤ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[56] មាត្រា១១៩៩, ក១ក្រមរដ្ឋប្បវេណីដដែល

[57] មាត្រា១២១២, ក១ ក្រមរដ្ឋប្បវេណីដដែល

[58] មាត្រា១១៩៩, ក២ ក្រមរដ្ឋប្បវេណីដដែល

**១.១.៣ រយៈពេលអច្ច័យទានបង្កើតអានុភាព**

តាមរយៈនិយមន័យអច្ច័យទាន អានុភាពនៃអច្ច័យទានក៏ដូចជាសន្តតិកម្មដែរ ព្រោះវានឹងបង្កើតអានុភាពពេលដែលម្ចាស់បណ្តាំទទួលមរណភាព លើកលែងតែក្នុងករណីដែលអច្ច័យទានមានភ្ជាប់នឹងបន្ទុក ឬ ល័ក្ខខ័ណ្ឌបង្អង់ណាមួយ តាមឆន្ទៈម្ចាស់បណ្តាំ លុះត្រាតែល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញទើបអច្ច័យទាននោះចាត់ទុកថាមានអានុភាព។ អច្ច័យទានពុំមានអានុភាពឡើយ បើសិទ្ធិដែលជាកម្មវត្ថុនៃអច្ច័យទាននោះ ពុំស្ថិតនៅក្នុងមត៌កនៅពេលដែលម្ចាស់បណ្តាំទទួលមរណភាព[59] មានន័យថាប្រសិនបើមតកជនបានធ្វើអច្ច័យទាន ប៉ុន្តែនៅពេលដែលមតកសាសន៍បង្កើតអានុភាពទ្រព្យដែលជាកម្មវត្ថុនៃអច្ច័យទាននោះ ពុំមែនជាទ្រព្យរបស់មតកជនទៀតទេនាំឲ្យអច្ច័យទានក៏ពុំអាចអនុវត្តន៍បានដែរ វាជាស្ថានភាពមួយដែលអវត្តមានកម្មវត្ថុនៃមត៌ក ដូច្នេះក៏ពុំមានអ្វីដើម្បីផ្ទេរឲ្យអច្ច័យលាភីដែរ។ ម៉្យាងទៀតអច្ច័យទានពុំបង្កើតអានុភាពឡើយ បើអច្ច័យលាភីទទួលមរណភាព នៅមុន ឬ ក្នុងពេលដែលម្ចាស់បណ្តាំទទួលមរណភាព។

**១.២ ការយល់ព្រម និងការបោះបង់អច្ច័យទាន**

អច្ច័យទានជាឆន្ទៈឯកតោភាគីរបស់ម្ចាស់បណ្តាំ ប៉ុន្តែឆន្ទៈការយល់ព្រម ឬ បោះបង់អច្ច័យទាន ជាសិទ្ធិរបស់អច្ច័យលាភី។ អច្ច័យលាភីអាចយល់ព្រម ឬ បោះបង់អច្ច័យទាន បានបន្ទាប់ពីទទួលដំណឹងអំពីអច្ច័យទាននោះ ក្រោយមរណភាពរបស់ម្ចាស់បណ្តាំបាន លើកលែងតែអច្ច័យទានភ្ជាប់បន្ទុក បើទោះជាមានការយល់ព្រមក៏ពុំទាន់មានអានុភាពប្រសិនបើមិនទាន់បំពេញល័ក្ខខ័ណ្ឌ។

**១.២.១ ការបោះបង់អច្ច័យទាន និង សិទ្ធិលុបចោលសច្ចានុម័តទទួលស្គាល់ ឬ បោះបង់**

នៅក្រោយពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព អច្ច័យលាភីអាចបោះបង់អច្ច័យលាភីអាចបោះបង់អច្ច័យទាននៅពេលណាក៏បាន។ ប៉ុន្តែ ចំពោះការបោះបង់អច្ច័យទានសកល ត្រូវអនុលោមតាមបញ្ញត្តិស្តីពីការបោះបង់សន្តតិកម្ម។ ការបោះបង់អច្ច័យទានត្រូវមានអានុភាពប្រតិសកម្ម ចាប់ពីពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព។[60] ស្របតាមបញ្ញត្តិស្តីពីការបោះបង់សន្តតិកម្ម អច្ច័យលាភី នៃអច្ច័យទានសកលត្រូវដាក់ពាក្យសុំបោះបង់ទៅតុលាការ អានុភាពនៃការបោះបង់ត្រូវបានចាត់ទុកថាអច្ច័យលាភីពុំមែនជាអច្ច័យលាភីតាំងពីដំបូង។ ការទទួលស្គាល់ ឬ ការបោះបង់អច្ច័យទានពុំអាចលុបចោលវិញបានទេ។[61] ប៉ុន្តែក្នុងករណីដែល

---

[59] មាត្រា១២០៧ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[60] មាត្រា១២០១ ក្រមរដ្ឋប្បវេណីដដែល

[61] មាត្រា១២០៤ ក្រមរដ្ឋប្បវេណីដដែល

ការយល់ព្រម ឬ ការបោះបង់ដោយមានវិការៈ អនុលោមតាមច្បាប់ គេអាចធ្វើការលុបចោលសច្ចានុម័តនោះបាន ក្នុងរយៈពេល ៦ខែ។

### ១.២.២ ការទទួលស្គាល់ ឬ បោះបង់ករណីអច្ច័យលាភីជាសន្តតិជន

ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន បើបានបោះបង់សន្តតិកម្ម បុគ្គលនោះត្រូវបានចាត់ទុកថាបាន បោះបង់អច្ច័យទានផងដែរ។ អច្ច័យលាភីនោះ មិនអាចទទួលស្គាល់អច្ច័យទានដោយការបោះបង់ចោលសន្តតិកម្មបានឡើយ។ ទោះបីជាបានទទួលស្គាល់សន្តតិកម្មហើយក៏ដោយ ក៏អច្ច័យលាភីខាងលើអាចបោះបង់អច្ច័យទានមានកំណត់ បានដែរ។[62] បញ្ញត្តិស្តីពីការបោះបង់ ឬ ការទទួលស្គាល់អច្ច័យទានរបស់អច្ច័យលាភីជាសន្តតិជននេះ មានគោលបំណងរក្សាការពារនូវផលប្រយោជន៍សន្តតិជនដទៃទៀត ដែលពុំមែនជាអច្ច័យលាភីតាមគោលការណ៍សមធម៌ ព្រោះស្ថានភាពរបស់អច្ច័យទាន គឺជាការទទួលបានផលប្រយោជន៍ពីមតកជន ទន្ទឹមនឹងរបបសន្តតិកម្មមានភ្ជាប់ទាំងសិទ្ធិ និងកាតព្វកិច្ច។ ដូច្នេះក្នុងស្ថានភាពមួយដែលបុគ្គលទទួលបាននូវឋានៈពីរជា អច្ច័យលាភី និង សន្តតិជន ហើយខ្លួនបានបោះបង់សន្តតិកម្មដែលភ្ជាប់ទៅនឹងកាតព្វកិច្ច ដោយជ្រើសរើសទទួលតែផលនៃអច្ច័យទានហាក់ពុំមានសមភាពសម្រាប់សន្តតិជនដទៃឡើយ។

### ១.២.៣ មរណភាពនៃអច្ច័យលាភី

អច្ច័យទានពុំបង្កើតអានុភាពឡើយ បើអច្ច័យលាភីទទួលមរណភាព នៅមុន ឬ ក្នុងពេលដែលម្ចាស់បណ្តាំទទួលមរណភាព។ ត្រូវអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអច្ច័យទានភ្ជាប់ជាមួយល័ក្ខខ័ណ្ឌបង្អង់ ហើយអច្ច័យលាភីបានទទួលមរណភាពមុនពេលដែលល័ក្ខខ័ណ្ឌត្រូវបានបំពេញ។ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ។[63] មរណភាពនៃអច្ច័យលាភី មុន ឬតំណាលនឹងមតកជន ឬ មរណភាពនៃអច្ច័យលាភីករណីពុំទាន់បំពេញល័ក្ខខ័ណ្ឌបង្អង់ គឺជាមូលហេតុដែលនាំឲ្យអច្ច័យទានពុំអាចបង្កើតអានុភាពចំពោះចំណែកដែលត្រូវបានកំណត់ជាអច្ច័យទាននោះ ព្រោះអច្ច័យលាភីត្រូវបានចាត់ទុកថារលត់នូវសិទ្ធិ មុនពេលដែលមតកសាសន៍មានអានុភាព ប៉ុន្តែក្នុងករណីដែលមតកជនបានសម្តែងនូវឆន្ទៈផ្ទេរបន្តនូវប្រទានកម្មនោះដោយរបៀបផ្សេង នោះអ្នកប្រតិបត្តិត្រូវអនុវត្តតាម ម្យ៉ាងទៀតក្នុងករណីមរណភាពរបស់អច្ច័យលាភីក៏ពុំរាំងដល់ការទទួលជំនួសនូវអច្ច័យលាភីករណីដែលអច្ច័លាភីជាសន្តតិជនរបស់មតកសាសន៍[64] នោះទេ ប៉ុន្តែប្រសិនបើអច្ច័យលាភីជាតតិយជននោះការទទួលជំនួសពុំមានអានុភាពឡើយបើគ្មានឆន្ទៈរបស់មតកជនបានបង្ហាញ។

[62] មាត្រា១២០៥ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[63] មាត្រា១២០០ ក្រមរដ្ឋប្បវេណីដដែល

[64] មាត្រា១២០០, ចា៣ ក្រមរដ្ឋប្បវេណីដដែល

### ១.២.៤ ការទទួលស្គាល់ ឬ បោះបង់ដោយសន្តតិជនអច្ច័យលាភី

បើអច្ច័យលាភីបានទទួលមរណភាព ដោយមិនបានទទួលស្គាល់ ឬ បោះបង់អច្ច័យទានទេ សន្តតិជនរបស់អច្ច័យទាននោះអាចទទួលស្គាល់ ឬបោះបង់អច្ច័យទានបានត្រឹមទំហំនៃសិទ្ធិលើសន្តតិកម្មរបស់ខ្លួន។[65] បញ្ញត្តិនេះចែងអំពីការទទួលស្គាល់ ឬ បោះបង់អច្ច័យទានដោយសន្តតិជនរបស់អច្ច័យលាភី ក្នុងស្ថានភាពនៃការទទួលជំនួសនូវអច្ច័យទាន។ យោងតាមបញ្ញត្តិស្ដីពីសន្តតិកម្មជំនួស និងបញ្ញត្តិស្ដីពីអច្ច័យទាន សន្តតិកម្មជំនួសកើតមានចំពោះបច្ឆាញាតិផ្ទាល់របស់មតកជន[66]ប៉ុណ្ណោះ រីឯមាត្រាដែលចែងពីអច្ច័យទាន បញ្ញត្តថា អច្ច័យទានពុំបង្កើតអានុភាពឡើយ បើអច្ច័យលាភីបានទទួលមរណភាពមុន ឬក្នុងពេលមតកជនទទួលមរណភាព [67] ប៉ុន្តែក្នុងករណីដែលសន្តតិជនត្រូវសន្មតថាជាអច្ច័យលាភីនោះ អានុភាពនៃមរណភាពអច្ច័យលាភីពុំរារាំងក្នុងការទទួលស្គាល់ ឬបោះបង់ដោយសន្តតិជនរបស់អច្ច័យលាភីនោះទេ ដូច្នេះមាត្រានេះចែងទទួលស្គាល់ក្នុងករណីដែលអច្ច័លាភី ជាសន្តតិជនប៉ុណ្ណោះ ទើបអាចកើតមាននូវសន្តតិកម្មជំនួស បើអច្ច័យលាភីជាតតិយជនពុំមែនជាសន្តតិជនបានទទួលមរណភាពអច្ច័យទាននោះនឹងពុំមានអានុភាព ទាល់តែមានឆន្ទៈដោយឡែករបស់មតកជនទើបអនុវត្តន៍ទៅតាមឆន្ទៈនោះ។

### ១.៣ អច្ច័យទានភ្ជាប់បន្ទុក

អច្ច័យទានភ្ជាប់បន្ទុក គឺជាអច្ច័យទានដែលអច្ច័យលាភីត្រូវទទួលបន្ទុកនូវករណីយកិច្ចមួយចំនួនតាមផ្លូវច្បាប់ អច្ច័យទានភ្ជាប់បន្ទុកទាមទារឲ្យអច្ច័យលាភីត្រូវបំពេញទៅតាមល័ក្ខខ័ណ្ឌ ដើម្បីឲ្យអច្ច័យទាននោះបង្កើតអានុភាព ហេតុនេះមរណភាពនៃអនុប្បទាយីមិនធ្វើឲ្យអច្ច័លាភីទទួលទ្រព្យនោះទេ ព្រោះបន្ទុកនៃអច្ច័យទានជាល័ក្ខខ័ណ្ឌបង្អង់ក្នុងការបង្កើតអានុភាពរបស់វា។ ដោយសារលក្ខខណ្ឌទាំងនោះធ្វើឲ្យ អច្ច័យលាភីត្រូវបានកំណត់ឲ្យមានសិទ្ធិ និងករណីយកិច្ចមួយចំនួនត្រូវអនុវត្តដូចខាងក្រោម៖

### ១.៣.១ ការលុបចោលអច្ច័យទានភ្ជាប់បន្ទុក

បើអច្ច័យលាភីពុំបានអនុវត្តករណីយកិច្ចដែលម្ចាស់បណ្ដាំបានតម្រូវ ឲ្យអច្ច័យលាភីនោះទទួលបន្ទុកជាថ្នូរនឹងអច្ច័យទានទេ អ្នកប្រតិបត្តមតកសាសន៍ ឬ បើគ្មានអ្នកប្រតិបត្តិមតកសាសន៍ទេ សន្តតិជនអាចដាស់តឿនឲ្យអច្ច័យលាភីនោះអនុវត្តករណីយកិច្ចនោះ ដោយកំណត់កំឡុងពេលសមរម្យ ហើយប្រសិនបើអច្ច័យលាភីនោះមិនអនុវត្តករណីយកិច្ច នៅក្នុងកំឡុងពេលនោះទេ អ្នកប្រតិបត្តមតកសាសន៍ ឬ សន្តតិជននោះអាចទាមទារទៅ

[65] មាត្រា១២០៣ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[66] មាត្រា១១៥៧ ក្រមរដ្ឋប្បវេណីដដែល

[67] មាត្រា១២០០, ច១ ក្រមរដ្ឋប្បវេណីដដែល

តុលាការឲ្យលុបចោលអច្ច័យទាននោះបាន។[68] ជាក់ស្តែងអច្ច័យទានអាចលុបចោលក្រោមរូបភាពពីរយ៉ាង គឺលុបចោលតាមឆន្ទៈរបស់ម្ចាស់បណ្តាំមុនទទួលមរណភាព និង លុបចោលក្រោមមូលហេតុនៃ ការមិនអនុវត្តករណីយកិច្ច(ដោះបន្ទុក)របស់អច្ច័យលាភីស្របតាមឆន្ទៈម្ចាស់បណ្តាំ។

### ១.៣.២ សិទ្ធិ និង ករណីយកិច្ចអច្ច័យលាភីភ្ជាប់បន្ទុក

អច្ច័យលាភី មានសិទ្ធិទទួលនូវផលអច្ច័យទាន លើកលែងតែ ជនដែលបានទទួលអច្ច័យទានភ្ជាប់បន្ទុក ត្រូវទទួលខុសត្រូវក្នុងការអនុវត្តករណីយកិច្ចដែលខ្លួនទទួលបន្ទុក ត្រឹមតែកម្រិតដែលមិនលើសពីតម្លៃនៃកម្មវត្ថុនៃអច្ច័យទាននោះប៉ុណ្ណោះ។ បើតម្លៃនៃកម្មវត្ថុនៃអច្ច័យទានភ្ជាប់បន្ទុក បានថយចុះ ដោយសារការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង អច្ច័យលាភីត្រូវរួចផុតពីករណីយកិច្ចដែលខ្លួនត្រូវទទួលបន្ទុក តាមសមាមាត្រនៃភាគដែលចុះថយនោះ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ត្រូវអនុលោមតាម។[69]

## ផ្នែកទី២៖ ការអនុវត្តមតកសាសន៍

ដើម្បីអនុវត្តនូវកិច្ចនីតិវិធីនានា ក្នុងរបបមតកសាសន៍ មិនត្រឹមតែត្រូវការបញ្ជាក់អំពីមន្ត្រីសាធារណៈប៉ុណ្ណោះទេ គឺទាមទារឲ្យមានអ្នកអនុវត្តសម្រាប់ដំណើរការនៃនីតិវិធីមួយចំនួនដូចខាងក្រោម៖

### ២.១ អ្នកប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍ ជាបុគ្គល ឬ ក្រុមបុគ្គលដែលបានទទួលនូវសិទ្ធិ និងករណីយកិច្ចមួយចំនួនក្នុងការអនុវត្តសកម្មភាពក្នុងកិច្ចនីតិវិធីប្រតិបត្តិចំពោះមតកសាសន៍។ ដូច្នេះដើម្បីអាចក្លាយអ្នកប្រតិបត្តិមតកសាសន៍ត្រូវគោរពតាមលក្ខខណ្ឌ តួនាទី និងភារកិច្ចមួយចំនួនផងដែរ។

### ២.១.១ ការជ្រើសតាំង និងជនមានសមត្ថភាពជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍ត្រូវបានជ្រើសរើសក្នុងចំណោមសមត្ថជន ដែលមិនមែនជា ជនក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិតូបត្ថម្ភ អនីតិជន ជនធនក្ស័យ[70] និងជនដែលមតកជនប្រកាសថាត្រូវបានផ្តាច់ពីមត៌ក ឬ ប្រកាសថាជាអភព្វបុគ្គល។ ម្ចាស់បណ្តាំអាចកំណត់អ្នកប្រតិបត្តិមតកសាសន៍ម្នាក់ ឬ ច្រើននាក់ ឬ អាចប្រគល់អាណត្តិឲ្យតតិយជនកំណត់អ្នកប្រតិបត្តិនោះតាមមតកសាសន៍បាន។[71] អ្នកប្រតិបត្តិមតកសាសន៍អាចជ្រើសតាំងដោយផ្ទាល់តាមការកំណត់របស់មតកជន និង ក្នុងករណីដែលម្ចាស់បណ្តាំប្រគល់អាណត្តិឲ្យ

---

[68] មាត្រា១១៩៣ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[69] មាត្រា១២១១ ក្រមរដ្ឋប្បវេណីដដែល

[70] មាត្រា ១២១៧ ក្រមរដ្ឋប្បវេណីដដែល

[71] មាត្រា១១៨៦ ក្រមរដ្ឋប្បវេណីដដែល

តតិយជនតាមរយៈបណ្តាំមត៌ក ជនដែលទទួលអាណត្តិ ត្រូវកំណត់ជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍ ហើយបើគ្មានការហាមឃាត់របស់មតកជនទេ ជនដែលទទួលអាណត្តិក៏អាចកំណត់ខ្លួនជាអ្នកប្រតិបត្តិមតកសាសន៍ និង ត្រូវជូនដំណឹងទៅសន្តតិជន ដោយគ្មានការយឺតយ៉ាវ។ ប្រសិនបើគ្មានអ្នកប្រតិបត្តិមតកសាសន៍ ឬ បាត់បង់អ្នកប្រតិបត្តិ តុលាការអាចជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ តាមរយៈការទាមទាររបស់សន្តតិជន ឬជនពាក់ព័ន្ធនឹងផលប្រយោជន៍។ គេពុំសុទ្ធតែចាំបាច់ក្នុងការជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍នោះទេ ក្នុងករណីដែលសន្តតិជនបានធ្វើការព្រមព្រៀងអនុវត្តមតកសាសន៍ដោយខ្លួនឯង គេអាចអនុវត្តទៅបាន។ អ្នកប្រតិបត្តិមតកសាសន៍ក៏មានសិទ្ធិជ្រើសតាំងបន្ត នូវអ្នកប្រតិបត្តិមតកសាសន៍ផ្សេងដោយភ្ជាប់ទៅនឹងមូលហេតុដែលពុំអាចចៀសវាងបាន ប៉ុន្តែ អ្នកប្រតិបត្តិមតកសាសន៍នោះត្រូវទទួលខុសត្រូវក្នុងការជ្រើសតាំង និងការត្រួតពិនិត្យជននោះ ចំពោះអច្ច័យលាភី និងសន្តតិជន ករណីដែលជនដែលខ្លួនជ្រើសរើសបានអនុវត្តភារកិច្ចដែលនាំឲ្យខូចខាតផលប្រយោជន៍ចំពោះអច្ច័យលាភី និងសន្តតិជន ជននោះត្រូវទទួលខុសត្រូវសំណងការខូចខាតដែលបានកើតឡើង។ ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ តាមរយៈជនដែលមានតួនាទីជាអ្នកប្រតិបត្តិមតកសាសន៍ស្រាប់នោះមានលក្ខណៈរឹតត្បិត ផ្អែកតាមឆន្ទៈនៃរបបមតកសាសន៍ ជនដែលទទួលតួនាទីភារកិច្ច ច្រើនតែត្រូវបានជ្រើសតាំងដោយមតកជន ឈរលើស្ថានភាពនៃទំនុកចិត្តរបស់មតកជនដូច្នេះចំពោះការផ្លាស់ប្តូរជនដែលប្រតិបត្តិ គេមានការព្រួយបារម្ភថាបុគ្គលនោះអាចទុកចិត្តក្នុងការផ្តល់តួនាទីឲ្យ ឬ អត់ ដើម្បីធានាដល់ការការពារផលប្រយោជន៍របស់សន្តតិជន ឬ ជនមានផលប្រយោជន៍ពាក់ព័ន្ធ។

### ២.១.២ តួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ ហើយប្រគល់បញ្ជីនោះឲ្យទៅសន្តតិជន ដោយគ្មានការយឺតយ៉ាវ។[72] ការធ្វើបញ្ជីសារពើភ័ណ្ឌមានភាពចាំបាច់ក្នុងការកំណត់ឲ្យបានច្បាស់លាស់នូវកម្មវត្ថុ និង សិទ្ធិគ្រប់គ្រងចាត់ចែងមត៌ករបស់មតកជនដើម្បីមានភាពងាយស្រួលក្នុងការចាត់ចែងសិទ្ធិ និងកាតព្វកិច្ចនានា របស់សន្តតិជន និងជនមានផលប្រយោជន៍ពាក់ព័ន្ធ។ អ្នកប្រតិបត្តិមតកសាសន៍មានសិទ្ធិ និងករណីយកិច្ចក្នុងការគ្រប់គ្រងមត៌ក និងធ្វើនូវរាល់សកម្មភាពផ្សេងទៀតដែលចាំបាច់ ដើម្បីប្រតិបត្តិមតកសាសន៍។[73] មាត្រានេះហាក់ពង្រីកវិសាលភាពនៃការអនុវត្តសិទ្ធិរបស់អ្នកប្រតិបត្តិមតកសាសន៍ ដោយពុំមានភាពច្បាស់លាស់អំពីសកម្មភាពនោះទេ ប៉ុន្តែទោះជាយ៉ាងណារាល់សកម្មភាពផ្សេងៗអ្នកប្រតិបត្តិមតកសាសន៍ត្រូវបម្រើផលប្រយោជន៍ដល់ការអនុវត្តមតកសាសន៍ ក៏ដូចជាមានអានុភាពដល់សន្តតិជន។ តាមស្មារតីនៃមាត្រានេះនាំឲ្យអ្នកប្រតិបត្តិមតកសាសន៍មានតួនាទីដូចជា៖ ធ្វើបញ្ជីសារពើភ័ណ្ឌកំណត់ទ្រព្យសកម្ម ទ្រព្យអកម្ម និង

[72] មាត្រា១២១៩ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[73] មាត្រា១២២០ ក្រមរដ្ឋប្បវេណីដដែល

ជម្រះបញ្ជីមុនពេលកំណត់ការបែងចែកមត៌កក។ ធ្វើការផ្សព្វផ្សាយដំណឹងជាសាធារណៈ ដើម្បីជូនដំណឹងអំពីមរណភាពមតកជនដើម្បីឲ្យ ម្ចាស់បំណុល ឬ កូនបំណុលមតកជនចូលរួមមក ទាក់ទងក្នុងការធ្វើការជម្រះបញ្ជីទូទាត់បំណុល។ ករណីដែលគ្មានសន្តតិជន អ្នកប្រតិបត្តិមតកសាសន៍ត្រូវធ្វើការប្រកាសស្វែងរកសន្តតិជន។ អ្នកប្រតិបត្តិមតកសាសន៍ត្រូវធ្វើការប្រកាសអំពីពន្ធដែលត្រូវបង់ជូនរដ្ឋ។ ធ្វើការដាស់តឿន និងដាក់រយៈពេលកំណត់ក្នុងការបង្ហាញខ្លួនរបស់ជនដែលមានផលប្រយោជន៍ទាំងអស់។ អ្នកប្រតិបត្តិមតកសាសន៍អាចធ្វើការស្នើសុំបិទគណនីធនាគាររបស់មតកជន។ ធ្វើការប្រកាសអំពីការបរិច្ឆេទនៃថ្ងៃបិទបញ្ជីសារពើភ័ណ្ឌ។ ធ្វើការប្រគល់ឲ្យសន្តតិជន នូវបញ្ជីសារពើភ័ណ្ឌរបស់មតកជន ក្រោយការទូទាត់ជម្រះបញ្ជីបានចប់សព្វគ្រប់ជាស្ថាពរមុនពេលចាប់ផ្តើមការបែងចែកតាមមតកសាសន៍។ បន្ថែមលើតួនាទីខាងលើ អ្នកប្រតិបត្តិមតកសាសន៍មានតួនាទីដ៏ចម្បង៣បន្ថែមទៀត ដូចជា៖ **ទីមួយ៖** ធ្វើការកំណត់ស្វែងរក និងទៅជួបផ្ទាល់ជាមួយបណ្តាជនដែលមានផលប្រយោជន៍ក្នុងគោលដៅផ្តល់ព័ត៌មាន និងរៀបចំដំណើរការនៃនីតិវិធីជម្រះបញ្ជីសារពើភ័ណ្ឌសន្តតិកម្មរបស់មតកជនចាប់តាំងពីពេល ចាប់ផ្តើមជំនួប រហូតដល់ពេលបែងចែកសន្តតិកម្ម។ **ទីពីរ៖** ធ្វើការចាប់ផ្តើមបំពេញសំណុំឯកសារតាមផ្លូវច្បាប់ដើម្បីដាក់ជូនទៅតុលាការដើម្បីបញ្ជាក់ឱ្យឃើញថាបណ្តាំមត៌កមានសុពលភាពត្រឹមត្រូវតាមច្បាប់ និងបញ្ជាក់ថាអ្នកប្រតិបត្តិមតកសាសន៍បានចាប់ផ្តើមបំពេញតួនាទីរបស់ខ្លួនបានត្រឹមត្រូវតាមបញ្ញត្តិច្បាប់។ **ទីបី៖** ធ្វើការបែងចែកអច្ច័យទាន និងធ្វើការចាត់ចែងបែងចែកសន្តតិកម្មដែលនៅសល់ចំពោះបណ្តាសន្តតិជន ជាទាយាទរបស់មតកជន ឬក៏ប្រគល់អាណត្តិបែងចែកតាមបណ្តាំមតកជន ទៅឱ្យតតិយជនណាមួយបំពេញតួនាទីនេះប្រសិនបើមានការចាំបាច់ដូចបានបញ្ជាក់ក្នុងបណ្តាំមត៌ក។[74]

### ២.១.៣ កម្រៃ និង សោហ៊ុយនៃអ្នកប្រតិបត្តិមតកសាសន៍

កម្រៃ និងសោហ៊ុយនៃអ្នកប្រតិបត្តិមតកសាសន៍ត្រូវបែងចែកជាពីរគឺ កម្រៃដែលជាថ្នូរនៃការអនុវត្តតួនាទី និងសោហ៊ុយចាំបាច់នានាក្នុងនីតិវិធីនៃការបើកមតកសាសន៍។ កម្រៃជាថ្នូរនៃការអនុវត្តតួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍ក៏អាច មាន ឬ គ្មាន អាស្រ័យលើអ្នកប្រតិបត្តិនោះជាអ្នកប្រតិបត្តិដោយយកកម្រៃឬពុំយកកម្រៃ រីឯសោហ៊ុយដើម្បីអនុវត្តន៍នីតិវិធីបើកមតកសាសន៍ជាចំណាយចាំបាច់ដែលខានពុំបាន។

#### ក. កម្រៃរបស់អ្នកប្រតិបត្តិបណ្តាំមត៌ក

ការប្រតិបត្តិបណ្តាំមត៌កអាចមានពីរយ៉ាង គឺការប្រតិបត្តិដោយយកកម្រៃ និងការប្រតិបត្តិដោយមិនយកកម្រៃ។ អ្នកប្រតិបត្តិបណ្តាំមត៌កមានសិទ្ធិ និងករណីយកិច្ចក្នុងការគ្រប់គ្រងមត៌ក និងធ្វើរាល់សកម្មភាពផ្សេងទៀតដែលចាំបាច់ដើម្បីប្រតិបត្តិបណ្តាំមត៌ក ពេលប្រតិបត្តិកិច្ចការនោះត្រូវចាត់ចែងកិច្ចការដោយប្រុងប្រយ័ត្នក្នុង

[74] ឯកសារនីតិបេតិកភណ្ឌគ្រួសា របស់សាស្ត្រាចារ្យ ស្រី វណ្ណធី, ១៣ មករា ២០២៣

នាមជាអ្នកគ្រប់គ្រងសុចរិត ហើយបន្ទុកមុខងារនេះធ្ងន់ធ្ងរណាស់ដូចនេះ គប្បីទទួលកម្រៃ ជាពិសេសក្នុងករណីដែលជ្រើសតាំងតតិយជនដែលមិនមែនជាសន្តតិជនឲ្យធ្វើជាអ្នកប្រតិបត្តិបណ្តាំមត៌កគួរតែមានកម្រៃ។ ចំនួនទឹកប្រាក់នៃកម្រៃនោះវិញ ប្រសិនបើមានកំណត់នៅក្នុងលិខិតបណ្តាំមត៌កត្រូវអនុវត្តតាមបណ្តាំមត៌កត្រូវអនុវត្តតាមបណ្តាំមត៌កនោះ។ បើក្នុងបណ្តាំមត៌កកំណត់ថាពុំមានកម្រៃទេ នោះមិនមានសិទ្ធិទាមទារកម្រៃទេ ហេតុនេះបើមិនពេញចិត្ត អាចបដិសេធមិនកាន់មុខងារនេះបានក្នុងករណីដែលបណ្តាំមត៌កពុំបានកំណត់កម្រៃទេ តុលាការត្រូវកំណត់ចំនួនទឹកប្រាក់នៃកម្រៃនោះ តាមពាក្យស្នើសុំរបស់អ្នកប្រតិបត្តិបណ្តាំមត៌ក។ ឃ្លា បើយល់ឃើញថាសមរម្យក្នុងការបង់កម្រៃ គឺដោយសារថា អាចមានករណីដែលសន្តតិជនធ្វើជាអ្នកប្រតិបត្តិបណ្តាំមត៌ក ហើយដែលមានការប្រតិបត្តិនោះមានភាពងាយស្រួល ដូចនេះមិនចាំបាច់ឲ្យកម្រៃក៏បានដែរ។ ករណីតតិយជនជាអ្នកប្រតិបត្តិបណ្តាំ មត៌កទោះជាតិចក៏ដោយក៏តុលាការគួរតែកំណត់ចំនួនទឹកប្រាក់នៃកម្រៃនេះដែរ។ ពេលកំណត់ចំនួនទឹកប្រាក់នៃកម្រៃនេះត្រូវពិចារណាទៅលើស្ថានភាពនៃមត៌ក ទំនាក់ទំនងរវាងម្ចាស់បណ្តាំ និងអ្នកប្រតិបត្តិបណ្តាំមត៌កព្រមទាំងស្ថានភាពផ្សេងៗទៀត។[75]

### ខ. សោហ៊ុយដើម្បីប្រតិបត្តិបណ្តាំមត៌ក

សោហ៊ុយដើម្បីប្រតិបត្តិមតកសាសន៍ជាបន្ទុកមួយនៃមត៌កហេតុនេះអាចកាត់ពីមត៌កបាន។ សោហ៊ុយដើម្បីប្រតិបត្តិបណ្តាំមត៌កមានដូចជា៖

- សោហ៊ុយចាំបាច់សម្រាប់នីតិវិធីពិនិត្យបញ្ជាក់លិខិតមតកសាសន៍ សោហ៊ុយចាំបាច់នេះសំដៅលើសេវារដ្ឋបាលពេលដាក់ពាក្យសុំទៅតុលាការ សោហ៊ុយអនុវត្តន៍នីតិវិធីក្នុងតុលាការជាដើម ផ្ទុយទៅវិញការចំណាយធ្វើដំណើរ ឬសោហ៊ុក្រៅពីចំណាយលើនីតិវិធីពុំរាប់ថាជាការចំណាយចាំបាច់ទេ។
- សោហ៊ុយធ្វើបញ្ជីសារពើភ័ណ្ឌមត៌ក បញ្ជីសារពើភណ្ឌធ្វើឡើងក្នុងបំណងពិនិត្យបញ្ជាក់ពីភាពជាក់លាក់នៃមត៌ក ហើយអ្នកប្រតិបត្តិមតកសាសន៍មានតួនាទីធ្វើបញ្ជីសារពើភ័ណ្ឌនោះ។
- សោហ៊ុយគ្រប់គ្រងមត៌ក សោហ៊ុយគ្រប់គ្រងមត៌ក សំដៅលើថ្លៃចំណាយទាំងឡាយដែលប្រើប្រាស់ក្នុងសកម្មភាពគ្រប់គ្រង ថែទាំ ជួសជុល ប្រមូលផលស៊ីវិល ឬផលធម្មជាតិ ជាអាទិ៍ ដែលមានក្នុងមត៌ក។

---

[75] សៀវភៅស្តីពី សេចក្តីកំណត់មាត្រានីមួយៗ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៩ របស់ក្រសួងយុត្តិធម៌ (គន្លឹ៨-គន្លឹ៩) ពន្យល់ មាត្រា១២២៦

- កម្រៃអ្នកប្រតិបត្តិមតកសាសន៍ ប្រសិនបើអ្នកប្រតិបត្តិមតកសាសន៍ជាអ្នកប្រតិបត្តិដោយយកកម្រៃ នោះសោហ៊ុយដែលចំណាយលើកម្រៃអ្នកប្រតិបត្តិជាបន្ទុកនៃសោហ៊ុយដើម្បីប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិបណ្តាំមត៌កអាចកាត់សោហ៊ុយទាំងនេះពីមត៌កបាន។ ការកាត់សោហ៊ុយប្រតិបត្តិមតកសាសន៍មិនអាចបន្ថយភាគបម្រុងបានទេ។[76]

### ២.១.៤ ការលាឈប់ និងបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍

ដើម្បីលាឈប់ពីមុខងាររបស់ខ្លួន អ្នកប្រតិបត្តិមតកសាសន៍ត្រូវមានមូលហេតុត្រឹមត្រូវហើយចាំបាច់ត្រូវមានការអនុញ្ញាតពីតុលាការ។ ដោយសារតែមុខងាររបស់អ្នកប្រតិបត្តិមតកសាសន៍គឺធ្វើឲ្យបានសម្រេចនូវឆន្ទៈរបស់មតកជនដែលទទួលមរណភាពគឺហាក់បីដូចជាការងារអាណាព្យាបាល។ មូលហេតុត្រឹមត្រូវនោះមានដូចជា មានជំងឺ ត្រូវបំពេញបេសកកម្មនៅឆ្ងាយរយៈពេលវែង កាន់កាប់មុខងារមួយថ្មីដែលមានភាពមមាញឹកហួសហេតុ។ ករណីបញ្ឈប់អ្នកប្រតិបត្តិបណ្តាំមត៌ក ប្រសិនបើមានមូលហេតុត្រឹមត្រូវជនដែលទាក់ទងនឹងផលប្រយោជន៍ ដូចជាសន្តតិជន ឬអច្ច័យលាភីអាចដាក់ពាក្យសុំទៅតុលាការឲ្យបញ្ឈប់អ្នកប្រតិបត្តិបណ្តាំមត៌កនោះបាន។ មូលហេតុនៃការបញ្ឈប់មានដូចជា ភាពខ្ជិលច្រអូសបំពេញមុខងារ ការបាត់ខ្លួនរបស់អ្នកប្រតិបត្តិមតកសាសន៍ មានជំងឺរយៈពេលវែងដែលជាឧបសគ្គក្នុងការប្រតិបត្តិ។ ក្នុងករណីដែលមានមូលហេតុដែលមិនអាចក្លាយជា អ្នកប្រតិបត្តិមតកសាសន៍ដោយបុគ្គលដែលមិនអាចក្លាយជាអ្នកប្រតិបត្តិមតកសាសន៍[77] អ្នកប្រតិបត្តិបណ្តាំមត៌កនោះត្រូវបាត់បង់ដោយស្វ័យប្រវត្តិនូវឋានៈរបស់ខ្លួន ហេតុនេះហើយសន្តតិជន ឬជនដែលទាក់ទងនឹងផលប្រយោជន៍ផ្សេងទៀត អាចដាក់ពាក្យសុំទៅតុលាការឲ្យជ្រើសតាំងអ្នកប្រតិបត្តិបណ្តាំមត៌កថ្មីតាមការទាមទារសន្តតិជន ឬអ្នកពាក់ព័ន្ធនឹងផលប្រយោជន៍[78] បានដោយមិនចាំបាច់មាននីតិវិធីសុំឲ្យបញ្ឈប់ឡើយ។

## ២.២ នីតិវិធីក្នុងបើកមតកសាសន៍

បើទោះបីជាមរណភាពរបស់មតកជនជាមូលហេតុដែលនាំឲ្យ របបសន្តតិកម្ម ក៏ដូចជាមតកសាសន៍មានអានុភាព ឬ ត្រូវបើកយ៉ាងណាក្តី ប៉ុន្តែដើម្បីធានាលើសុពលភាពរបស់មតកសាសន៍នោះថាមានអានុភាព ឬអាចមានសុវត្ថិភាពគតិយុត្ត ឬអត់នោះទាមទារឲ្យមានការអនុវត្តបន្ថែមចំពោះលិខិតបណ្តាំដែលមានស្រាប់នោះទៅតាមកិច្ចនីតិវិធីមួយចំនួន។

[76] សៀវភៅស្តីពី សេចក្តីកំណត់មាត្រានីមួយៗ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៩ របស់ក្រសួងយុត្តិធម៌ (គន្លឹ៨-គន្លឹ៩) ពន្យល់ មាត្រា១២២៨

[77] មាត្រា១២១៧ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

[78] មាត្រា១២១៨ ក្រមរដ្ឋប្បវេណីដដែល

### ២.២.១ អត្ថន័យនៃការបើកមតកសាសន៍

ការអនុវត្តមតកសាសន៍ គឺជាការចាត់ចែងដែលចាំបាច់ ដើម្បីសម្រេចនូវខ្លឹមសារនៃមតកសាសន៍នោះ ក្រោយពេលដែលអានុភាពនៃមតកសាសន៍នោះ បានកើតឡើង។ អានុភាពនៃមតកសាសន៍ កើតឡើងដោយគ្មាននីតិវិធីច្បាស់លាស់នោះទេ។ បើទោះជាការទទួលស្នងមត៌កកើតឡើងតាមគោលការណ៍ស្វ័យប្រវត្តិយ៉ាងណាក្តី ប៉ុន្តែស្ថានភាពដែលស្នងដោយស្វ័យប្រវត្តិនោះត្រូវបានបែងចែកចំពោះទ្រព្យដែលជាចលនវត្ថុ និង អចលនវត្ថុផងដែរ។[79] ជាក់ស្តែងចំពោះចលនវត្ថុត្រូវកត់សម្គាល់តាមរយៈការផ្ទេរការកាន់កាប់ ឬការទទួលការកាន់កាប់ដោយផ្ទាល់របស់សន្តតិជន ដោយឡែកចំពោះវត្ថុដែលជាអចលនវត្ថុការសម្គាល់ដោយការកាន់កាប់ពុំបានបំពេញគ្រប់គ្រាន់ចំពោះលក្ខខណ្ឌនោះឡើយ ពោលគឺអចលនវត្ថុត្រូវបានទាមទារឱ្យមានការចុះបញ្ជីកម្មសិទ្ធិចំពោះអចលនវត្ថុនោះ។

### ២.២.២ ការពិនិត្យ និងការបើកលិខិតមតកសាសន៍

ក្រៅពីមតកសាសន៍ជាលិខិតយថាភូត មតកសាសន៍ទាំងអស់ត្រូវធ្វើការពិនិត្យបញ្ជាក់។ អ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ ត្រូវដាក់ពាក្យសុំបញ្ជាក់លិខិតនោះដោយភ្ជាប់លិខិតមតកសាសន៍នោះ ជូនទៅតុលាការ ដោយគ្មានការយឺតយ៉ាវ ក្រោយពីខ្លួនបានដឹងអំពីការចាប់ផ្តើមសន្តតិកម្ម។ លិខិតមតកសាសន៍ដែលបានបិទដោយប្រថាប់ត្រា អាចបើកបាននៅតែតុលាការដោយមានវត្តមានអ្នកសង្កេតការណ៍ជាសន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ ឬអ្នកតំណាងរបស់ជននោះ។ បុគ្គលដែលបានបើកលិខិតមតកសាសន៍ នៅក្រៅតុលាការនឹងត្រូវផាកពិន័យជាប្រាក់មិនលើសពី ១លានរៀល។ លិខិតមតកសាសន៍នោះ បើទោះបីជាបានបើកនៅក្រៅតុលាការក៏ពុំត្រូវបានចាត់ទុកថាបាត់បង់អានុភាពនោះទេ។[80]

### ២.២.៣ គោលបំណងនៃការបញ្ជាក់មតកសាសន៍

គោលបំណងនៃការពិនិត្យបញ្ជាក់មតកសាសន៍ គឺជាការរក្សាទុកនូវភស្តុតាង។ តាមរយៈការពិនិត្យបញ្ជាក់ តុលាការបានកត់ត្រាទុកនូវស្ថានភាពខាងក្រៅនៃមតកសាសន៍ ចៀសវាងការក្លែងបន្លំ ឬការផ្លាស់ប្តូរ។ ដូច្នេះ តុលាការនឹងកត់ត្រាទុកនូវមតកសាសន៍ដោយការថតចម្លង ការថតយករូបភាព និង ពណ៌នាស្ថានភាពខាងក្រៅនៃមតកសាសន៍ដោយផ្ទាល់មាត់។ ម្យ៉ាងវិញទៀត តុលាការនឹងមិនវិនិច្ឆ័យសុពលភាពរបស់មតកសាសន៍នោះទេ។ ប្រសិនបើបុគ្គលណាម្នាក់ចង់លើកមតិប្រឆាំងលើសុពលភាពនៃមតកសាសន៍ បុគ្គលនោះត្រូវ

[79] សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ដោយក្រុមការងារនៃគ្រូបង្គោលនៅសាលាភូមិន្ទចៅក្រម, កែសម្រួលលើការបោះពុម្ពលើកទី១, ខែមីនា ឆ្នាំ២០១៧, ភាគ៣, ជំពូកទី៩, ផ្នែកទី១ មតកសាសន៍, ចំណុច៨.១

[80] មាត្រា១២១៣ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

ដាក់ពាក្យបណ្ដឹងទៅតុលាការ។ ការបញ្ជាក់នូវសុពលភាពនៃមតកសាសន៍ មិនមែនជាគោលបំណងនៃការពិនិត្យបញ្ជាក់នោះទេ។[81]

### ២.២.៤ នីតិវិធីសំខាន់ដែលត្រូវគោរពតាមមុនឡើងតុលាការ

អ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ ក្រោយពីបានដឹងពីការចាប់ផ្ដើមសន្តិកម្ម ត្រូវបង្ហាញឯកសារមតកសាសន៍ ទៅកាន់តុលាការ ដោយគ្មានការយឺតយ៉ាវ ហើយតុលាការត្រូវពិនិត្យបញ្ជាក់។ ករណីគ្មានអ្នកថែរក្សាគ្រប់គ្រងមតកសាសន៍ គេត្រូវធ្វើដូចខាងលើដែរ ក្រោយពេលសន្តតិជន ឬជនពាក់ព័ន្ធនឹងផលប្រយោជន៍បានរកឃើញលិខិតមតកសាសន៍។

ប្រសិនបើសន្តតិជន បានរកឃើញមានមតកសាសន៍ដែលរហែក ហើយពួកគេគិតថាមតកសាសន៍នោះត្រូវបានលុបចោល ពួកគេនៅតែត្រូវប្រគល់មតកសាសន៍នោះ ទៅឲ្យតុលាការដើម្បីពិនិត្យបញ្ជាក់ ពីព្រោះតុលាការគឺជាអ្នកកំណត់ចុងក្រោយថាមតកសាសន៍នោះ ត្រូវបានលុបចោល ឬក៏អត់។ ប្រសិនបើមានមតកសាសន៍ត្រូវបានបិទដល់ប្រថាប់ត្រា គេមិនត្រូវបើកមតកសាសន៍នោះទេ។ អ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ដែលបិទដោយប្រថាប់ត្រា សន្តតិជន ឬជនពាក់ព័ន្ធនឹងផលប្រយោជន៍ ត្រូវប្រគល់លិខិតមតកសាសន៍នោះទៅកាន់តុលាការ ដែលមិនត្រូវបើកមើលឡើយ។ ជាធម្មតាមតកសាសន៍ដែលបិទដោយប្រថាប់ត្រា គឺជាមតកសាសន៍ដោយលិខិតសម្ងាត់។ ប៉ុន្តែ ម្ចាស់បណ្ដាំក៏អាចបិទប្រថាប់ត្រានូវមតកសាសន៍ដោយលិខិតផ្ទាល់ខ្លួនផងដែរ។ ក្នុងករណីនេះគេមិនត្រូវបើកមើលមតកសាសន៍ដោយលិខិតផ្ទាល់ខ្លួនដែលបានបិទប្រថាប់ត្រានោះទេ។[82]

### ២.២.៥ នីតិវិធីពិនិត្យបញ្ជាក់នៅតុលាការ

ដើម្បីបញ្ជាក់ពីភាពពិតនៃមតកសាសន៍ និងលក្ខខណ្ឌបង្កើតអានុភាពរបស់វា លិខិតមតកសាសន៍ត្រូវអនុវត្តន៍នីតិវិធីពិនិត្យបញ្ជាក់មួយចំនួន នៅស្ថាប័នដែលមានសមត្ថកិច្ចជាមុនសិនទើបអាចបង្កើតអានុភាពអនុវត្តន៍ស្របច្បាប់បាន។

#### ២.២.៥.១ សមត្ថកិច្ច

សាលាដំបូង គឺជាកន្លែងមានសមត្ថកិច្ចការចាប់ផ្ដើមសន្តតិកម្ម។[83] កន្លែងចាប់ផ្ដើមសន្តតិកម្ម គឺជាអាសយដ្ឋានរបស់មតកជននៅពេលទទួលមរណភាព។ សាលាដំបូងនៃលំនៅដ្ឋានរបស់មតកជនពេលមតក

[81] សេចក្ដីពន្យល់អំពីក្រមរដ្ឋប្បវេណី ដោយក្រុមការងារនៃគ្រូបង្គោលនៅសាលាភូមិន្ទចៅក្រម, កែសម្រួលលើការបោះពុម្ពលើកទី១, ខែមីនា ឆ្នាំ២០១៧, ភាគ៣, ជំពូកទី៩, ផ្នែកទី១ មតកសាសន៍, ចំណុច ៨.២.១

[82] សៀវភៅសេចក្ដីពន្យល់អំពីក្រមរដ្ឋប្បវេណី ដោយក្រុមការងារនៃគ្រូបង្គោលនៅសាលាភូមិន្ទចៅក្រម, កែសម្រួលលើការបោះពុម្ពលើកទី១, ខែមីនា ឆ្នាំ២០១៧, ភាគ៣, ជំពូកទី៩, ផ្នែកទី១មតកសាសន៍, ចំណុច៨.២.២

[83] ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង,ក្រសួងយុត្តិធម៌, ឆ្នាំ២០១០ មាត្រា៤ និងឧបសម្ព័ន ផ្នែកទី៥ ចំណុចទី៥

ជនទទួលមរណភាព មានសមត្ថកិច្ចទទួលពាក្យស្នើសុំពិនិត្យបញ្ជាក់ និងអនុវត្តន៍កិច្ចនីតិវិធីក្នុងតុលាការ ដើម្បីដំណើការនីតិវិធីបើកមតកសសន៍។

### ២.២.៥.២ ការកោះហៅសន្តតិជន ជាអាទិ៍

ជាទូទៅ សន្តតិជនជាអ្នកដាក់ពាក្យសុំស្នើរឲ្យមានការពិនិត្យបញ្ជាក់។ យោងតាមក្រមរដ្ឋប្បវេណី មិនតម្រូវឱ្យមានវត្តមានរបស់សន្តតិជន ឬ អច្ច័យលាភី ក្នុងការពិនិត្យបញ្ជាក់នោះទេ។ ប៉ុន្តែតុលាការគួរតែអនុញ្ញាតឱ្យសន្តតិជន ឬ អច្ច័យលាភី មានឱកាសចូលរួមនីតិវិធីពិនិត្យបញ្ជាក់នោះ។ ដូច្នេះតុលាការត្រូវកំណត់ពេលវេលាសម្រាប់ការពិនិត្យបញ្ជាក់ ហើយកោះហៅសន្តតិជន ឬ អច្ច័យលាភី ដែលតុលាការបានស្គាល់នោះ។ ជាពិសេសប្រសិនបើមតកសាសន៍ត្រូវបានបិទដោយប្រថាប់ត្រា មតកសាសន៍នោះនឹងត្រូវបើកនៅក្នុងតុលាការដែលមានវត្តមានរបស់ សន្តតិជន ជនពាក់ព័ន្ធនឹងផលប្រយោជន៍ ឬអ្នកតំណាងរបស់ពួកគេ។ ដូច្នេះ ការណាមតកសាសន៍ត្រូវបិទដោយប្រថាប់ត្រា តុលាការត្រូវកោះហៅសន្តតិជន និង អច្ច័យលាភី ដែលតុលាការបានស្គាល់ (ប៉ុន្តែ ជាធម្មតាតុលាការមិនស្គាល់អច្ច័យលាភីទេ ពីព្រោះមតកសាសន៍ត្រូវបានបិទដោយប្រថាប់ត្រាបាត់ទៅហើយ)។ ទោះបីជាយ៉ាងនោះ ក៏ដោយ ក្នុងករណីមតកសាសន៍បិទប្រថាប់ត្រា មិនមែនមានន័យថាគ្រប់ សន្តិជនទាំងអស់ត្រូវមានវត្តមាននោះទេ។ ការបើកមតកសាសន៍អាចប្រព្រឹត្តិទៅបាននៅអំឡុងពេលពាក់កណ្តាលនៃនីតិវិធីពិនិត្យបញ្ជាក់បាន។[84]

### ២.២.៥.៣ កាលបរិច្ឆេទនៃការពិនិត្យបញ្ជាក់

តុលាការត្រូវតែពិនិត្យមតកសាសន៍ ទោះបីជាមតកសាសន៍នោះហាក់ដូចជាគ្មានសុពលភាព ឬ ត្រូវបានលុបចោលក្តី ក៏តុលាការត្រូវតែធ្វើការពិនិត្យបញ្ជាក់ដែរ។ តុលាការគប្បីកត់ត្រាចំណុចដូចខាងក្រោម៖

-បុគ្គលដែលបានស្នើសុំពិនិត្យបញ្ជាក់ ក្នុងគោលបំណងផ្ទៀងផ្ទាត់អំពីឋានៈរបស់បុគ្គលនោះថាមានសិទ្ធិ ឬកាតព្វកិច្ចណាមួយក្នុងការអនុវត្តសកម្មភាពនោះដែរឬទេ

-កាលបរិច្ឆេទពិនិត្យបញ្ជាក់ ការបរិច្ឆេទពិនិត្យបញ្ជាក់សារសំខាន់ដល់អ្នកមានផលប្រយោជន៍ពាក់ព័ន្ធជាខ្លាំងក្នុងការកំណត់អំពីរយៈពេលដែលបុគ្គលនោះមានសិទ្ធិ ឬថ្លោះសិទ្ធិក្នុងការអនុវត្តសកម្មភាពណាមួយជាក់ស្តែងដូចជាក្នុងលិខិតមតកសាសន៍នៃជនជួបគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិតរយៈពេលនៃការបង្កើត និងការពិនិត្យត្រូវមានកំឡុងពេលកំណត់ ដើម្បីចៀងវាងការថ្លោះសិទ្ធិ ដែលនាំឲ្យមិនអាចអនុវត្តន៍សន្តតិកម្មតាមបណ្តាំនេះបាន។

---

84 សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ដោយក្រុមការងារនៃគ្រូបង្គោលនៅសាលាភូមិន្ទចៅក្រម, កែសម្រួលលើការបោះពុម្ពលើកទី១, ខែមីនា ឆ្នាំ២០១៧, ភាគ៣, ជំពូកទី៩, ផ្នែកទី១ មតកសាសន៍, ចំណុច៨.២.៣.២

-បុគ្គលដែលមានវត្តមាននៅពេលធ្វើនីតិវិធីពិនិត្យបញ្ជាក់ វត្តមានបុគ្គលដែលចូលរួមក្នុងនីតិវិធី បង្ហាញពីការអនុវត្តកិច្ចនីតិវិធីបានយ៉ាងត្រឹមត្រូវ ព្រោះប្រសិនបើគ្មានការចូលរួមឬបង្ហាញវត្តមានក្នុងតុលាការ តុលាការច្បាស់ជាច្រានចោលពាក្យសុំបញ្ជាក់នោះ វាហាក់ដូចជាស្ថានមួយដែលអវត្តមាននៃភាគីមិនអាចអនុវត្តន៍ការទាញហេតុផលបាន ឬជាសំណុំរឿងដែលគ្មានមនុស្ស។

-ស្ថានភាពខាងក្រៅនៃមតកសាសន៍ ដូចជា ចំនួនទំព័រ ប្រភេទ និងគុណភាពក្រដាស ប្រភេទប៊ិច ហត្ថលេខា និងការលុបបរិច្ឆេទនៅក្នុងមតកសាសន៍ ជាដើម។

-ថតរូបភាព និង ចម្លងមតកសាសន៍នោះ។[85]

[85] សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ដោយក្រុមការងារនៃគ្រូបង្គោលនៅសាលាភូមិន្ទចៅក្រម, កែសម្រួលលើការបោះពុម្ពលើកទី១, ខែមីនា ឆ្នាំ២០១៧, ភាគ៣, ជំពូកទី៩, ផ្នែកទី១ មតកសាសន៍, ចំណុច៨.២.៣.៣

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវ និងបកស្រាយទៅលើប្រធានបទ "របបគតិយុត្តនៃមតកសាសន៍នៅកម្ពុជា" រួចមកយើងសង្កេតឃើញថា មតកសាសន៍ពិតជាលិខិតបណ្តាំចុងក្រោយសម្រាប់សម្តែងឆន្ទៈរបស់មតកជនពិតមែន ព្រោះវាត្រូវបានបង្កើតអានុភាពដោយមរណភាពរបស់ម្ចាស់បណ្តាំ ទន្ទឹមនឹងអាចទទួលស្គាល់ថាមតកសាសន៍មួយអាចបង្កើតអានុភាពបានលុះត្រាតែត្រូវបានធ្វើដោយបំពេញលក្ខខណ្ឌតាមផ្លូវច្បាប់ ចំណុចសំខាន់ៗនៃលក្ខខណ្ឌនៃមតកសាសន៍នោះរួមមាន ដូចជា សមត្ថភាពផ្នែកឆន្ទៈរបស់មតកជន ព្រោះមតកសាសន៍ជាសកម្មភាពឯកតោភាគី ទន្ទឹងនឹងនេះហើយទើបសមត្ថភាពផ្នែកឆន្ទៈក៏ជាចំណុចសំខាន់មួយដែលមិនអាចខ្វះបានដើម្បីឲ្យវាមានសុពលភាព និងអាចបង្កើតអានុភាពបាន បន្ថែមពីនេះសុពលភាពផ្នែកទម្រង់ក៏ជាលក្ខខណ្ឌគ្រឹះនៃមតកសាសន៍ផងដែរ ព្រោះបើមតកសាសន៍ដែលធ្វើឡើងដោយគ្មានសុពលភាពទម្រង់នោះទេនឹងចាត់ទុកជាមោឃៈ ម៉្យាងវិញទៀត របបមតកសាសន៍មិនអាចមានអានុភាពទាំងស្រុងនោះទេ ប្រសិនបើបានបំពាននូវភាគបម្រុង។ មូលហេតុដែលយើងលើកឡើងថាមិនអាចមានអានុភាពទាំងស្រុងនោះព្រោះ បើទោះជាមតកសាសន៍មួយបានកំណត់ចំណែកមត៌កដោយបំពាននូវភាគបម្រុងក៏មតកសាសន៍នោះនៅតែមានអានុភាពដោយគ្រាន់តែត្រូវកាត់ចំណែកដែលបានបំពាន ឱ្យទៅអ្នកមានសិទ្ធិលើភាគបម្រុងទៅតាមចំណែករបស់ពួកគេប៉ុណ្ណោះ វាមិនរារាំងដល់ការបង្កើតអានុភាពរបស់មតកសាសន៍នោះទេ មិនតែប៉ុណ្ណោះផ្អែកលើគោលការណ៍សេរីភាពនៃឆន្ទៈតាមរយៈរបបមតកសាសន៍ មតកជនអាចសម្តែងនូវឆន្ទៈរបស់ខ្លួនដោយសេរីក្នុងការផ្ទេរសិទ្ធិចំពោះទ្រព្យសម្បត្តិរបស់ខ្លួនទៅឲ្យជនដែលមិនមែនជាសន្តតិជនតាមរយៈមតកសាសន៍ នៅក្នុងរូបភាពជាការធ្វើអច្ច័យទានដែលនឹងបង្កើតអានុភាពជាមួយគ្នានឹងមតកសាសន៍ដែរ លើកលែងតែមានលក្ខខណ្ឌបង្អង់ដោយឡែក។

លើសពីនេះ បន្ទាប់ពីមតកសាសន៍មួយបានរួចរាល់ មតកជននៅតែរក្សាសិទ្ធិក្នុងការលុប ឬកែប្រែក្នុងចំណុចផ្សេងៗទៅតាមឆន្ទៈរបស់ខ្លួនបាដោយនពុំមានលក្ខខណ្ឌហាមឃាត់ឡើយ ហើយបន្ទាប់ពីការបង្កើតអានុភាពនៃមតកសាសន៍ បុគ្គលដែលមានតួនាទី និងជនដែលមានផលប្រយោជន៍ពាក់ព័ន្ធត្រូវប្រតិបត្តកិច្ចនីតិវិធីមួយចំនួនដើម្បីក្លាយជាកម្មសិទ្ធិករនៃចលនវត្ថុ និងអចលនវត្ថុ ដែលជាកម្មវត្ថុនៃមតកសាសន៍។

សរុបសេចក្តីមក ដើម្បីឱ្យមតកសាសន៍មួយត្រូវបានទទួលស្គាល់ដោយច្បាប់មតកជនត្រូវដឹងអំពីការបង្កើតឡើង និងលក្ខខណ្ឌសុពលភាពឱ្យបានត្រឹមត្រូវដើម្បីចៀសវាងចំពោះបញ្ហានានាបន្ទាប់ពីវាបង្កើតអានុភាព។ ដូច្នេះបុគ្គលគ្រប់រូបដែលមានបំណងធ្វើការបែងចែកទ្រព្យសម្បត្តិតាមបណ្តាំត្រូវស្វែងយល់ពីនីតិវិធីក្នុងការបង្កើត ដើម្បីឱ្យមានប្រសិទ្ធអាចប្រើប្រាស់ត្រឹមត្រូវតាមច្បាប់។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវ និងចងក្រងសារណារួចមកបានឱ្យឃើញថា ការប្រើប្រាស់វិធីនៃការបែងចែកមត៌កតាមរយៈបណ្តាំនៅក្នុងសង្គមកម្ពុជានៅមានកម្រិតតិច បើប្រៀបទៅនឹង ការបែងចែកមត៌កតាមបញ្ញត្តិច្បាប់ ដោយសារផ្នត់គំនិតរបស់ប្រជាជនយើងមិនចង់ឱ្យមានលក្ខណៈស្មុគស្មាញជាមុន រហូតដល់ពេលវេលាទុកឱ្យក្លាយជាសមត្ថកិច្ចរបស់តុលាការសម្រេចបែងចែកទៅតាមច្បាប់ទៅចុះ យ៉ាងណាកត្តាទាំងនោះក៏ជាសេរីភាពនៃការប្រើប្រាស់សិទ្ធិរបស់ប្រជាពលរដ្ឋ ម្យ៉ាងក៏ព្រោះមូលដ្ឋានចំណេះដឹងពាក់ព័ន្ធនឹងច្បាប់របស់ប្រជាជនយើងនៅមានកម្រិត ដូច្នេះការស្វែងយល់អំពីនីតិវិធីនៃការធ្វើមតកសាសន៍ហាក់មានភាពស្មុគស្មាញសម្រាប់ពួកគាត់ និងត្រូវចំណាយចំពោះសោហ៊ុយនានា ដូចជាការពិគ្រោះអំពីវិធី ចំណាយចំពោះសារការី សោហ៊ុយការតម្កល់រក្សាលិខិត សោហ៊ុយសម្រាប់អ្នកប្រតិបត្តិ ការដាក់ពាក្យសុំត្រួតពិនិត្យ ជាអាទិ៍ ទន្ទឹងនឹងនេះក៏ពុំមានការផ្សព្វផ្សាយ ពន្យល់ បកស្រាយបានទូលំទូលាយផងនោះ វាជាមូលហេតុដែលបញ្ញត្តិអំពីសន្តតិកម្មតាមបណ្តាំមានបទប្បញ្ញត្តិជាច្រើនតែពុំសូវបានជួបប្រទះ និងលើកយកមកអនុវត្តន៍ឲ្យបានសកម្មទេ។

ដោយសារតែការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមានកម្រិត ព្រមទាំងពុំសូវទទួលបានការផ្សព្វផ្សាយ ឬឯកសារច្បាប់ដែលព័ន្ធ ទើបក្រុមយើងខ្ញុំ សូមចូលរួមនូវការផ្តល់មតិយោបល់មួយចំនួនក្នុងគោលបំណងជួយអភិវឌ្ឍន៍សង្គមជាតិ និង កែតម្រូវចំណុចមួយចំនួនដូចជា៖

- រាជរដ្ឋាភិបាល គប្បីធ្វើការផ្សព្វផ្សាយជាសាធារណៈតាមបណ្តាញសង្គមផ្សេងៗដូចជា ទូរទស្សន៍ វិទ្យុ ការសែត ទស្សនាវត្តី បណ្តាញសង្គមInternet ការបង្កើតមាតិកាដើម្បីណែនាំតាមរូបភាពផ្សេងៗ ឬការចាត់តាំងមន្ត្រីដែលមានជំនាញដើម្បីបណ្តុះបណ្តាលដល់មូលដ្ឋាននានា ក្នុងគោលបំណងឲ្យប្រជាជនមានចំណេះដឹងផ្នែកច្បាប់ព្រមទាំង បញ្ជ្រាបដល់ចំណាប់អារម្មណ៍ប្រជាជនពីផលប្រយោជន៍ និងនីតិវិធីនៃការធ្វើមតកសាសន៍ជាដើម។
- ប្រជាពលរដ្ឋត្រូវចូលរួមគោរព និងសិក្សាស្វែងយល់អំពីច្បាប់ មិនចំពោះតែចំណុចដែលពាក់ព័ន្ធនឹងប្រធានបទយើងនោះទេ សូមស្វែងយល់អំពីទ្រឹស្តីច្បាប់ទូទៅនានាផង ព្រោះការដែលប្រទេសមួយឈរលើមូលដ្ឋានច្បាប់នឹងដឹកនាំឲ្យប្រទេសជាតិមួយមានសន្តិសុខ សន្តិភាពសង្គម មិនបង្កឲ្យមានស្ថានភាពដែលអសណ្តាប់ធ្នាប់រំខានដល់ការរស់នៅ។ ម្យ៉ាងដើម្បីបង្កើនចំណេះដឹងដល់ប្រជាជនទូទៅយើងជាអ្នកដែលបានសិក្សា និងឈ្វេងយល់គប្បីមានឆន្ទៈក្នុងការចែករំលែកចំណេះដឹងរវាងគ្នា ដើម្បីជាផលប្រយោជន៍រួមមួយសម្រាប់សង្គមជាតិយើងនាពេលបច្ចុប្បន្ន និងអនាគត។

# ឯកសារយោង

# ឯកសារយោង


**១. បទដ្ឋានគតិយុត្ត**

១.១. ក្រម

-ក្រមរដ្ឋប្បវេណី ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

១.២. ច្បាប់

-ច្បាប់ស្តីពី នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១០/០១៣ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១០

**២. វចនានុក្រម**

២.១. វចនានុក្រមខ្មែរ ទម្រង់អេឡិចត្រូនិច របស់សម្តេចព្រះសង្ឃរាជ ជួន ណាត Version១.២.២

**៣. សន្ទានុក្រម**

៣.១. សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី ដែលត្រូវបានរៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះពុម្ពដោយទីស្តីការគណៈរដ្ឋមន្ត្រី នៅឆ្នាំ២០០៧

**៤. សៀវភៅ**

៤.១. សៀវភៅស្តីពី សេចក្តីកំណត់មាត្រានីមួយៗ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៩ របស់ក្រសួងយុត្តិធម៌ (គន្ថី៨-គន្ថី៩)

៤.២. សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ដោយក្រុមការងារនៃគ្រូបង្គោលនៅសាលាភូមិន្ទចៅក្រម, កែសម្រួលលើការបោះពុម្ពលើកទី១,ខែមីនា ឆ្នាំ២០១៧

៤.៣. សៀវភៅសិក្សា នីតិបេតិកភណ្ឌគ្រួសារ របស់លោកស្រី ស្រី វណ្ណធី ឆ្នាំសិក្សា២០២២-២០២៣

**៥. ឯកសារតាមរយៈការធ្វើបទបង្ហាញ សិក្ខាសាលា និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ៖**

៥.១. ឯកសារ របស់សាលាដំបូងរាជធានីភ្នំពេញបទបង្ហាញស្តីពីសន្តតិកម្មII SHINODA Yoichiro Attorney at Law (Japan) https://www.jica.go.jp/Resource/project/english/cambodia/025/materials/c8h0vm0000c54sbn-att/code_08_02.pdf

៥.២. ស្លាយបង្រៀន ស្តីពីមតកសាសន៍ ឧទ្ទេសនាមដោយ លោកមេធាវី អ៊ីវ ប៉ូលី លោកស្រីមេធាវី ទេព បូផល, ថ្ងៃ២២ ខែតុលា ឆ្នាំ២០១៧

៥.៣. ស្លាយបង្រៀន វគ្គបណ្តុះបណ្តាលជំនាន់ទី៧ ស្តីពីសន្តតិកម្មតាមមតកសាសន៍៖ ទិដ្ឋភាពទូទៅ ឧទ្ទេសនាមដោយ លោកស្រីមេធាវី ទេព បូផល

៥.៤. ស្លាយបង្រៀន វគ្គបណ្តុះបណ្តាលជំនាន់ទី៧ ស្តីពីលក្ខខណ្ឌបង្កើតកិច្ចសន្យា ឧទ្ទេសនាមដោយ លោកស្រី មេធាវី ឈុំ មុនីសុជាតា

៥.៥. ស្លាយបង្រៀន នីតិមរតក លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត មេរៀនទី៦ "មតកសាសន៍" រៀបរៀង ដោយ លោក រុន ពណ្ណារិទ្ធ និង លោកស្រី ចាំង ស៊ីណាត

៥.៦. https://sinchanphalkun.wordpress.com/2016/04/13/**មេរៀនសង្ខេបនីតិមរតក-លោក**/

# ឧបសម្ព័ន្ធ

# បញ្ជីរាយនាមឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ ១៖ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ឧបសម្ព័ន្ធ ២៖ សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ៣

ឧបសម្ព័ន្ធ ៣៖ គំរូលិខិតបណ្តាំមត៌កជាលិខិតឯកជន

ឧបសម្ព័ន្ធ ៤៖ ទម្រង់មតកសាសន៍ជាលិខិតយថាភូត

# ឧបសម្ព័ន្ធ ១៖
# ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា
# ឆ្នាំ២០០៧

ពិចារណាទៅលើពេល វិធី និង កម្រិតនៃវិភាគទាននោះ ចំនួនទឹកប្រាក់នៃមត៌ក និង ស្ថានភាពទាំងអស់ផ្សេងទៀត ។

៣-ភាគនៃវិភាគទាន មិនអាចឱ្យលើសពីចំនួនទឹកប្រាក់ដែលបានដកចេញនូវតម្លៃនៃអច្ច័យទាន និង តម្លៃនៃទ្រព្យសម្បត្តិ ដែលមតកជនបានកំណត់ថាជាចំណែកមត៌ករបស់សហសន្តតិជន ឬ ជាវិធីបែងចែកមត៌ក ពីចំនួនតម្លៃនៃមត៌ក ដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្មឡើយ ។

៤-ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ អាចធ្វើបានក្នុងករណីដែលមានពាក្យសុំ ដោយយោងតាមកថាខណ្ឌទី ១ នៃមាត្រា ១២៧០ (ការបែងចែកដោយតុលាការ) ឬ មានពាក្យបណ្តឹង ដោយយោងតាមមាត្រា ១២៧៤ (ការទាមទាររបស់ជនដែលត្រូវបានទទួលស្គាល់ក្រោយការបែងចែកមត៌ក) ។

**មាត្រា ១១៦៧.-** ទំនាក់ទំនងជាមួយនឹងតតិយជន

ការសម្រួលចំណែកមត៌កដែលយោងតាមបញ្ញត្តិនៃផ្នែកទី ៣ (ការសម្រួលចំណែកមត៌ក) នេះ មិនអាចយកមកអះអាងនឹងតតិយជនបានឡើយ បើមិនមានល័ក្ខខ័ណ្ឌតតាំងចំពោះលទ្ធផលនៃការបែងចែកមត៌ក ដោយផ្អែកលើការសម្រួលនោះទេ ។

## ជំពូកទី ៣

## សន្តតិកម្មតាមមតកសាសន៍

### ផ្នែកទី ១

### សមត្ថភាពក្នុងការធ្វើមតកសាសន៍

**មាត្រា ១១៦៨.-** បុគ្គលដែលអាចធ្វើមតកសាសន៍បាន

១-បុគ្គលដែលជានីតិជន និង អនីតិជនដែលបានអត្តាធីនភាពរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬ អំណាចមេបា អាចធ្វើមតកសាសន៍បាន ។

២-បញ្ញត្តិនៃមាត្រា ២៦ (សិទ្ធិលុបចោលសកម្មភាព) និង មាត្រា ៣០ (សិទ្ធិលុប

បោលសកម្មភាព) នៃក្រមនេះ មិនត្រូវយកមកអនុវត្តចំពោះមតកសាសន៍ឡើយ ។

**មាត្រា ១១៦៩.–** សមត្ថភាពនាពេលធ្វើមតកសាសន៍

១-ម្ចាស់បណ្តាំ ត្រូវមានសមត្ថភាព នៅពេលធ្វើមតកសាសន៍ ។

២-បុគ្គលដែលអះអាងអំពីការខ្វះសមត្ថភាពរបស់ម្ចាស់បណ្តាំ ត្រូវបញ្ជាក់ភស្តុតាងអំពីហេតុនោះ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបានកំណត់នៅក្នុងមាត្រា ១១៧៦ (មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

## ផ្នែកទី ២
## ទម្រង់នៃមតកសាសន៍

**មាត្រា ១១៧០.–** ភាពចាំបាច់នៃទម្រង់មតកសាសន៍

១-មតកសាសន៍ ពុំអាចធ្វើបានឡើយ បើពុំផ្អែកតាមទម្រង់ដែលបានកំណត់ក្នុងក្រមនេះទេ ។

២-មតកសាសន៍ដែលធ្វើមិនត្រូវនឹងទម្រង់ណាមួយក្នុងបញ្ញត្តិនៃក្រមនេះ ត្រូវចាត់ទុកជាមោឃៈ ។ ប៉ុន្តែ មតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ ត្រូវចាត់ទុកថាមានសុពលភាព លុះត្រាតែមតកសាសន៍នោះ មិនផ្ទុយនឹងមតកសាសន៍ផ្សេងទៀតដែលបានធ្វើដោយម្ចាស់បណ្តាំដូចគ្នានេះ ។ នៅក្នុងករណីដែលមតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ មានចំនួនច្រើន ហើយបើមតកសាសន៍ទាំងនេះ ផ្ទុយនឹងគ្នា អានុភាពនៃមតកសាសន៍ទាំងនោះត្រូវកាត់បន្ថយគ្នាទៅវិញទៅមក ។

**មាត្រា ១១៧១.–** សុពលភាពនៃទម្រង់

មតកសាសន៍ដែលត្រូវនឹងទម្រង់ណាមួយដែលបានកំណត់នៅក្នុងក្រមនេះ ត្រូវចាត់ទុកថាមានសុពលភាពចំពោះទម្រង់ ។

**មាត្រា ១១៧២.–** បុគ្គលដែលមិនអាចក្លាយជាសាក្សី ជាអាទិ៍

បុគ្គលដែលកំណត់ដូចខាងក្រោមនេះ មិនអាចធ្វើជាសាក្សី ឬ ជាអ្នកសង្កេតការណ៍នៅពេលធ្វើមតកសាសន៍បានឡើយ :

ក-អនីតិជន ឬ ជននៅក្រោមអាណាព្យាបាលធម្មតា ។

ខ-ជនដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី ហើយនិងសហព័ទ្ធ និង ញាតិលោហិតខ្សែផ្ទាល់ របស់ជនទាំងនោះ ។

គ-បើសារការីជាអ្នកពាក់ព័ន្ធក្នុងការធ្វើមតកសាសន៍ជាលិខិតយថាភូត ឬ ជាលិខិតមតកសាសន៍សម្ងាត់ សហព័ទ្ធរបស់សារការី ញាតិលោហិតខ្សែផ្ទាល់ ក្រឡាបញ្ជី និង និយោជិត របស់សារការីនោះ ។

**មាត្រា ១១៧៣.–** មតកសាសន៍ដោយលិខិតយថាភូត

១-មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើឡើងដោយម្ចាស់បណ្ដាំ នៅចំពោះមុខសារការី តាមទម្រង់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងក្រោមនេះ ។

២-មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើឡើង ដោយយោងតាមទម្រង់ដូចខាងក្រោមនេះ :

ក-ត្រូវមានវត្តមានរបស់សាក្សីយ៉ាងតិច ២ (ពីរ) នាក់ ។

ខ-ម្ចាស់បណ្ដាំត្រូវប្រាប់ផ្ទាល់មាត់ នូវខ្លឹមសារនៃមតកសាសន៍ ចំពោះសារការី ។

គ-សារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្ដាំនោះ ជាលាយល័ក្ខណ៍អក្សរ ហើយត្រូវសូត្រឱ្យម្ចាស់បណ្ដាំ និង សាក្សីនោះស្ដាប់ ។

ឃ-បន្ទាប់ពីម្ចាស់បណ្ដាំ និង សាក្សី បានទទួលស្គាល់ថាកំណត់ជាលាយល័ក្ខណ៍អក្សរនោះត្រឹមត្រូវហើយ ជននីមួយៗនោះត្រូវធ្វើឱ្យមានភាពច្បាស់លាស់នៅលើឯកសារអំពីឈ្មោះ អាយុ និង លំនៅឋាន ហើយ ត្រូវចុះហត្ថលេខា រៀងៗខ្លួន ។ ប៉ុន្តែបើម្ចាស់បណ្ដាំ មិនអាចសរសេរអក្សរ ឬ មិនអាចចុះហត្ថលេខាបានទេ សារការីអាចជំនួសការសរសេរ និង ហត្ថលេខាដូចកំណត់ខាងលើនេះ ដោយសរសេរឈ្មោះ អាយុ និង លំនៅឋានរបស់ជននោះ ហើយត្រូវសរសេរបន្ថែមនូវហេតុនោះផង ។

ង-សាក្សីត្រូវសរសេរថ្ងៃខែឆ្នាំ ហើយត្រូវចុះហត្ថលេខា ។

**មាត្រា ១១៧៤.–** មតកសាសន៍ដោយលិខិតឯកជន

១-មតកសាសន៍ដោយលិខិតឯកជន ត្រូវធ្វើឡើង ដោយម្ចាស់បណ្តាំសរសេរពាក្យទាំងអស់ និង ចុះថ្ងៃខែឆ្នាំ ដោយខ្លួនឯង ហើយត្រូវចុះហត្ថលេខាលើលិខិតនោះ ។ មតក-សាសន៍ដោយលិខិតឯកជនដែលត្រូវបានសរសេរជំនួសដោយអ្នកដទៃ ឬ ដែលត្រូវបានសរសេរដោយប្រើម៉ាស៊ីនដូចជាអង្គុលីលេខ ជាអាទិ៍ នឹងត្រូវចាត់ទុកជាមោឃៈ ។

២-ការបន្ថែម ការលុប ឬ ការកែប្រែផ្សេងទៀត នៅក្នុងមតកសាសន៍ដោយលិខិតឯកជន ពុំមានអានុភាពឡើយ បើម្ចាស់បណ្តាំមិនបានបង្ហាញនូវកន្លែង ហើយសរសេរបន្ថែមនូវហេតុនៃការកែប្រែនោះ ជាពិសេសបើមិនបានចុះហត្ថលេខាទេ ។

**មាត្រា ១១៧៥.–** មតកសាសន៍ដោយលិខិតសម្ងាត់

មតកសាសន៍ដោយលិខិតសម្ងាត់ ត្រូវធ្វើឡើង ដោយយោងតាមទម្រង់ដូចខាងក្រោមនេះ :

ក-ម្ចាស់បណ្តាំត្រូវចុះហត្ថលេខាលើលិខិតនោះ ។

ខ-ម្ចាស់បណ្តាំត្រូវដាក់លិខិតនោះក្នុងស្រោមបិទជិត ហើយត្រូវចុះហត្ថលេខា ឬ សរសេរសញ្ញាសំគាល់ ឬ មធ្យោបាយផ្សេងទៀតដែលអាចវិនិច្ឆ័យបានអំពីការបានបើក ឬ មិនបានបើកស្រោមលិខិតនោះ នៅមាត់ស្រោមលិខិតនោះ ។

គ-ម្ចាស់បណ្តាំត្រូវដាក់លិខិតដែលបានបិទជិតនោះ នៅចំពោះមុខសារការីម្នាក់ និង សាក្សី ២ (ពីរ) នាក់ និង ធ្វើសេចក្តីថ្លែងការណ៍ថា លិខិតនេះជាលិខិតមតកសាសន៍របស់ខ្លួន ហើយបើមានជនក្រៅពីសាមីខ្លួនបានសរសេរ ត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីឈ្មោះ និង លំនៅឋានរបស់ជនដែលបានសរសេរនោះ ។

ឃ-សារការីត្រូវចុះថ្ងៃខែឆ្នាំដែលសាមីខ្លួនបានដាក់លិខិតនោះ និង សរសេរសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តាំ នៅលើលិខិតដែលបិទជិតនោះ ហើយត្រូវចុះហត្ថ-លេខាលើលិខិតនោះ ជាមួយគ្នានឹងសាក្សី និង ម្ចាស់បណ្តាំ ។

**មាត្រា ១១៧៦.–** មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ

១-ដើម្បីធ្វើមតកសាសន៍ នៅពេលដែលជននៅក្រោមអាណាព្យាបាលទូទៅ បានសះស្បើយមួយរយៈឡើងវិញ នូវសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ត្រូវមានវត្តមានរបស់វេជ្ជបណ្ឌិត យ៉ាងតិច ២ (ពីរ) នាក់ ។

២-វេជ្ជបណ្ឌិតដែលមានវត្តមាននៅពេលធ្វើមតកសាសន៍ ត្រូវសរសេរបញ្ជាក់បន្ថែមលើលិខិតមតកសាសន៍នោះថា នៅពេលដែលម្ចាស់បណ្ដាំបានធ្វើមតកសាសន៍នោះ ម្ចាស់បណ្ដាំពុំបានស្ថិតក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិស្មារតីទេ ហើយត្រូវចុះហត្ថលេខាដោយបញ្ជាក់ថា ខ្លួនជាវេជ្ជបណ្ឌិតផងដែរ ។

**មាត្រា ១១៧៧.–** មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត

១-ប្រសិនបើជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ដោយសារជម្ងឺ ឬ ហេតុផ្សេងទៀត មានបំណងចង់ធ្វើមតកសាសន៍ មតកសាសន៍នេះអាចធ្វើបានដោយតម្រូវឱ្យមានវត្តមានរបស់សាក្សីយ៉ាងតិច ៣ (បី) នាក់ ហើយដោយប្រកាសខ្លឹមសារនៃមតកសាសន៍នោះ ដោយផ្ទាល់មាត់ ចំពោះជនម្នាក់ ក្នុងចំណោមសាក្សីនោះ ។ នៅក្នុងករណីនេះ ជនដែលបានទទួលការប្រកាសដោយផ្ទាល់មាត់នោះ ត្រូវសរសេរជាលាយល័ក្ខណ៍អក្សរ ហើយអានឱ្យសាក្សីស្ដាប់ ឬ ឱ្យមើល ហើយនៅក្រោយពេលដែលសាក្សីនីមួយៗបានទទួលស្គាល់ថាការសរសេរនោះត្រឹមត្រូវហើយ សាក្សីនីមួយៗនោះ ត្រូវចុះហត្ថលេខាលើលិខិតនោះ ។

២-មតកសាសន៍ដែលបានធ្វើតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ បើសាក្សីណាម្នាក់ ឬ បុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ពុំបានដាក់ពាក្យសុំទៅតុលាការ នៅក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានធ្វើមតកសាសន៍នោះ ហើយពុំបានទទួលការបញ្ជាក់ទេ ។

៣-តុលាការមិនអាចធ្វើការបញ្ជាក់មតកសាសន៍បានឡើយ ប្រសិនបើពុំមានជំនឿ

ទុកចិត្តថាមតកសាសន៍នោះ ចេញពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ ។

**មាត្រា ១១៧៨.-** មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង ជាអាទិ៍

១-បុគ្គលដែលជាប់ឃុំឃាំងនៅទីកន្លែងដាច់ដោយឡែក ដោយសាលក្រម ឬ សាលដីកា ឬ ដោយសារការចាត់ចែងផ្នែករដ្ឋបាល អាចធ្វើលិខិតមតកសាសន៍បាន ដោយត្រូវឱ្យមានវត្តមានរបស់នគរបាល ឬ មន្ត្រីនៃមន្ទីរឃុំឃាំងម្នាក់ និង សាក្សី យ៉ាងតិច ២ (ពីរ) នាក់ ។

២-បុគ្គលដែលនៅក្នុងនាវា ឬ យន្តហោះ អាចធ្វើលិខិតមតកសាសន៍បាន ដោយត្រូវឱ្យមានវត្តមានមេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះម្នាក់ និង សាក្សីយ៉ាងតិច ២ (ពីរ) នាក់ ។

៣-នៅពេលធ្វើមតកសាសន៍ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍ ដោយផ្ទាល់មាត់ ចំពោះនគរបាល មន្ត្រីនៃមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះបាន ។

៤-បញ្ញត្តិពីចំណុច ខ ដល់ចំណុច ង កថាខណ្ឌទី ២ នៃមាត្រា ១១៧៣ (មតក-សាសន៍ដោយលិខិតយថាភូត) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ។ ក្នុងករណីនេះ ពាក្យ សារការីត្រូវបានបកស្រាយថាជា នគរបាល មន្ត្រីនៃមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះ ។

៥-មតកសាសន៍ដែលត្រូវបានធ្វើឡើង ដោយយោងតាមបញ្ញត្តិពីកថាខណ្ឌទី ១ ដល់កថាខណ្ឌទី ៤ ខាងលើនេះ ពុំមានអានុភាពឡើយ បើម្ចាស់បណ្តាំបន្តនៅរស់ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីពេលដែលម្ចាស់បណ្តាំនោះ បែរជាអាចធ្វើមតកសាសន៍បាន តាមទម្រង់ណាមួយដែលបានកំណត់ចាប់ពីមាត្រា ១១៧៣ (មតកសាសន៍ដោយលិខិតយថាភូត) ដល់មាត្រា ១១៧៥ (មតកសាសន៍ដោយលិខិតសម្ងាត់) នៃក្រមនេះ ក្រោយពេលខ្លួនត្រូវបានដោះលែងពីមន្ទីរឃុំឃាំង ឬ ចុះពីនាវា ឬ យន្តហោះ ។

**មាត្រា ១១៧៩.-** ការធ្វើមតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន ជាអាទិ៍

១-នៅក្នុងករណីដែលបុគ្គលមិនអាចនិយាយបាន ធ្វើមតកសាសន៍តាមទម្រង់ដែលបានកំណត់នៅក្នុងមាត្រា ១១៧៣ (មតកសាសន៍ដោយលិខិតយថាភូត) មាត្រា ១១៧៥ (មតកសាសន៍ដោយលិខិតសម្ងាត់) មាត្រា ១១៧៧ (មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត) នៃក្រមនេះ ម្ចាស់បណ្តាំនោះអាចជំនួសការប្រាប់បាន ដោយធ្វើសេចក្តីថ្លែងការណ៍អំពីខ្លឹមសារនៃមតកសាសន៍ ឬ សេចក្តីថ្លែងការណ៍ថាលិខិតនោះជាលិខិតមតកសាសន៍ តាមការបកប្រែរបស់អ្នកបកប្រែ ឬ សរសេរដោយដៃខ្លួនផ្ទាល់ នៅចំពោះមុខសារការី ឬ សាក្សី ។

២-ក្នុងករណីដែលសារការី ឬ បុគ្គលផ្សេងទៀតដែលបានកំណត់នៅក្នុងក្រមនេះ ត្រូវអានឱ្យម្ចាស់បណ្តាំ ឬ សាក្សី ស្តាប់នូវអត្ថន័យនៃមតកសាសន៍ ក្រោយពេលបានសរសេរជាលាយល័ក្ខណ៍អក្សរនូវខ្លឹមសារនៃមតកសាសន៍នោះ បើម្ចាស់បណ្តាំ និង សាក្សីនោះ បែរជាមនុស្សថ្លង់មិនអាចស្តាប់បានទេ សារការី ឬ បុគ្គលផ្សេងទៀតដែលត្រូវបានកំណត់នៅក្នុងក្រមនេះ អាចជំនួសការអានឱ្យស្តាប់បាន ដោយប្រាប់អំពីអត្ថន័យដែលខ្លួនបានសរសេរនោះ តាមការបកប្រែរបស់អ្នកបកប្រែ ទៅម្ចាស់បណ្តាំ ឬ សាក្សីនោះ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ សារការី ឬ បុគ្គលផ្សេងទៀតដែលបានកំណត់នៅក្នុងក្រមនេះ ត្រូវសរសេរអំពីហេតុនោះចូលទៅក្នុងលិខិតនោះ ។

**មាត្រា ១១៨០.-** ការសរសេរនាមត្រកូល និង នាមខ្លួន និង ការផ្តិតម្រាមដៃ ជំនួសឱ្យការចុះហត្ថលេខា

ក្នុងករណីដែលសារការី និង សាក្សី ត្រូវចុះហត្ថលេខា សារការី និង សាក្សី គ្រាន់តែសរសេរនាមត្រកូល និង នាមខ្លួន និង ផ្តិតម្រាមដៃ ជាការគ្រប់គ្រាន់ហើយ ។

**មាត្រា ១១៨១.-** បទប្បញ្ញត្តិពិសេសចំពោះមតកសាសន៍របស់ជនជាតិខ្មែរដែលរស់នៅបរទេស

បើជនជាតិខ្មែរមានបំណងចង់ធ្វើមតកសាសន៍ដោយលិខិតយថាភូត ឬ លិខិត

សម្ងាត់ នៅកន្លែងដែលមានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅ កុងស៊ុលនោះត្រូវអនុវត្តមុខនាទីរបស់សារការី ។

## ផ្នែកទី ៣
## ចំណុចនៃមតកសាសន៍

**មាត្រា ១១៨២.–** ការកំណត់ចំណែកមត៌ក

១-មតកជនអាចកំណត់ចំណែកមត៌ករបស់សហសន្តតិជនតាមមតកសាសន៍ ឬ អាចបង្ហាញឆន្ទៈផ្ទុយពីបញ្ញត្តិនៃមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) នៃក្រមនេះ ស្តីពីចំណែកមត៌ករបស់បុគ្គលដែលបានទទួលផលប្រយោជន៍ពិសេសបាន ។ ប៉ុន្តែ ការកំណត់ចំណែកមត៌កដែលបំពានភាគបម្រុង ត្រូវអនុលោមតាមបញ្ញត្តិស្តីពីភាគបម្រុង ។

២-បើមតកជនបានកំណត់ចំណែកមត៌ក ចំពោះសន្តតិជនតែម្នាក់ ឬ ច្រើននាក់ក្នុងចំណោមសហសន្តតិជនទាំងអស់ ចំណែកមត៌ករបស់សហសន្តតិជនផ្សេងទៀត ត្រូវកំណត់ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ៣ (ការសម្រួលចំណែកមត៌ក) ជំពូកទី ២ ។

**មាត្រា ១១៨៣.–** ការកំណត់នូវវិធីបែងចែកដោយមតកសាសន៍ ជាអាទិ៍

មតកជន អាចកំណត់នូវវិធីបែងចែកតាមមតកសាសន៍ ឬ អាចប្រគល់អាណត្តិឱ្យតតិយជនកំណត់វិធីនោះ ឬ អាចហាមឃាត់មិនឱ្យបែងចែកនៅក្នុងអំឡុងពេលដែលមិនលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្មនោះ បាន ។

**មាត្រា ១១៨៤.–** អនុប្បទានទ្រព្យសម្បត្តិ

ម្ចាស់បណ្តាំអាចធ្វើប្រទានកម្មនូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែក ឬ អាចធ្វើប្រទានកម្មដោយមតកសាសន៍ តាមវិធីដែលបានកំណត់នៅក្នុងមាត្រា ១១៩៩ (និយមន័យនៃអច្ច័យទាន) នៃក្រមនេះបាន នៅក្នុងល័ក្ខខ័ណ្ឌដែលអនុលោមតាមបញ្ញត្តិស្តីពីភាគបម្រុង ។

**មាត្រា ១១៨៥.–** អនុប្បទានទ្រព្យសម្បត្តិចំពោះសន្តតិជន

១-បើមតកជនបានធ្វើមតកសាសន៍ដែលមានអត្ថន័យជាការធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬ ច្រើន ឱ្យទៅសហសន្តតិជនតែម្នាក់ ឬ ច្រើននាក់ មតក-សាសន៍នោះត្រូវបានសន្មតថាបានកំណត់នូវវិធីបែងចែកមត៌ក លើកលែងតែនៅក្នុងករណីដែលមតកសាសន៍នោះមានអត្ថន័យជាអច្ច័យទានយ៉ាងច្បាស់លាស់ ដូចជាអច្ច័យទានដែលភ្ជាប់ជាមួយនឹងបន្ទុក ជាអាទិ៍ ហើយបើតម្លៃនៃទ្រព្យសម្បត្តិដែលបានកំណត់នោះ មានចំនួនលើសពីចំណែកមត៌ករបស់សន្តតិជន នោះត្រូវសន្មតថាបានកំណត់ចំណែកមត៌កផងដែរ ។

២-ក្នុងករណីដែលមតកជនបានធ្វើមតកសាសន៍ ចំពោះទ្រព្យសម្បត្តិតែមួយភាគនៅក្នុងចំណោមមត៌ក បើតម្លៃនៃទ្រព្យសម្បត្តិនោះ មានចំនួនតិចជាងចំណែកមត៌ក ដែលសន្តតិជននោះត្រូវទទួល លុះត្រាតែពុំមានការបង្ហាញឆន្ទៈផ្សេងទៀតនៅក្នុងមតកសាសន៍នោះ ត្រូវសន្មតថាបានកំណត់ត្រឹមតែវិធីបែងចែកមត៌កដែលត្រូវធ្លាក់ទៅលើសន្តតិជននោះតែប៉ុណ្ណោះ ។

**មាត្រា ១១៨៦.–** ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍

ម្ចាស់បណ្ដាំអាចកំណត់អ្នកប្រតិបត្តិមតកសាសន៍ម្នាក់ ឬ ច្រើននាក់ ឬ អាចប្រគល់អាណត្តិឱ្យតតិយជនកំណត់អ្នកប្រតិបត្តិនោះ តាមមតកសាសន៍បាន ។

**មាត្រា ១១៨៧.–** ចំណុចផ្សេងៗ

ក្រៅពីធ្វើមតកសាសន៍តាមចំណុចដែលបានកំណត់នៅក្នុងក្រមនេះ ម្ចាស់បណ្ដាំអាចធ្វើមតកសាសន៍ដោយផ្ដល់ដំបូន្មាន ឬ យោបល់ ដើម្បីឱ្យមានភាពសុខដុមរមនាដល់ក្រុមគ្រួសារ និង ចំណុចផ្សេងៗទៀតបាន ។ នៅក្នុងករណីនេះ សន្តតិជន ជាអាទិ៍ ត្រូវគោរពទៅតាមមតកសាសន៍នោះ ។

# ផ្នែកទី ៤
## ការលុបចោលនូវមតកសាសន៍

**មាត្រា ១១៨៨.–** ពេល និង ទម្រង់នៃការលុបចោលនូវមតកសាសន៍

ម្ចាស់បណ្ដាំអាចលុបចោលនូវមតកសាសន៍ មួយភាគ ឬ ទាំងមូល នៅពេលណាក៏បាន ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ៤ (ការលុបចោលនូវមតកសាសន៍) នេះ ។

**មាត្រា ១១៨៩.–** ការលុបចោលដោយទម្រង់នៃមតកសាសន៍

១-ម្ចាស់បណ្ដាំអាចលុបចោលនូវមតកសាសន៍ មួយភាគ ឬ ទាំងមូលបាន តាមទម្រង់នៃមតកសាសន៍ ។

២-បើមតកសាសន៍ដែលបានធ្វើក្រោយនេះ មានភាពផ្ទុយនឹងមតកសាសន៍ដែលបានធ្វើមុន ត្រូវចាត់ទុកថា មតកសាសន៍ដែលបានធ្វើក្រោយនោះ បានលុបចោលមតក-សាសន៍ដែលបានធ្វើមុន ចំពោះផ្នែកដែលផ្ទុយគ្នានោះ ។

**មាត្រា ១១៩០.–** ការលុបចោលមតកសាសន៍ ដោយការចាត់ចែងនាពេលនៅរស់

បើម្ចាស់បណ្ដាំ បានធ្វើអនុប្បទាន ឬ បានធ្វើសកម្មភាពផ្សេងទៀត ចំពោះវត្ថុដែលជាកម្មវត្ថុនៃមតកសាសន៍ នាពេលនៅរស់ ត្រូវចាត់ទុកថា ម្ចាស់បណ្ដាំបានលុបចោលមតកសាសន៍ ចំពោះផ្នែកដែលផ្ទុយនឹងអនុប្បទាន ឬ សកម្មភាពផ្សេងនោះ ។

**មាត្រា ១១៩១.–** ការលុបចោលដោយការបដិសេធលិខិតមតកសាសន៍ ជាអាទិ៍

បើម្ចាស់បណ្ដាំ បានបំផ្លាញច្បាប់ដើមនៃមតកសាសន៍ ដោយចេតនា ត្រូវចាត់ទុកថាបានលុបចោលមតកសាសន៍ ចំពោះផ្នែកដែលត្រូវបានបំផ្លាញនោះ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់បណ្ដាំបានបំផ្លាញវត្ថុ ដែលជាកម្មវត្ថុនៃមតកសាសន៍ ដោយចេតនា ។

**មាត្រា ១១៩២.–** ការបោះបង់សិទ្ធិលុបចោលមតកសាសន៍

ម្ចាស់បណ្ដាំមិនអាចបោះបង់សិទ្ធិលុបចោលមតកសាសន៍ បានឡើយ ។

**មាត្រា ១១៩៣.-** ការលុបចោលអច្ច័យទានដែលភ្ជាប់បន្ទុក

បើអច្ច័យលាភីពុំបានអនុវត្តករណីយកិច្ចដែលម្ចាស់បណ្តាំបានតម្រូវឱ្យអច្ច័យលាភីនោះទទួលបន្ទុកជាថ្នូរនឹងអច្ច័យទានទេ អ្នកប្រតិបត្តិមតកសាសន៍ ឬ បើគ្មានអ្នកប្រតិបត្តិមតកសាសន៍នោះទេ សន្តតិជនអាចដាស់តឿនឱ្យអច្ច័យលាភីនោះ អនុវត្តករណីយកិច្ចនោះ ដោយកំណត់អំឡុងពេលសមរម្យ ហើយប្រសិនបើអច្ច័យលាភីនោះ មិនបានអនុវត្តករណីយកិច្ច នៅក្នុងអំឡុងពេលនោះទេ អ្នកប្រតិបត្តិមតកសាសន៍ ឬ សន្តតិជននោះ អាចទាមទារទៅតុលាការ ឱ្យលុបចោលអច្ច័យទាននោះបាន ។

## ផ្នែកទី ៥
## អានុភាពនៃមតកសាសន៍

**មាត្រា ១១៩៤.-** ពេលដែលមតកសាសន៍បង្កើតអានុភាព

១-មតកសាសន៍ ត្រូវបង្កើតអានុភាព ចាប់ពីពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ។

២-នៅក្នុងករណីដែលមតកសាសន៍ ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ បើល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញនៅក្រោយពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព មតកសាសន៍នោះ ត្រូវមានអានុភាព ចាប់ពីពេលដែលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ ។

**មាត្រា ១១៩៥.-** អានុភាពនៃការកំណត់ចំណែកមត៌ក ជាអាទិ៍

១-បើមតកជនបានកំណត់ចំណែកមត៌ក ឬវិធីបែងចែកមត៌ក ដោយធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬ ច្រើន ឱ្យចំពោះសន្តតិជនតែម្នាក់ ឬ ច្រើននាក់ ដោយមតកសាសន៍ ទ្រព្យសម្បត្តិជាក់លាក់នោះ ត្រូវធ្លាក់ទៅសន្តតិជនដែលនឹងត្រូវទទួលទ្រព្យសម្បត្តិនោះ ដោយស្វ័យប្រវត្តិ ព្រមគ្នានឹងពេលមតកសាសន៍នោះបង្កើតអានុភាព ។

២-នៅក្នុងករណីដែលមតកសាសន៍ ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ បើល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញនៅក្រោយពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចាត់ទុកថា ត្រូវបានធ្លាក់ទៅ

សន្តតិជនដែលនឹងត្រូវទទួលទ្រព្យសម្បត្តិនោះ ដោយប្រតិសកម្ម គិតចាប់តាំងពីពេលដែលមតកជននោះ បានទទួលមរណភាព ។

**មាត្រា ១១៩៦.–** មរណភាពនៃជនដែលត្រូវបានសន្មតថាជាសន្តតិជន ជាអាទិ៍

១-នៅក្នុងករណីដែលមតកជនបានកំណត់ចំណែកមតិករបស់សន្តតិជន ឬ វិធីនៃការបែងចែកមតិក ដោយមតកសាសន៍ បើជនដែលត្រូវបានសន្មតថាជាសន្តតិជន បានទទួលមរណភាព នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬ បានបាត់បង់សិទ្ធិសន្តតិកម្ម ដោយត្រូវនឹងបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) នៃក្រមនេះ ឬ ដោយការកាត់កាល់សន្តតិជន ការកំណត់នោះត្រូវបានចាត់ទុកថា បានធ្វើចំពោះអ្នកទទួលសន្តតិកម្មជំនួសរបស់ជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើគ្មានអ្នកទទួលសន្តតិកម្មជំនួសជនដែលត្រូវបានសន្មតថាជាសន្តតិជននោះទេ ការកំណត់ចំពោះជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ ពុំត្រូវបង្កើតអានុភាពឡើយ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសន្តតិជនបានបោះបង់សន្តតិកម្ម ។

៣-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះក៏ដោយ បើមតកជនបានបង្ហាញឆន្ទៈផ្សេង ក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១១៩៧.–** ការកម្រិតនូវមតកសាសន៍ ចំពោះអ្នកអាណាព្យាបាល ជាអាទិ៍

១-បើជនដែលនៅក្រោមអាណាព្យាបាលទូទៅ បានធ្វើមតកសាសន៍ ដែលជាផលប្រយោជន៍ដល់អ្នកអាណាព្យាបាល ឬ សហព័ទ្ធ ឬ បច្ឆាញាតិផ្ទាល់របស់អ្នកអាណាព្យាបាលនោះ នៅមុនពេលបញ្ចប់ការគណនានូវចំណូលចំណាយក្នុងកិច្ចការអាណាព្យាបាល មតក-សាសន៍នោះត្រូវចាត់ទុកជាមោឃៈ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលញាតិលោហិតផ្ទាល់ សហព័ទ្ធ ឬ បងប្អូនបង្កើត ជាអ្នកអាណាព្យាបាលទូទៅ ។

**មាត្រា ១១៩៨.-** សិទ្ធិទទួលទ្រព្យសម្បត្តិ ក្នុងករណីដែលអច្ច័យទានមោឃៈ ជាអាទិ៍

បើអច្ច័យទានពុំបានបង្កើតអានុភាព ដោយសារអច្ច័យលាភីជាអភ័ព្វបុគ្គល ឬ ទទួលមរណភាព ឬ ដោយសារហេតុផ្សេងទៀត ឬ បើពុំបានបង្កើតអានុភាពដោយសារការបោះបង់ ទ្រព្យដែលអច្ច័យលាភីត្រូវទទួលនោះ ត្រូវធ្លាក់ទៅសន្តតិជនរបស់មតកជន ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

## ផ្នែកទី ៦
## អច្ច័យទាន

**មាត្រា ១១៩៩.-** និយមន័យនៃអច្ច័យទាន

អច្ច័យទានសកល គឺជាប្រទានកម្មដែលម្ចាស់បណ្តាំផ្ញើទៅឱ្យមនុស្សម្នាក់ ឬ ច្រើននាក់ នូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែកដែលកំណត់ទៅតាមភាគ រីឯអច្ច័យទានមានកំណត់ គឺជាប្រទានកម្មដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ ទៅឱ្យមនុស្សម្នាក់ ឬ ច្រើននាក់ ដោយមតកសាសន៍ ។

**មាត្រា ១២០០.-** មរណភាពរបស់អច្ច័យលាភី

១-អច្ច័យទាន ពុំបង្កើតអានុភាពឡើយ បើអច្ច័យលាភីបានទទួលមរណភាព នៅមុន ឬ ក្នុងពេលដែលម្ចាស់បណ្តាំទទួលមរណភាព ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអច្ច័យទានភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ ហើយអច្ច័យលាភីបានទទួលមរណភាព នៅមុនពេលដែលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

៣-ក្នុងករណីដែលសន្តតិជនដែលត្រូវបានសន្មត ជាអច្ច័យលាភី បញ្ញត្តិនៃកថា-ខណ្ឌទី ១ ខាងលើនេះ មិនរារាំងចំពោះការយកបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ១១៩៦ (មរណភាពនៃជនដែលត្រូវបានសន្មតថាជាសន្តតិជន ជាអាទិ៍) នៃក្រមនេះ មកអនុវត្តឡើយ ។

**មាត្រា ១២០១.–** ការបោះបង់អច្ច័យទាន

១-នៅក្រោយពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព អច្ច័យលាភីអាចបោះបង់អច្ច័យទាន នៅពេលណាក៏បាន ។ ប៉ុន្តែ ចំពោះការបោះបង់អច្ច័យទានសកល ត្រូវអនុលោមតាមបញ្ញត្តិស្ដីពីការបោះបង់សន្តតិកម្ម ។

២-ការបោះបង់អច្ច័យទាន ត្រូវមានអានុភាពប្រតិសកម្ម ចាប់ពីពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព ។

**មាត្រា ១២០២.–** ការដាស់តឿនរបស់ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍

បុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធទៅនឹងអច្ច័យទាន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ អាចដាស់តឿនឱ្យអច្ច័យលាភីទទួលស្គាល់ ឬ បោះបង់អច្ច័យទានបាន ដោយកំណត់អំឡុងពេលសមរម្យ ។ បើអច្ច័យលាភីមិនបានបង្ហាញឆន្ទៈ ចំពោះបុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធទៅនឹងអច្ច័យទាន នៅក្នុងអំឡុងពេលដែលបានកំណត់នោះទេ ត្រូវចាត់ទុកថា អច្ច័យលាភីបានទទួលស្គាល់អច្ច័យទាននោះ ។

**មាត្រា ១២០៣.–** ការបោះបង់ ឬ ការទទួលស្គាល់ ដោយសន្តតិជនរបស់អច្ច័យលាភី

បើអច្ច័យលាភីបានទទួលមរណភាព ដោយមិនបានទទួលស្គាល់ ឬ បោះបង់អច្ច័យទានទេ សន្តតិជនរបស់អច្ច័យលាភីនោះ អាចទទួលស្គាល់ ឬ បោះបង់អច្ច័យទានបាន ត្រឹមទំហំនៃសិទ្ធិលើសន្តតិកម្មរបស់ខ្លួន ។ ប៉ុន្តែ បើម្ចាស់បណ្ដាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១២០៤.–** ការលុបចោលនូវការទទួលស្គាល់ ឬ ការបោះបង់

១-ការទទួលស្គាល់ ឬ ការបោះបង់អច្ច័យទាន ពុំអាចលុបចោលវិញបានទេ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១២៥២ (ការលុបចោលការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការទទួលស្គាល់ និង ការបោះបង់អច្ច័យទាននេះ ។

**មាត្រា ១២០៥.–** ការទទួលស្គាល់ ឬ បោះបង់ ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន

១-ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន បើបានបោះបង់សន្តតិកម្ម បុគ្គលនោះត្រូវបានចាត់ទុកថាបានបោះបង់អច្ច័យទានផងដែរ ។ អច្ច័យលាភីនោះ មិនអាចទទួលស្គាល់អច្ច័យទាន ដោយបោះបង់សន្តតិកម្មបានឡើយ ។

២-ទោះបីបានទទួលស្គាល់សន្តតិកម្មហើយក៏ដោយ ក៏អច្ច័យលាភីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចបោះបង់អច្ច័យទានមានកំណត់ បានដែរ ។

**មាត្រា ១២០៦.–** សិទ្ធិទទួលផលរបស់អច្ច័យលាភី

អច្ច័យលាភីអាចទទួលផល ចាប់តាំងពីពេលដែលខ្លួនអាចទាមទារឱ្យអនុវត្តអច្ច័យ-ទានបាន ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសនី ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១២០៧.–** អច្ច័យទាននៃសិទ្ធិដែលមិនស្ថិតនៅក្នុងមតិក

អច្ច័យទាន ពុំមានអានុភាពឡើយ បើសិទ្ធិដែលជាកម្មវត្ថុនៃអច្ច័យទាននោះ ពុំស្ថិតនៅក្នុងមតិក នៅពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ។

**មាត្រា ១២០៨.–** អច្ច័យទាននៃវត្ថុ ឬ សិទ្ធិដែលភ្ជាប់ជាមួយនឹងសិទ្ធិរបស់តតិយជន

បើវត្ថុ ឬ សិទ្ធិ ដែលជាកម្មវត្ថុនៃអច្ច័យទាន ជាកម្មវត្ថុនៃសិទ្ធិរបស់តតិយជន នៅពេលដែលម្ចាស់បណ្តាំទទួលមរណភាព អច្ច័យលាភីមិនអាចទាមទារឱ្យរំលត់សិទ្ធិនោះចំពោះជនដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទានបានឡើយ ។

**មាត្រា ១២០៩.–** ឧបាទេសកម្មលើវត្ថុ

១-បើម្ចាស់បណ្តាំមានសិទ្ធិទាមទារប្រាក់សំណង ចំពោះតតិយជន ដោយការបាត់បង់ ឬ កែបន្លំវត្ថុដែលជាកម្មវត្ថុនៃអច្ច័យទាន ឬ បាត់បង់ការកាន់កាប់វត្ថុនោះ ត្រូវសន្មតថាបានយកសិទ្ធិនោះ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

២-ក្នុងករណីដែលវត្ថុដែលជាកម្មវត្ថុនៃអច្ច័យទាន មានភាពជាប់គ្នា លាយគ្នា ឬ

ប្រែបល់គ្នានឹងវត្ថុផ្សេងទៀត បើម្ចាស់បណ្ដាំបានក្លាយជាកម្មសិទ្ធិករតែឯង ឬ ជាម្ចាស់កម្មសិទ្ធិអវិភាគនៃវត្ថុដែលបានផ្សំ ដោយយោងតាមបញ្ញត្តិនៃមាត្រា ១៨៦ (ការជាប់គ្នារវាងចលនវត្ថុ និង អចលនវត្ថុ) ឬ មាត្រា ១៩៨ (ការជាប់គ្នា ការលាយប្រែបល់គ្នានៃចលនវត្ថុ) នៃក្រមនេះ ត្រូវសន្មតថា ម្ចាស់បណ្ដាំបានយកកម្មសិទ្ធិទាំងអស់ ឬ កម្មសិទ្ធិអវិភាគនោះ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

**មាត្រា ១២១០.-** ឧបាទេសកម្មលើវត្ថុ នៃអច្ច័យទាននៃសិទ្ធិលើបំណុល

១-ក្នុងករណីដែលសិទ្ធិលើបំណុលត្រូវបានយកមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន បើម្ចាស់បណ្ដាំបានទទួលសំណង ហើយបើវត្ថុដែលបានទទួលនោះ នៅតែមានក្នុងមតិក ត្រូវសន្មតថាបានយកវត្ថុនោះមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

២-ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ត្រូវសន្មតថាបានយកប្រាក់ និង ប្រាក់បញ្ញើ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ត្រឹមកម្រិតនៃប្រាក់ដែលមាននៅក្នុងមតិក និង ប្រាក់ដែលបានបញ្ចូលក្នុងប្រាក់បញ្ញើ ក្រោយពីបានសង ។

**មាត្រា ១២១១.-** ការទទួលខុសត្រូវរបស់អច្ច័យលាភី នៅក្នុងអច្ច័យទានភ្ជាប់បន្ទុក

១-ជនដែលបានទទួលអច្ច័យទានភ្ជាប់បន្ទុក ត្រូវទទួលខុសត្រូវក្នុងការអនុវត្តករណីយកិច្ចដែលខ្លួនទទួលបន្ទុក ត្រឹមតែកម្រិតដែលមិនលើសពីតម្លៃនៃកម្មវត្ថុនៃអច្ច័យទាននោះប៉ុណ្ណោះ ។

២-បើតម្លៃនៃកម្មវត្ថុនៃអច្ច័យទានភ្ជាប់បន្ទុក បានចុះថយ ដោយសារការទទួលស្គាល់សន្តតិកម្មដោយមានកម្រិត ឬ ដោយសារការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង អច្ច័យលាភីត្រូវរួចផុតពីករណីយកិច្ចដែលខ្លួនត្រូវទទួលបន្ទុក តាមសមាមាត្រនៃភាគដែលចុះថយនោះ ។ ប៉ុន្តែ បើម្ចាស់បណ្ដាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១២១២.-** សិទ្ធិ និង ករណីយកិច្ចរបស់អច្ច័យលាភីសកល

១-អច្ច័យលាភីសកល មានសិទ្ធិ និង ករណីយកិច្ច ដូចគ្នានឹងសន្តតិជន ។

២-បើមត៌កទាំងអស់ត្រូវបានធ្វើអច្ច័យទានសកលឱ្យទៅបុគ្គលផ្សេងដែលមិនមែនជាសន្តតិជន សន្តតិជនត្រូវបានចាត់ទុកថា មិនបានទទួលសន្តតិកម្ម លើកលែងតែសិទ្ធិលើភាគបម្រុង ។

## ផ្នែកទី ៧
## ការប្រតិបត្តិមតកសាសន៍

**មាត្រា ១២១៣.–** ការពិនិត្យបញ្ជាក់ និង ការបើកលិខិតមតកសាសន៍

១-អ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ ត្រូវដាក់ពាក្យសុំការបញ្ជាក់លិខិតនោះ ដោយភ្ជាប់លិខិតមតកសាសន៍នោះ ជូនទៅតុលាការ ដោយគ្មានការយឺតយ៉ាវ ក្រោយពីខ្លួនបានដឹងអំពីការចាប់ផ្ដើមសន្តតិកម្ម ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលគ្មានអ្នកថែរក្សាគ្រប់គ្រង ក្រោយពេលដែលសន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ផ្សេងទៀត បានរកឃើញលិខិតមតកសាសន៍នោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះមតកសាសន៍ដែលបានធ្វើដោយលិខិតយថាភូត ។

៣-លិខិតមតកសាសន៍ដែលបិទដោយប្រថាប់ត្រា អាចបើកបានតែនៅតុលាការ ដោយមានវត្តមានរបស់អ្នកសង្កេតការណ៍ជាសន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ ឬ អ្នកតំណាងរបស់ជននោះ ។

៤-បុគ្គលដែលបានបើកលិខិតមតកសាសន៍ នៅក្រៅតុលាការ ដោយផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ នឹងត្រូវពិន័យស៊ីវិលជាប្រាក់ មិនលើសពី ១.០០០.០០០ (មួយលាន) រៀល ។

៥-ចំពោះលិខិតមតកសាសន៍ ទោះបីជាបានបើកនៅក្រៅតុលាការ ដោយផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ក៏ដោយ មិនត្រូវបាត់បង់អានុភាព ដោយសារតែមូលហេតុនោះឡើយ ។

**មាត្រា ១២១៤.–** ការកំណត់អ្នកប្រតិបត្តិមតកសាសន៍

១-បើម្ចាស់បណ្ដាំបានប្រគល់អាណត្តិឱ្យតតិយជនកំណត់អ្នកប្រតិបត្តិមតកសាសន៍តាមមតកសាសន៍ ជនដែលបានទទួលអាណត្តិ ត្រូវកំណត់អ្នកប្រតិបត្តិមតកសាសន៍ ហើយត្រូវជូនដំណឹងនោះទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

២-បើជនដែលបានទទួលអាណត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មានបំណងលាឈប់ពីអាណត្តិនោះ ជននោះត្រូវជូនដំណឹងអំពីហេតុនោះ ទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

**មាត្រា ១២១៥.–** ការកាន់មុខងាររបស់អ្នកប្រតិបត្តិមតកសាសន៍

បើអ្នកប្រតិបត្តិមតកសាសន៍ បានយល់ព្រមកាន់មុខងារហើយ អ្នកប្រតិបត្តិមតក-សាសន៍នោះ ត្រូវអនុវត្តភារកិច្ចនោះ ភ្លាមៗ ។

**មាត្រា ១២១៦.–** ការដាស់តឿនឱ្យអ្នកប្រតិបត្តិមតកសាសន៍កាន់មុខងារ

១-សន្តតិជន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ផ្សេងទៀត អាចកំណត់អំឡុងពេលសមរម្យ ហើយដាស់តឿន ចំពោះជនដែលត្រូវបានកំណត់ជាអ្នកប្រតិបត្តិមតក-សាសន៍ ឱ្យឆ្លើយបញ្ជាក់ច្បាស់ក្នុងអំឡុងពេលនោះ អំពីការយល់ព្រម ឬ មិនយល់ព្រមកាន់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍បាន ។ បើអ្នកប្រតិបត្តិមតកសាសន៍ មិនបានឆ្លើយបញ្ជាក់ច្បាស់ ក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថា បានលាឈប់ពីការងារនោះ ។

២-បញ្ញត្តិនៃវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលតតិយជន ដែលត្រូវបានប្រគល់អាណត្តិឱ្យកំណត់អ្នកប្រតិបត្តិមតកសាសន៍ ពុំបានកំណត់អ្នកប្រតិបត្តិមតកសាសន៍ ឱ្យបានឆាប់រហ័ស ។ ក្នុងករណីនេះ បើតតិយជននោះមិនបានកំណត់អ្នកប្រតិបត្តិមតកសាសន៍ នៅក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថា បានលាឈប់ពីអាណត្តិនោះ ។

**មាត្រា ១២១៧.–** បុគ្គលដែលមិនអាចក្លាយជាអ្នកប្រតិបត្តិមតកសាសន៍

ជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិតូបត្ថម្ភ អនីតិជន និង ជន

ធនក្ស័យ ពុំអាចធ្វើជាអ្នកប្រតិបត្តិមតកសាសន៍បានឡើយ ។

**មាត្រា ១២១៨.–** ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍

បើគ្មានអ្នកប្រតិបត្តិមតកសាសន៍ទេ ឬ បើបាត់បង់អ្នកប្រតិបត្តិមតកសាសន៍ តុលាការអាចជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍បាន តាមការទាមទាររបស់សន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ ។

**មាត្រា ១២១៩.–** ការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ

១-អ្នកប្រតិបត្តិមតកសាសន៍ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ ហើយប្រគល់បញ្ជីសារពើភ័ណ្ឌនោះទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

២-សន្តតិជន អាចមានវត្តមាន នៅពេលដែលអ្នកប្រតិបត្តិមតកសាសន៍ ធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិបាន ។

**មាត្រា ១២២០.–** សិទ្ធិអំណាច មុខនាទី នៃអ្នកប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍ មានសិទ្ធិ និង ករណីយកិច្ចក្នុងការគ្រប់គ្រងមតិក និង ធ្វើនូវរាល់សកម្មភាពផ្សេងទៀតដែលចាំបាច់ ដើម្បីប្រតិបត្តិមតកសាសន៍ ។

**មាត្រា ១២២១.–** ការបាត់បង់នូវសិទ្ធិចាត់ចែងរបស់សន្តតិជន

១-បើមានអ្នកប្រតិបត្តិមតកសាសន៍ សន្តតិជនពុំអាចចាត់ចែងមតិក ឬ ធ្វើសកម្មភាពផ្សេងទៀតដែលនាំឱ្យរារាំងដល់ការប្រតិបត្តិមតកសាសន៍បានឡើយ ។

២-ការចាត់ចែងដែលបានធ្វើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ ។

**មាត្រា ១២២២.–** ការប្រតិបត្តិមតកសាសន៍ ចំពោះទ្រព្យសម្បត្តិដែលបានកំណត់ជាក់លាក់

ក្នុងករណីមតកសាសន៍ ទាក់ទងនឹងទ្រព្យសម្បត្តិដែលបានកំណត់ជាក់លាក់ បញ្ញត្តិចាប់ពីមាត្រា ១២១៩ (ការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ) រហូតដល់មាត្រា ១២២១

(ការបាត់បង់នូវសិទ្ធិចាត់ចែងរបស់សន្តតិជន) នៃក្រមនេះ ត្រូវយកមកអនុវត្ត ចំពោះតែទៅលើទ្រព្យសម្បត្តិនោះប៉ុណ្ណោះ ។

**មាត្រា ១២២៣.–** ឋានៈនៃអ្នកប្រតិបត្តិមតកសាសន៍

១-អ្នកប្រតិបត្តិមតកសាសន៍ ត្រូវធ្វើសកម្មភាព នៅក្នុងនាមជាអ្នកប្រតិបត្តិមតកសាសន៍ ចំពោះមតិកដែលខ្លួនត្រូវប្រតិបត្តិ ។

២-សកម្មភាពដែលអ្នកប្រតិបត្តិមតកសាសន៍បានធ្វើជាមុខនាទី ត្រូវមានអានុភាពផ្ទាល់ ចំពោះសន្តតិជន ។

**មាត្រា ១២២៤.–** សិទ្ធិជ្រើសតាំងបន្ត របស់អ្នកប្រតិបត្តិមតកសាសន៍

១-បើគ្មានមូលហេតុដែលពុំអាចជៀសវាងបានទេ អ្នកប្រតិបត្តិមតកសាសន៍ ពុំអាចឱ្យតតិយជនអនុវត្តភារកិច្ចរបស់ខ្លួនបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេង នៅក្នុងមតកសាសន៍ ។

២-ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍ បានឱ្យតតិយជនអនុវត្តភារកិច្ចរបស់ខ្លួន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អ្នកប្រតិបត្តិមតកសាសន៍នោះ ត្រូវទទួលខុសត្រូវក្នុងការជ្រើសតាំង និង ការត្រួតពិនិត្យជននោះ ចំពោះអច្ច័យលាភី និង សន្តតិជន ។ បើអ្នកប្រតិបត្តិមតកសាសន៍ បានឱ្យតតិយជនអនុវត្តភារកិច្ចនោះ ដោយផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសងសំណងនៃការខូចខាត ដែលកើតឡើងដោយសារហេតុនោះ ចំពោះអច្ច័យលាភី និង សន្តតិជន ។

**មាត្រា ១២២៥.–** សហអ្នកប្រតិបត្តិមតកសាសន៍

១-ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍មានច្រើននាក់ ការអនុវត្តភារកិច្ចនោះ ត្រូវសម្រេចដោយសម្លេងលើសពីពាក់កណ្តាល ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ អ្នកប្រតិបត្តិមតកសាសន៍នីមួយៗ អាចធ្វើសកម្មភាពរក្សាទុកបាន ។

**មាត្រា ១២២៦.-** កម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍

១-អ្នកប្រតិបត្តិមតកសាសន៍ អាចទទួលកម្រៃដែលបានកំណត់នៅក្នុងមតកសាសន៍បាន ។

២-ក្នុងករណីដែលមតកសាសន៍ពុំបានកំណត់កម្រៃទេ តុលាការត្រូវកំណត់ចំនួនទឹកប្រាក់នៃកម្រៃនោះ តាមពាក្យសុំរបស់អ្នកប្រតិបត្តិមតកសាសន៍ បើយល់ឃើញថាសមរម្យក្នុងការបង់កម្រៃ ដោយពិចារណាទៅលើស្ថានភាពនៃមតិក ទំនាក់ទំនងរវាងម្ចាស់បណ្តាំ និង អ្នកប្រតិបត្តិមតកសាសន៍ និង ស្ថានភាពផ្សេងទៀត ។

**មាត្រា ១២២៧.-** ការលាឈប់ និង ការបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍

១-បើមានមូលហេតុត្រឹមត្រូវ អ្នកប្រតិបត្តិមតកសាសន៍ អាចលាឈប់ពីភារកិច្ចបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

២-បើអ្នកប្រតិបត្តិមតកសាសន៍ បានធ្វេសប្រហែសក្នុងភារកិច្ច ឬ បើមានមូលហេតុត្រឹមត្រូវផ្សេងទៀត អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ អាចដាក់ពាក្យសុំទៅតុលាការឱ្យបញ្ឈប់ជននោះបាន ។

**មាត្រា ១២២៨.-** សោហ៊ុយនៃការប្រតិបត្តិមតកសាសន៍

សោហ៊ុយដែលទាក់ទងទៅនឹងការប្រតិបត្តិមតកសាសន៍ ត្រូវជាបន្ទុកនៃមតិក ។ ប៉ុន្តែ មិនអាចបន្ថយភាគបម្រុង ដោយសារបន្ទុកនេះឡើយ ។

**មាត្រា ១២២៩.-** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីអាណត្តិ

បញ្ញត្តិស្តីពីអាណត្តិ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះមុខនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍ លើកលែងតែមានភាពផ្ទុយនឹងលក្ខណៈនៃតួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍នោះ ។

# ឧបសម្ព័ន្ធ ២៖
# សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ៣

ឧទាហរណ៍ ម្ចាស់បណ្តាំ A បានរក្សាទុកមតកសាសន៍ដែលមានខ្លឹមសារថា "ប្រគល់អច្ច័យទានដីឲ្យ B។ ប៉ុន្តែ B ត្រូវសងទៅ C ១០០០$។" តម្លៃដីនោះគឺ ២០០០$ ប៉ុន្តែ B សងតែ ១០០០$ ទៅឲ្យសន្តតិជន ដោយសារតែការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។ ក្នុងករណីនេះ ដោយសារតែតម្លៃនៃកម្មវត្ថុនៃអច្ច័យទានភ្ជាប់បន្ទុកត្រូវបានកាត់បន្ថយចំនួន ៥០% បន្ទុកក៏ត្រូវកាត់បន្ថយ ៥០% ដែរ។ ដូច្នេះ B ត្រូវសងទៅ C តែ ៥០០$ ប៉ុណ្ណោះ។

មួយវិញទៀត ប្រសិនបើ ម្ចាស់បណ្តាំសរសេរក្នុងមតកសាសន៍ថា "បើទោះជាតម្លៃកម្មវត្ថុនៃអច្ច័យទានភ្ជាប់បន្ទុក ត្រូវបានកាត់បន្ថយដោយសារការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងក៏ដោយ បន្ទុកក៏មិនត្រូវកាត់បន្ថយដែរ។ មតកសាសន៍នេះនឹងបង្កើតអានុភាព ហើយB ត្រូវបង់ ១០០០$ ទៅ C។ ទោះបីជាយ៉ាងណាក៏ដោយ ត្រូវធ្វើការកត់សម្គាល់ថា ទោះបីជាក្នុងករណីនេះក៏ដោយ ក៏ត្រូវអនុលោមតាម មាត្រា ១២១១ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីដែរ។ ដូច្នេះហើយ ប្រសិនបើ B បង់ ១៥០០$ ឲ្យទៅសន្តតិជនដោយសារការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងក៏ដោយ ក៏តម្លៃកម្មវត្ថុនៃអច្ច័យទានភ្ជាប់បន្ទុកមានតម្លៃត្រឹមតែ ៥០០$ ប៉ុណ្ណោះ។ ដូចនេះ B ត្រូវបង់ ៥០០$ ទៅឲ្យ C។

### ៧.៤.៣. ករណីអច្ច័យលាភីមិនបានអនុវត្តករណីយកិច្ច

សន្តតិជន ឬ អ្នកប្រតិបត្តិមតកសាសន៍ ត្រូវមាន ២ ជម្រើស៖

១. ពួកគេអាចដាក់បណ្តឹងទាមទារការអនុវត្តករណីយកិច្ច ពីអច្ច័យលាភី

២. ពួកគេអាចលុបចោលកិច្ចសន្យាអច្ច័យទានដោយផ្អែកលើ មាត្រា ១១៩៣ នៃក្រមរដ្ឋប្បវេណី។

*ទោះបីជាអច្ច័យលាភីមិនបានអនុវត្តករណីយកិច្ចក៏ដោយ ក៏សន្តតិជនមិនអាចរំលាយអច្ច័យទានដោយផ្អែកលើមាត្រា ៤០៧ នៃក្រមរដ្ឋប្បវេណីបានដែរ ពីព្រោះ អច្ច័យទានមិនមែនជាកិច្ចសន្យានោះទេ។

## ៨. ការអនុវត្តមតកសាសន៍

### ៨.១ អត្ថន័យនៃការអនុវត្តមតកសាសន៍

ការអនុវត្តមតកសាសន៍ គឺជាការចាត់ចែងដែលចាំបាច់ ដើម្បីសម្រេចនូវខ្លឹមសារនៃមតកសាសន៍នោះ ក្រោយពេលដែលអានុភាពនៃមតកសាសន៍នោះ បានកើតឡើង។

អានុភាពនៃមតកសាសន៍ កើតឡើងដោយគ្មាននីតិវិធីច្បាស់លាស់នោះទេ។ ឧទាហរណ៍ នៅពេលដែលមតកសាសន៍បានកំណត់ចំណែកមត៌កសម្រាប់សន្តតិជននីមួយៗ មត៌កនោះក្លាយជាកម្មសិទ្ធរបស់សន្តតិជននោះដោយស្វ័យប្រវត្តិតាមរយៈចំណែកដែលត្រូវបានកំណត់នោះ។ ឬក៏អច្ច័យលាភីមានសិទ្ធិទទួលបាននូវកម្មវត្ថុនៃអច្ច័យទាននោះ។ ក៏ប៉ុន្តែ ដើម្បីបំពេញនូវអានុភាពនោះ

ចាំបាច់ត្រូវមាននីតិវិធីច្បាស់លាស់ ។ ឧទាហរណ៍ ត្រូវផ្ទេរការកាន់កាប់ទ្រព្យជាកម្មវត្ថុនៃសន្តតិកម្ម ត្រូវដកលុយពីធនាគារ ត្រូវផ្ទេរការចុះបញ្ជីកម្មសិទ្ធអចលនវត្ថុ ជាដើម។ ដូច្នេះ ក្រមរដ្ឋប្បវេណី មានបញ្ញត្តិដែលចែងអំពី នីតិវិធីនៃការអនុវត្តមតកសាសន៍។

### ៨.២. ការពិនិត្យបញ្ជាក់ និង ការបើកលិខិតមតកសាសន៍ (មាត្រា ១២១៣)

ក្រៅពីមតកសាសន៍ដោយលិខិតយថាភូត មតកសាសន៍ទាំងអស់ត្រូវធ្វើការពិនិត្យបញ្ជាក់ រួមទាំងមតកសាសន៍ដោយវិធីពិសេស (មាត្រា ១២១៣ កថាខណ្ឌ ទី ២ នៃក្រមរដ្ឋប្បវេណី)។ ជាពិសេស ត្រូវកត់សម្គាល់ថា មតកសាសន៍ដោយជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់ជីវិត ត្រូវបានបញ្ជាក់ដោយតុលាការរួចហើយ (មាត្រា ១១៧៧ កថាខណ្ឌទី ២ និង ទី ៣ នៃក្រមរដ្ឋប្បវេណី) ប៉ុន្តែ នៅតែតម្រូវឲ្យមានការពិនិត្យបញ្ជាក់។

### ៨.២.១. គោលបំណងនៃការពិនិត្យបញ្ជាក់មតកសាសន៍

គោលបំណងនៃការពិនិត្យបញ្ជាក់មតកសាសន៍ គឺជាការរក្សាទុកនូវភស្តុតាង។ តាមរយៈការពិនិត្យបញ្ជាក់ តុលាការបានកត់ត្រាទុកនូវស្ថានភាពខាងក្រៅនៃមតកសាសន៍ ចៀសវាងការក្លែងបន្លំ ឬការផ្លាស់ប្តូរ។ ដូច្នេះ តុលាការនឹងកត់ត្រាទុកនូវមតកសាសន៍ដោយការថតចម្លង ការថតយករូបភាព និង ពណ៌នាស្ថានភាពខាងក្រៅនៃមតកសាសន៍ដោយផ្ទាល់មាត់។ ម្យ៉ាងវិញទៀត តុលាការនឹងមិនវិនិច្ឆ័យសុពលភាពរបស់មតកសាសន៍នោះទេ។ ប្រសិនបើមានបុគ្គលណាម្នាក់ចង់លើកមតិប្រឆាំងលើសុពលភាពនៃមតកសាសន៍ បុគ្គលនោះត្រូវដាក់ពាក្យបណ្តឹងទៅតុលាការ។ ការបញ្ជាក់នូវសុពលភាពនៃមតកសាសន៍ មិនមែនជាគោលបំណងនៃការពិនិត្យបញ្ជាក់នោះទេ។

### ៨.២.២. នីតិវិធីសំខាន់ដែលត្រូវគោរពតាមមុនពេលឡើងតុលាការ

អ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ ក្រោយពីបានដឹងពីការចាប់ផ្តើមសន្តតិកម្ម ត្រូវបង្ហាញឯកសារមតកសាសន៍ទៅកាន់តុលាការ ដោយគ្មានការយឺតយ៉ាវ ហើយតុលាការត្រូវពិនិត្យបញ្ជាក់។ ករណីគ្មានអ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ គេត្រូវធ្វើដូចខាងលើដែរ ក្រោយពេលសន្តតិជន ឬ ជនពាក់ព័ន្ធនឹងផលប្រយោជន៍ បានរកឃើញលិខិតមតកសាសន៍នោះ (មាត្រា ១២១៣ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។ ប្រសិនបើសន្តតិជនបានរកឃើញមតកសាសន៍ដែលរហែក ហើយពួកគេគិតថាមតកសាសន៍នោះត្រូវបានលុបចោល ពួកគេនៅតែត្រូវប្រគល់មតកសាសន៍នោះទៅឲ្យតុលាការដើម្បីពិនិត្យបញ្ជាក់ ពីព្រោះតុលាការគឺជាអ្នកកំណត់ចុងក្រោយថា មតកសាសន៍នោះត្រូវបានលុបចោល ឬក៏អត់។

ប្រសិនបើមតកសាសន៍ត្រូវបានបិទដោយប្រថាប់ត្រា គេមិនត្រូវបើកមតកសាសន៍នោះទេ។ អ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ដែលបិទដោយប្រថាប់ត្រា សន្តតិជន ឬ ជនពាក់ព័ន្ធនឹងផលប្រយោជន៍ ត្រូវប្រគល់លិខិតមតកសាសន៍នោះទៅកាន់តុលាការ ដោយមិនត្រូវបើកមើលឡើយ។ ជាធម្មតា មតកសាសន៍ដែលបិទដោយប្រថាប់ត្រា គឺជាមតកសាសន៍ដោយលិខិតសម្ងាត់។ ប៉ុន្តែ ម្ចាស់បណ្តាំក៏អាចបិទប្រថាប់ត្រានូវមតកសាសន៍ដោយលិខិតផ្ទាល់ខ្លួនបានផងដែរ។ ករណីនេះ គេមិនត្រូវបើកមើលមតកសាសន៍ដោយលិខិតផ្ទាល់ខ្លួនដែលបានបិទប្រថាប់ត្រានោះទេ។

ជនដែលបានបើកលិខិតមតកសាសន៍ដោយមិនបានធ្វើការពិនិត្យបញ្ជាក់ ត្រូវពិន័យជាប្រាក់ មិនលើសពី ១ លានរៀល (មាត្រា ១២១៣ កថាខណ្ឌទី ៤ នៃក្រមរដ្ឋប្បវេណី)។ ប៉ុន្តែ ទោះបីជាមតកសាសន៍នោះត្រូវបានបើកមើលនៅក្រៅតុលាការក៏ដោយ មតកសាសន៍នោះក៏នៅតែមានសុពលភាពដដែល (មាត្រា ១២១៣ កថាខណ្ឌទី ៥ នៃក្រមរដ្ឋប្បវេណី)។

### ៨.២.៣. នីតិវិធីពិនិត្យបញ្ជាក់នៅតុលាការ

#### ៨.២.៣.១. សមត្ថកិច្ច

សាលាដំបូង គឺជាកន្លែងមានសមត្ថកិច្ចការចាប់ផ្តើមសន្តតិកម្ម (មាត្រា ៤ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង និង ឧបសម្ព័ន្ធ ផ្នែកទី៥ ចំណុចទី ៥)។ កន្លែងចាប់ផ្តើមសន្តតិកម្ម គឺជាអាស័យដ្ឋានរបស់មតកជននៅពេលទទួលមរណភាព (មាត្រា ១១៤៦ នៃក្រមរដ្ឋប្បវេណី)។

#### ៨.២.៣.២. ការកោះហៅសន្តតិជន ជាអាទិ៍

ជាទូទៅ សន្តតិជនជាអ្នកដាក់ពាក្យសុំស្នើឲ្យមានការពិនិត្យបញ្ជាក់។ យោងតាមក្រមរដ្ឋប្បវេណី មិនតម្រូវឲ្យមានវត្តមានរបស់សន្តតិជន ឬ អច្ច័យលាភីក្នុងការពិនិត្យបញ្ជាក់នោះទេ។ ប៉ុន្តែ តុលាការគួរតែអនុញ្ញាតឲ្យសន្តតិជន ឬ អច្ច័យលាភី មានឱកាសចូលរួមនីតិវិធីពិនិត្យបញ្ជាក់នោះ។ ដូច្នេះតុលាការត្រូវកំណត់ពេលវេលាសម្រាប់ការពិនិត្យបញ្ជាក់ ហើយកោះហៅសន្តតិជន ឬ អច្ច័យលាភីដែលតុលាការបានស្គាល់នោះ។

ជាពិសេស ប្រសិនបើមតកសាសន៍ត្រូវបានបិទដោយប្រថាប់ត្រា មតកសាសន៍នោះនឹងត្រូវបើកនៅក្នុងតុលាការដោយមានវត្តមានរបស់ សន្តតិជន ជនពាក់ព័ន្ធនឹងផលប្រយោជន៍ ឬ អ្នកតំណាងរបស់ពួកគេ (មាត្រា ១២១៣ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី)។ ដូច្នេះ កាលណាមតកសាសន៍បិទដោយប្រថាប់ត្រា តុលាការត្រូវកោះហៅសន្តតិជន និង អច្ច័យលាភីដែលតុលាការបានស្គាល់ (ប៉ុន្តែ ជាធម្មតាតុលាការមិនស្គាល់អច្ច័យលាភីទេ ពីព្រោះមតកសាសន៍ត្រូវបានបិទដោយ

ប្រថាប់ត្រាបាត់ទៅហើយ)។ ទោះបីជាយ៉ាងនេះ ក៏ដោយ ក្នុងករណីមតកសាសន៍បិទដោយប្រថាប់ត្រា មិនមែនមានន័យថា គ្រប់សន្តតិជនទាំងអស់ត្រូវមានវត្តមាននោះទេ។

ការបើកមតកសាសន៍អាចប្រព្រឹត្តទៅបាននៅអំឡុងពេលពាក់កណ្តាលនៃនីតិវិធីពិនិត្យបញ្ជាក់បាន។

### ៨.២.៣.៣. កាលបរិច្ឆេទនៃការពិនិត្យបញ្ជាក់

តុលាការត្រូវពិនិត្យមតកសាសន៍។ ទោះបីជាមតកសាសន៍នោះហាក់ដូចជាគ្មានសុពលភាព ឬ ត្រូវបានលុបចោលក្តី ក៏តុលាការត្រូវតែធ្វើការពិនិត្យបញ្ជាក់ដែរ។ តុលាការគប្បីកត់ត្រាចំណុចដូចខាងក្រោម៖

-បុគ្គលដែលបានស្នើសុំការពិនិត្យបញ្ជាក់

-កាលបរិច្ឆេទការពិនិត្យបញ្ជាក់

-បុគ្គលដែលមានវត្តមាននៅពេលធ្វើនីតិវិធីការពិនិត្យបញ្ជាក់

-ស្ថានភាពខាងក្រៅនៃមតកសាសន៍ ដូចជា ចំនួនទំព័រ ប្រភេទ និង គុណភាពក្រដាស ប្រភេទប៊ិច ហត្ថលេខា និង កាលបរិច្ឆេទនៅក្នុងមតកសាសន៍ ជាដើម។

-ថតរូបភាព និង ថតចម្លងមតកសាសន៍នោះ

## ៨.៣. អ្នកប្រតិបត្តិមតកសាសន៍

### ៨.៣.១. ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍

មតកជនអាចជ្រើសតាំង ឬ ប្រគល់អាណត្តិឲ្យតតិយជនជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ម្នាក់ ឬ ច្រើននាក់បានតាមរយៈមតកសាសន៍ (មាត្រា ១១៨៦ នៃក្រមរដ្ឋប្បវេណី)។ ដូចនេះ ប្រសិនបើមតកសាសន៍បានបញ្ញត្តអំពីការជ្រើសតាំង ឬ ប្រគល់អាណត្តិឲ្យតតិយជនជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ សន្តតិជនត្រូវផ្តល់ដំណឹងទៅបុគ្គលដែលត្រូវបានជ្រើសតាំង ឬ តតិយជននោះ ឲ្យបានឆាប់រហ័សបំផុត។

ប្រសិនបើមតកសាសន៍មិនបានបញ្ញត្តដូចខាងលើនោះទេ សន្តតិជនត្រូវស្នើរសុំទៅតុលាការដើម្បីជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍។ ប៉ុន្តែ គេមិនចាំបាច់ធ្វើការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍គ្រប់ពេលនោះទេ។ ប្រសិនបើ សន្តតិជនទាំងអស់យល់ព្រមអនុវត្តមតកសាសន៍ដោយខ្លួនឯង នោះពួកគេអាចធ្វើដូចនេះបាន។ ករណីនេះ ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍មិនមានភាពចាំបាច់នោះទេ។

ទោះជាយ៉ាងនេះក៏ដោយ ចំពោះការទទួលស្គាល់កូនតាមរយៈមតកសាសន៍ (មាត្រា ៩៩៧ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី) ការផ្តាច់មតិកដោយមតកសាសន៍ (មាត្រា ១១៥២ នៃក្រមរដ្ឋប្បវេណី)

# ឧបសម្ព័ន្ធ ៣៖
# គំរូលិខិតបណ្ដាំមត៌កជាលិខិតឯកជន

# **គម្រូវលិខិតបណ្តាំមត៌ក**

(លិខិតបណ្តាំតាមទម្រង់លិខិតឯកជន)

មត្រា១១៧៤

**១. អត្តសញ្ញាណរបស់ម្ចាស់បណ្តាំ (មតកជន)**

ឈ្មោះ............................................................................................. .............

....................................................................................................................................

..................................................................................................................................។

(ចំណុចនេះអាចបញ្ជាក់អំពីសមត្ថភាពរបស់បុគ្គលដែលអាចធ្វើមតកសាសន៍)

មាត្រា១១៦៨

**២. ស្ថានភាពពេលកំពុងសរសេរមតកសាសន៍**

ខ្ញុំសរសេរបណ្តាំមត៌កនេះ ក្នុងស្ថានភាពដែលខ្ញុំមានស្មារតី ល្អ ដឹងច្បាស់ពីអ្វីដែលខ្ញុំ កំពុងតែចាត់ចែង ហើយអ្វីដែលខ្ញុំសរសេរនៅក្នុងបណ្តាំមត៌កនេះ ជាគោលបំណងរបស់ខ្ញុំ នៅពេលដែលខ្ញុំទទួលមរណភាព ។

(ចំណុចនេះ បញ្ជាក់អំពីសមត្ថភាពរបស់ម្ចាស់បណ្តាំនាពេលធ្វើលិខិតបណ្តាំ)

មាត្រា១១៦៩

**៣. បុគ្គលដែលត្រូវទទួលមត៌ក**

អ្នកដែលត្រូវទទួលមត៌ករបស់ខ្ញុំ គឺ កូន... ........................(បញ្ជាក់អំពីអត្តសញ្ញាណរបស់ជនដែលត្រូវទទួលមត៌ក) ។

**៤. បញ្ជាក់អំពីទំហំនៃទ្រព្យសម្បត្ត**

ដីទី១ ដីទី២ ដីទី៣ ដីទី៤ (អត្តសញ្ញាណនៃដី) លុយ (លេខគណនី ឈ្មោះធនាគារ.....) គ្រឿងអលង្កា សិទ្ធិលើបំណុល (ថ្លៃឈ្នួល ភាគហ៊ុន...........) សុរបទាំងអស់ .....................បំណុល ..........................................................................។

**៥. កំណត់អំពីចំណែកមត៌ក ឬ វិធីបែងចែកមត៌ក**

ដីទី១ដែលមានកំណត់នៅក្នុងចំណុចទី៤ ប្រគល់ឲ្យ កូន A

លុយចំនួន......កំណត់នៅក្នុងចំណុចទី៤ ប្រគល់ឲ្យកូន B

ធ្វើអច្ច័យទាន នូវគ្រឿងអលង្កាដែលមានកំណត់នៅក្នុងចំណុចទី៤ ឲ្យទៅកូន A

ភាគហ៊ុនដែលមានកំណត់នៅក្នុងចំណុចទី៤ ប្រគល់ឲ្យកូនA ២០ ភាគរយចំនួន កូនB ២០ភាគរយ កូនC ៦០ភាគរយ ។

ដីទី២ ដែលមានកំណត់នៅក្នុងចំណុចទី៤ ប្រគល់ឲ្យកូនD ប្រសិនបើ D រៀបការ

(មតកសាសន៍ដែលភ្ជាប់លក្ខខណ្ឌបង្គង់)

មាត្រា១១៩៤

### ៦. កំណត់អ្នកប្រតិបត្តិមតកសាសន៍

មេធាវី .........................................ជាអ្នកប្រតិបត្តិមតកសាសន៍ ដោយទទួលបានកម្រៃ .........................................។

### ៧. ផ្តាច់មត៌ក

កូន E មិនទទួលបានចំណែកមត៌ករបស់ខ្ញុំទេ ពីព្រោះ កូន ប្រមាថមើលងាយខ្ញុំ ធ្វើឲ្យខ្ញុំពិបាកចិត្តគ្រប់ពេល

(មាត្រា១១៥២)

### ៨. អច្ច័យទាន

ដីទី៣ ដែលមានកំណត់នៅក្នុងចំណុចទី៤ ខ្ញុំប្រគល់ឲ្យG ជាក្មួយរបស់ខ្ញុំ ប៉ុន្តែដីនោះ ត្រូវគ្រប់គ្រងដោយ ប្អូនស្រីរបស់ខ្ញុំ .................រហូតដល់ ក្មួយរបស់ខ្ញុំមាននីតិភាព ។

(មាត្រា១១៨៤)

### ៩. ចំនួន ការរក្សាទុក បើក និងប្រកាសបណ្តាំមត៌ក

បណ្តាំមត៌កច្បាប់ដើម ធ្វើឡើងចំនួន១ ច្បាប់

បណ្តាំមត៌កច្បាប់ដើម រក្សាទុកនៅការិយាល័យមេធាវី.....................

បណ្តាំមត៌កនេះ អាចបើកបាន ២ខែ ក្រោយពេលខ្ញុំទទួលមរណភាព

បណ្តាំមត៌កនេះ ត្រូវប្រកាស នៅផ្ទះរបស់ខ្ញុំ ....................................................................

### ១០. បណ្តាំចុងក្រោយរបស់ម្ចាស់បណ្តាំ

ឪពុកសង្ឃឹមថាកូនចេះស្រលាញ់គ្នា មិនធ្វើបាបគ្នា មិនយកទ្រព្យជាត្រើមុខ បំភ្លេចញាតិភាព ធ្វើឲ្យគ្រួសារក្លាយជាអព្វមង្គល ក្រោយពេលឪពុកស្លាប់។

អ្វីៗដែលឪពុកធ្វើគឺដើម្បីកូន ហើយសង្ឃឹមថាកូនៗ នឹងរស់នៅប្រកបដោយ សុភមង្គល និងបានប្រើប្រាស់ទ្រព្យនេះជាដើមទុន សម្រាប់ជីវភាពទៅអនាគត តាមការចាត់ចែងរបស់ម្ដាយកូន។

(មាត្រា១១៨៧)

**ម្ចាស់បណ្ដាំ**

**ហត្ថលេខារបស់ម្ចាស់បណ្ដាំ និងចុះកាលបរិច្ឆេទ**

មាត្រា១១៧៤

# ឧបសម្ព័ន្ធ ៤៖
# ទម្រង់មតកសាសន៍ជាលិខិតយថាភូត

**មតកសាសន៍**

**របស់**

**ពុទ្ធសករាជ**

**ស័ក ឆ្នាំ ថ្ងៃ កើត**

**ត្រូវនឹង គ្រិស្តសករាជ ខែ ថ្ងៃទី**

**វេលាម៉ោង** ប្រាំពីរ **និង**...[illegible]...**នាទី** [illegible]

**សារការី ដែលជាសារការីនៃ មន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា ដែលមានអាសយដ្ឋាននៅផ្ទះលេខ២២ ផ្លូវលេខ ២៨១ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។**

**បានទទួលសំណើពីម្ចាស់បណ្តាំ (អ្នកធ្វើមតកសាសន៍) ដើម្បីធ្វើលិខិតមតកសាសន៍តាមទម្រង់យថាភូត ដូចខាងក្រោម៖**

ដោយមានវត្តមានសាក្សីពីរនាក់៖ -

លោក ភេទប្រុស សញ្ជាតិខ្មែរ កើតនៅថ្ងៃទី កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី មានអាសយដ្ឋានបច្ចុប្បន្ននៅផ្ទះលេខ ផ្លូវ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

លោក ភេទប្រុស សញ្ជាតិខ្មែរ កើតនៅថ្ងៃទី កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី មានអាសយដ្ឋាន បច្ចុប្បន្ននៅផ្ទះលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

សាក្សីដែលតម្រូវឱ្យមានដោយអនុលោមតាមច្បាប់ត្រូវបានជ្រើសរើស និងកោះអញ្ជើញដោយម្ចាស់បណ្តាំ។ តាមការកោះសួររបស់សារការី សាក្សីទាំងពីរនាក់ខាងលើ បានប្រកាសយ៉ាងច្បាស់ជាក់លាក់ និងដាច់ដោយឡែកពីគ្នាថាពួកគេមានសញ្ជាតិខ្មែរ និងជានីតិជន យល់ និងចេះសរសេរអក្សរខ្មែរ ចេះចុះហត្ថលេខា មានសមត្ថភាព ប្រើប្រាស់សិទ្ធិស្របច្បាប់របស់ពួកគេ ហើយប្រកាសថាមិនមែនជាសន្តតិជន អច្ច័យលាភី និងសហព័ទ្ធ ហើយនិងមិនមានទំនាក់ទំនងញាតិលោហិតខ្សែផ្ទាល់ដែលច្បាប់ហាមឃាត់ ជាមួយនឹងម្ចាស់បណ្តាំ និងអច្ច័យលាភីទេ ។ លើសពីនេះ សាក្សីទាំងពីរអះអាងថាកម្រិតភាសាអង់គ្លេសរបស់ខ្លួនគឺអាចយល់ដឹងគ្រប់គ្រាន់នូវខ្លឹមសារទាំងស្រុងរបស់មតកសាសន៍ដែលបានថ្លែងដោយផ្ទាល់មាត់ពីម្ចាស់បណ្តាំចំពោះមុខសារការី។

បានចូលមកនៅចំពោះមុខយើង៖

ម្ចាស់បណ្តាំ ឈ្មោះ: ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ៖ សញ្ជាតិខ្មែរ មានសំបុត្របញ្ជាក់កំណើតលេខ ថ្ងៃទី ហើយកាន់កាប់អត្តសញ្ញាណប័ណ្ណ

សញ្ញាតិខ្មែរលេខ ចុះថ្ងៃទី មានទីកន្លែងកំណើត៖ ភូមិ ឃុំ ស្រុក ខេត្ត ព្រះរាជាណាចក្រកម្ពុជា និងមានអាសយដ្ឋានបច្ចុប្បន្ន៖ នៅភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ដែលមានស្មារតី និងសម្បទាជាប្រក្រតី នៅពេលធ្វើមតកសាសន៍ចំពោះមុខសារការី និងសាក្សីពីរនាក់ ដែលមានខ្លឹមសារទាំងស្រុងរបស់មតកសាសន៍នេះ មានដូចខាងក្រោម៖

១. ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃមតកសាសន៍

ខ្ញុំបាទសូមប្រកាសថា ខ្ញុំបាទគឺជាម្ចាស់កម្មសិទ្ធិ និងជាអ្នកកាន់កាប់ស្របច្បាប់នៃអចលនទ្រព្យ ដូចខាងក្រោម ៖

អចលនវត្ថុជាដី និងផ្ទះ ដែលមានអត្តសញ្ញាណដូចខាងក្រោម ៖

១.១. វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ

- ទំហំដី ៖ ម៉ែត្រការ៉េ និងលេខក្បាលដី
- ទីតាំងដីស្ថិតនៅ ៖ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។
- ចុះថ្ងៃទី ចេញដោយប្រធានមន្ទីររៀបចំដែនដី រាជធានីភ្នំពេញ។

១.២. លិខិតសំគាល់សិទ្ធិបណ្តោះអាសន្នលើដីសង់ផ្ទះ លេខ

- ទំហំដី៖ ទទឹងប្រវែង ២០ ម៉ែត្រ និងបណ្តោយប្រវែង ៤០ ម៉ែត្រ
- ទីតាំងដីស្ថិតនៅ៖ ភូមិ ឃុំ ស្រុក ខេត្ត ព្រះរាជាណាចក្រកម្ពុជា
- ចុះថ្ងៃទី ខែ ឆ្នាំ ចេញដោយគណៈកម្មាធិការប្រជាជនស្រុក

១.៣. លិខិតសំគាល់សិទ្ធិបណ្តោះអាសន្នលើដីសង់ផ្ទះ លេខ

- ទំហំដី៖ ទទឹងប្រវែង ២០ ម៉ែត្រ និងបណ្តោយប្រវែង ៤០ ម៉ែត្រ
- ទីតាំងដីស្ថិតនៅ៖ ភូមិ ឃុំ ស្រុក ខេត្ត ព្រះរាជាណាចក្រកម្ពុជា
- ចុះថ្ងៃទី ខែ ឆ្នាំ ចេញដោយគណៈកម្មាធិការប្រជាជនស្រុក

ច្បាប់ចម្លងនៃវិញ្ញាបនបត្រសម្គាល់អចលនវត្ថុ និងលិខិតសំគាល់សិទ្ធិបណ្តោះអាសន្នលើដីសង់ផ្ទះខាងលើ មានភ្ជាប់ជាឧបសម្ព័ន្ធនៃមតកសាសន៍នេះ។

២.ការប្រកាសអំពីញាតិរបស់ម្ចាស់បណ្តាំ៖

ខ្ញុំបាទសូមប្រកាសថា ខ្ញុំបាទមានកូនបង្កើត ចំនួន ០៦ (ប្រាំមួយ) នាក់ប៉ុណ្ណោះ ដែលមាន ទី១៖ កូនស្រី ឈ្មោះ (ស្លាប់ឆ្នាំ២០០៤) ទី២៖ កូនស្រី ឈ្មោះ ទី៣៖ កូនស្រី ឈ្មោះ ទី៤៖ កូនស្រី ឈ្មោះ ទី៥៖ កូនស្រី ឈ្មោះ និងទី៦៖ កូនស្រី ឈ្មោះ ។

សារការីបានពន្យល់ម្ចាស់បណ្តាំអំពីសិទ្ធិទទួលបានភាគបម្រុង និងទំហំនៃភាគបម្រុងស្របតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ដែលសន្តតិជនផ្សេងទៀតត្រូវទទួលបាន ហើយម្ចាស់បណ្តាំបានយល់ច្បាស់ពីអត្ថន័យនៃបញ្ញត្តិស្តីពីភាគបម្រុងនេះ ដែលកូនៗរបស់គាត់ដែលមានសិទ្ធិលើភាគបម្រុង។ ដូចនេះ ម្ចាស់បណ្តាំ សម្រេចធ្វើការបែងចែកទ្រព្យ

សម្បត្តិរបស់គាត់ទៅអច្ច័យលាភីដូចមានបញ្ជាក់ក្នុងចំណុចទី៣នៃមតកសាសន៍នេះ ដោយហេតុថាកូនស្រី បានទទួលចំណែកទ្រព្យសម្បត្តិជាដី និងផ្ទះលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ និងទ្រព្យសម្បត្តិមួយចំនួនរួចហើយ កាលដែលកូនស្រី ឈ្មោះ នៅរស់។

៣. ការកំណត់អច្ច័យលាភី និងការបែងចែកទ្រព្យសម្បត្តិឱ្យទៅអច្ច័យលាភី ៖

ខ្ញុំបាទសូមបញ្ជាក់ថាកូនស្រីខ្ញុំបាទឈ្មោះ បានទទួលដី និងផ្ទះ និងទ្រព្យសម្បត្តិមួយចំនួនរួច ហើយបន្ទាប់ពីឈ្មោះ បានរៀបការរួចមក, កូនស្រីឈ្មោះ បានទទួល ផ្ទះ១ល្វែងស្ថិតនៅ ខេត្ត ក្នុងបូរី ក្នុងឆ្នាំ២០១៨ និងកូនស្រីឈ្មោះ បានទទួល ផ្ទះ១ល្វែងស្ថិតនៅខេត្ត ក្នុងបូរី ក្នុងឆ្នាំ២០១៨ រួចហើយ។

ហេតុដូច្នេះ៖ ខ្ញុំបាទសូមធ្វើការបែងចែកទ្រព្យសម្បត្តិរបស់ខ្ញុំបាទដែលមានកំណត់ក្នុងចំណុចទី ១ នៃមតក-សាសន៍នេះទៅឱ្យកូនៗបង្កើតរបស់ខ្ញុំបាទក្នុងនាមជាអច្ច័យលាភី ដូចខាងក្រោម៖

ក. អច្ច័យលាភីឈ្មោះ ឈ្មោះ ឈ្មោះ , ឈ្មោះ ,ឈ្មោះ ៖
កូនស្រីបង្កើតរបស់ខ្ញុំបាទឈ្មោះ កើតឆ្នាំ រស់នៅខេត្ត , កូនស្រីបង្កើតរបស់ខ្ញុំបាទឈ្មោះ កើតនៅថ្ងៃទី មានសំបុត្របញ្ជាក់កំណើតលេខ - ចុះថ្ងៃទី ទីកន្លែងកំណើត៖ ភូមិ ខេត្ត , កូនស្រីបង្កើតរបស់ខ្ញុំបាទឈ្មោះ កើតនៅថ្ងៃទី មានសំបុត្រកំណើតលេខ ចុះថ្ងៃទី ទីកន្លែងកំណើត៖ ភូមិ ខេត្ត , កូនស្រីបង្កើតរបស់ខ្ញុំបាទឈ្មោះ កើតនៅថ្ងៃទី មានសំបុត្រកំណើតលេខ ចុះថ្ងៃទី ទីកន្លែងកំណើត៖ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ និងកូនស្រីបង្កើតរបស់ខ្ញុំបាទឈ្មោះ កើតនៅថ្ងៃទី មានសំបុត្រកំណើតលេខ ចុះថ្ងៃទី ទីកន្លែងកំណើត៖ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ត្រូវទទួលបាននូវសិទ្ធិកាន់កាប់ ឬសិទ្ធិកម្មសិទ្ធិលើដី ក្នុងចំណែកម្នាក់ៗចំនួន ១/៥ (មួយភាគប្រាំ) លើចំណែកនៃអចលនទ្រព្យ និងចលនទ្រព្យទាំងអស់ដែលមានក្នុងភូមិគ្រឹះរបស់ខ្ញុំបាទ ដូចមានចែងក្នុងចំណុច ១.២. និងចំណុច១.៣. នៃមតកសាសន៍នេះស្តីពី ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃមតកសាសន៍។ ប៉ុន្តែដកចំណែកចំនួន'២០.០០០,០០ (ពីរម៉ឺន) ដុល្លារអាមេរិកទៅឈ្មោះ ដែលត្រូវជាប្អូនជីដូនមួយក្រោយពេលលក់អចលនវត្ថុទាំងនេះ។

ក្នុងករណីដែលអច្ច័យលាភីណាម្នាក់ ក្នុងចំណោមអច្ច័យលាភីទាំងប្រាំខាងលើទទួលមរណភាពមុនខ្ញុំបាទ ឬព្រមគ្នាជាមួយខ្ញុំបាទ ឬបោះបង់អច្ច័យទាននេះ ខ្ញុំបាទសូមធ្វើការបែងចែកទ្រព្យសម្បត្តិ របស់ខ្ញុំខាងលើឱ្យទៅអច្ច័យលាភីដែលនៅរស់។

ខ. អច្ច័យលាភីឈ្មោះ ,ឈ្មោះ ៖
កូនស្រីបង្កើតរបស់ខ្ញុំបាទឈ្មោះ កើតនៅថ្ងៃទី មានសំបុត្រកំណើតលេខ ចុះថ្ងៃទី ទីកន្លែងកំណើត៖ ភូមិ សង្កាត់ ខណ្ឌ

រាជធានីភ្នំពេញ និងកូនស្រីបង្កើតរបស់ខ្ញុំបាទឈ្មោះ កើតនៅថ្ងៃទី មានសំបុត្រកំណើតលេខ ចុះថ្ងៃទី ទីកន្លែងកំណើត ៖ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ត្រូវទទួលបាននូវសិទ្ធិកាន់កាប់ ឬសិទ្ធិកម្មសិទ្ធិលើដី ក្នុងចំណែកម្នាក់ៗចំនួន ១/២ (មួយភាគពីរ) លើចំណែកនៃអចលនទ្រព្យ និងចលនវត្ថុទាំងអស់ដែលមាននៅក្នុងផ្ទះរបស់ខ្ញុំបាទ ដូចមានចែងក្នុងចំណុច ១.១. នៃមតកសាសន៍នេះស្តីពី ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃមតកសាសន៍ ដោយហេតុថាកូនស្រីទាំងពីរនាក់នេះកំពុងស្នាក់នៅជាមួយខ្ញុំបាទ និងមើលថែទាំឪពុកម្តាយជាប្រចាំរហូតមក។

ក្នុងករណីអច្ច័យលាភីណាមួយ ក្នុងចំណោមអច្ច័យលាភីទាំងពីរខាងលើទទួលមរណភាពមុនខ្ញុំបាទ ឬព្រមគ្នាជាមួយខ្ញុំបាទ ឬបោះបង់អច្ច័យទាននេះ ខ្ញុំបាទសូមធ្វើការបែងចែកទ្រព្យសម្បត្តិរបស់ខ្ញុំខាងលើឱ្យទៅអច្ច័យលាភីដែលនៅរស់។

ទឹកប្រាក់ដែលសេសសល់៖
ចំណែកទឹកប្រាក់មួយចំនួនដែលសេសសល់ពីការលក់ដី និងផ្ទះមួយកន្លែងមានទីតាំងស្ថិតនៅផ្ទះលេខ ភូមិ ឃុំ ស្រុក ខេត្ត ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ចុះថ្ងៃទី ចេញដោយប្រធានសុរិយោដីខេត្ត ដែលត្រូវបានរក្សាទុកដោយកូនស្រីឈ្មោះ ត្រូវបម្រុងទុកសម្រាប់ធ្វើចេតិយម្តាយឈ្មោះ និងខ្ញុំបាទ(ឪពុកម្តាយ) និងសម្រាប់រៀបចំពិធីបុណ្យតាមបែបប្រពៃណីបន្តបន្ទាប់រហូតដល់អស់ទឹកប្រាក់ទាំងនោះ។

៤. អ្នកប្រតិបត្តិមតកសាសន៍

ក. ក្នុងគោលដៅគ្រប់គ្រងមត៌ក និងធ្វើនូវរាល់សកម្មភាពផ្សេងៗដែលចាំបាច់ ដើម្បីប្រតិបត្តិមតកសាសន៍នេះ ខ្ញុំបាទជាម្ចាស់បណ្តាំសូមជ្រើសតាំងអច្ច័យលាភី ឈ្មោះ ជាអ្នកប្រតិបត្តិមតកសាសន៍នេះ ។

ខ. ក្នុងករណីដែលឈ្មោះ មានជម្ងឺធ្ងន់ធ្ងរ ឬទទួលមរណភាពមុនម្ចាស់បណ្តាំ ឬមិនអាចបំពេញកិច្ចជាអ្នកប្រតិបត្តិមតកសាសន៍នេះបានដោយមូលហេតុណាមួយនោះ តួនាទីជាអ្នកប្រតិបត្តិមតកសាសន៍ នឹងត្រូវប្រគល់ទៅឱ្យឈ្មោះ ។

គ. ក្នុងករណីដែលឈ្មោះ ។ មានជម្ងឺធ្ងន់ធ្ងរ ឬទទួលមរណភាពមុនម្ចាស់បណ្តាំ ឬមិនអាចបំពេញកិច្ចជាអ្នកប្រតិបត្តិមតកសាសន៍នេះបានដោយមូលហេតុណាមួយនោះ តួនាទីជាអ្នកប្រតិបត្តិមតកសាសន៍ នឹងត្រូវប្រគល់ទៅឱ្យឈ្មោះ ។

ឃ. ក្នុងករណីដែលឈ្មោះ មានជម្ងឺធ្ងន់ធ្ងរ ឬទទួលមរណភាពមុនម្ចាស់បណ្តាំ ឬមិនអាចបំពេញកិច្ចជាអ្នកប្រតិបត្តិមតកសាសន៍នេះបានដោយមូលហេតុណាមួយនោះតួនាទីជាអ្នកប្រតិបត្តិមតកសាសន៍ នឹងត្រូវប្រគល់ទៅឱ្យឈ្មោះ ។

ង. ក្នុងករណីដែលឈ្មោះ មានជម្ងឺធ្ងន់ធ្ងរ ឬទទួលមរណភាពមុនម្ចាស់បណ្តាំ ឬមិនអាចបំពេញកិច្ចជាអ្នកប្រតិបត្តិមតកសាសន៍នេះបានដោយមូលហេតុណាមួយនោះតួនាទីជាអ្នកប្រតិបត្តិមតកសាសន៍ នឹងត្រូវប្រគល់ទៅឱ្យឈ្មោះ ។

មតកសាសន៍នេះ ត្រូវបានសរសេរទាំងស្រុងដោយសារការី តាមការថ្លែងប្រាប់របស់ម្ចាស់បណ្តាំនៅចំពោះមុខសាក្សីទាំងពីររូប។ សារការីបានសូត្រខ្លឹមសារនៃមតកសាសន៍នេះឱ្យម្ចាស់បណ្តាំ និងសាក្សីស្តាប់ នៅចំពោះមុខសាក្សី ហើយម្ចាស់បណ្តាំ និងសាក្សីអះអាងថាពួកគាត់យល់ច្បាស់លាស់ និងទទួលស្គាល់ថាខ្លឹមសារនៃមតកសាសន៍នេះ គឺពិតជាចេញពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំប្រាកដមែន។

មតកសាសន៍នេះ ត្រូវបានតាក់តែងជាភាសាខ្មែរចំនួន ០១ (មួយ) ច្បាប់ដើម មានចំនួន ០៥ (ប្រាំ) ទំព័រ ដោយរាប់ទាំងទំព័រចុះហត្ថលេខា ដែលត្រូវតម្កល់ទុកនៅ មន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបើកនៅចំពោះមុខសារការីស្របតាមនីតិវិធីនៃច្បាប់ជាធរមាន ។

បន្ទាប់ពីសារការី បានសូត្រខ្លឹមសារទាំងស្រុងនៃមតកសាសន៍នេះឱ្យម្ចាស់បណ្តាំ និងសាក្សីស្តាប់ ហើយម្ចាស់បណ្តាំ និងសាក្សី យល់ព្រមចុះហត្ថលេខា និងផ្តិតស្នាមមេដៃនៅកាលបរិច្ឆេទខាងលើ។

| ម្ចាស់បណ្តាំ<br>ហត្ថលេខា និងស្នាមមេដៃ | | សាក្សី<br>ហត្ថលេខា និងស្នាមមេដៃ | | សាក្សី<br>ហត្ថលេខា និងស្នាមមេដៃ | |
|---|---|---|---|---|---|
| | | | | | |
| ឈ្មោះ: | | ឈ្មោះ: | | ឈ្មោះ: | |

លេខ៖
មន្ទីរសារការី មេគង្គនៃព្រះរាជាណាចក្រកម្ពុជា
បញ្ជាក់ថា ម្ចាស់បណ្តាំ និងសាក្សីទាំងពីរនាក់
បានចុះហត្ថលេខា និង/ផ្តិតស្នាមមេដៃនៅចំពោះមុខខ្ញុំ
ដើម្បីជាសក្ខីភាពខ្ញុំសូមចុះហត្ថលេខា និងប្រថាប់ត្រាមន្ទីរសារការី

KINGDOM OF CAMBODIA

/សារការី